**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université  Royale de Droit et des Sciences de Économiques

Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# ហ៊ីប៉ូតែកធម្មតា និង ហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត

ស្រាវជ្រាវចាប់ពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ ក. **អ៊ុក មុន្នីរ័ត្ន**

ក. **ជន សុផានី**

សាស្ត្រាចារ្យណែនាំ

លោកសាស្ត្រាចារ្យ **ញឹក ខុទ្ធី**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២១

ឆ្នាំចូលសិក្សា ២០១៧

ឆ្នាំសរសេរសារណា ២០២១

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université  Royale de Droit et des Sciences de Économiques

Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# ហ៊ីប៉ូតែកធម្មតា និង ហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត

ស្រាវជ្រាវចាប់ពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ   ក. **អ៊ុក មុន្នីរ័ត្ន**

ក. **ជន សុផានី**

សាស្ត្រាចារ្យណែនាំ

លោកសាស្ត្រាចារ្យ **ញឹក ឧត្តី**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២១

ឆ្នាំចូលសិក្សា   ២០១៧

ឆ្នាំសរសេរសារណា   ២០២១

# លិខិតថ្លែងអំណរគុណ

នាងខ្ញុំ **អ៊ុក មុន្នីរ័ត្ន** និង **ជន សុផានី** ជានិស្សិតបរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ ឆ្នាំទី៤ ជំនាន់ទី២១ នៃ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ជាដំបូងសូមលើកដៃក្រាបបង្គំអ្នកមានគុណទាំងទ្វេ គឺ លោកឪពុក **អ៊ុក ឈុនអេង** អ្នកម្តាយ **អ៊ុំ ណារិន** ព្រមទាំង លោកឪពុក **ម៉ី សាខុធ** អ្នកម្តាយ **លាង សុផាត**។ នាងខ្ញុំទាំងពីរ សូមអនុញ្ញាតសម្តែងនូវការគោរពប្រតិបត្តិ ដឹងគុណ យ៉ាងជ្រាលជ្រៅចំពោះអ្នកមានគុណទាំងពីរ ដែលបានផ្តល់កំណើតដល់រូបនាងខ្ញុំ និងបានខិតខំពុះពារ ចិញ្ចឹមបីបាច់ការពារ និងថែរក្សាកូនយ៉ាងប្រុងប្រយ័ត្ន។ លោកបានផ្តល់នូវទំនុកបំរុងយ៉ាងល្អបំផុតដល់កូនរហូតមកទាំងផ្លូវកាយ ផ្លូវចិត្ត សម្ភារៈ អាហារូបត្ថម្ភសម្រាប់រស់នៅ និងជាពិសេសគឺការឧបត្ថម្ភជ្រោមជ្រែង លើកទឹកចិត្តឱ្យនាងខ្ញុំបានបន្តការសិក្សាតាំងពីបឋមសិក្សា រហូតដល់ ឧត្តមសិក្សាបានខ្ពង់ខ្ពស់រហូតដល់ថ្ងៃនេះ។ កូនមិនភ្លេចឡើយនូវគុណនូបការៈនៃលោកទាំងបួន ដែលបានអប់រំ និងទូន្មានឱ្យកូនក្លាយជាកោសិការសង្គមដ៏មានតម្លៃក្នុងការអភិវឌ្ឍសង្គមគ្រួសារ និងសង្គមជាតិនេះ។

ជាបន្ទាប់ នាងខ្ញុំទាំងពីរសូមសម្តែងនូវការគោរពដល់ **ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង និង លោក លោកស្រីសាស្ត្រាចារ្យ** ទាំងអស់ដែលបាន ខិតខំកម្លាំងកាយ និងកម្លាំងចិត្តក្នុងការដឹកនាំ គ្រប់គ្រង បង្ហាត់បង្រៀនដល់ក្រុមនាងខ្ញុំជាច្រើន ទាក់ទងក្នុងវិស័យច្បាប់ និងស្ថានភាពសង្គមជាក់ស្តែង ជាពិសេសបានផ្តល់នូវដំបូន្មានដល់ពួកយើងជាច្រើនរហូតមក ដើម្បីជាទុនដល់ការស្រាវជ្រាវ និងគំនិតក្នុងការតាក់តែងស្នាដៃនេះឡើង។

ក្នុងវេលានេះ នាងខ្ញុំទាំងពីរសូមថ្លែងអំណរ អរគុណយ៉ាងអនេកប្បការ ជូនចំពោះ **លោកសាស្ត្រាចារ្យ ញឹក វុទ្ធី** ដែលបានជួយដឹកនាំជ្រោមជ្រែងនាងខ្ញុំ ក្នុងរយៈពេលសរសេរសារណាបញ្ចប់ឆ្នាំមួយនេះរហូតមក។ លោកបាន ចំណាយពេលដ៏មានតម្លៃក្នុងការផ្តល់យោបល់ និងកែលម្អនូវស្នាដៃនេះរហូតនាងខ្ញុំបានសម្រេចដោយជោគជ័យនូវ ពេលនេះ។

ជាទីបញ្ចប់ ក្រុមនាងខ្ញុំសូមលើកដៃបួងសួង ដល់រាល់វត្ថុស័ក្តិសិទ្ធទាំងអស់នៅក្នុងប្រទេសកម្ពុជា សូមឱ្យ ជួយថែរក្សាការពារលោកទាំងឡាយខាងលើ ឱ្យទទួលបានសេចក្តីសុខគ្រប់ប្រការ អាយុយឺនយូរ និងទទួលបាន ជោគជ័យគ្រប់ភារកិច្ចការងារ និងគ្រប់ពេលវេលា។

# អារម្ភកថា

ក្រុមនាងខ្ញុំពិតជាមានសេចក្ដីសោមនស្សក្នុងការស្រាវជ្រាវលើប្រធានបទមួយស្ដីពី **ហ៊ីប៉ូតែកធម្មតា និង ហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្ដែត។** កិច្ចការស្រាវជ្រាវនេះ កើតចេញពីការខិតខំប្រឹងប្រែងព្យាយាមរបស់នាងខ្ញុំទាំងពីរ នៅក្រោមការដឹកនាំប្រកបដោយការយកចិត្តទុកដាក់ខ្ពស់បំផុតពីសំណាក់ **លោកសាស្ត្រាចារ្យ ញឹក ឧុឆ្វី។** ក្រុមនាងខ្ញុំ បានស្រាវជ្រាវរកឯកសារនានាដែលពាក់ព័ន្ធនឹងសារណានេះ ព្រមទាំងទទួលបានចំណេះដឹងពីសាស្ត្រាចារ្យ បូករួមនឹងការឆ្វេងយល់នូវចំពោះដឹងទូទៅបន្ថែមដោយខ្លួនឯង ធ្វើឱ្យស្នាដៃស្រាវជ្រាវនេះលេចជារូបរាងឡើងនាពេលនេះ។ នៅក្នុងការស្រាវជ្រាវលើប្រធានបទ វាមិនមែនជាការងាយស្រួលឡើយដោយហេតុថា ការស្រាវជ្រាវទាមទារនូវការស្វែងរកឯកសារដែលអាចជឿទុកចិត្តបាន ដើម្បីយកមកធ្វើការតាក់តែងអត្ថបទជាលាយលក្ខណ៍អក្សរ។ ការស្រាវជ្រាវមួយនេះបានបង្កើនចំណេះដឹងយ៉ាងច្រើនដល់នាងខ្ញុំទាំងពីរនាក់អំពី **ហ៊ីប៉ូតែកធម្មតា និង ហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្ដែត** ដែលមានដូចជា៖ សញ្ញាណទូទៅនៃ ការបង្កើតហ៊ីប៉ូតែក ការអនុវត្តនៃហ៊ីប៉ូតែកធម្មតា និងហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្ដែត ព្រមទាំងការរំលត់នៃហ៊ីប៉ូតែកផងដែរ។

ការសម្រេចចិត្តជ្រើសរើសនូវប្រធានបទនេះ គឺធ្វើឡើងក្នុងគោលបំណងបង្ហាញពីអានុភាព និង ការអនុវត្តនូវហ៊ីប៉ូតែកទាំងពីរហ៊ីប៉ូតែកធម្មតានិងហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្ដែត ដោយបញ្ជាក់ពីចំណុចពិសេសទាំងអស់ដោយការពន្យល់ និង កំណត់បង្ហាញកាន់តែច្បាស់តាមចំណែកថ្នាក់នៃហ៊ីប៉ូតែក រួមផ្សំដោយការបកស្រាយតាមក្រមរដ្ឋប្បវេណីជាគោល។ លើសពីនេះ ការចងក្រងសារណាបញ្ចប់ការសិក្សានេះឡើង មានគោលដៅចង់ជំរុញអោយនិស្សិត និងមិត្តៗអ្នកអាន បានយល់និងសិក្សាបន្ថែមទៅលើចំណេះដឹងអំពីនីតិកាតព្វកិច្ចដែលខ្លួនអាចនឹងអនុវត្តនាថ្ងៃខាងមុខ តាមក្រមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

សារណាបញ្ចប់ការសិក្សាមួយនេះ គឺជាសមិទ្ធិផលមួយដែលក្រុមនាងខ្ញុំបានខិតខំស្វះស្វែងស្រាវជ្រាវព្រមទាំងធ្វើការវិភាគទៅលើដំណើរការនីមួយៗ ប្រកបដោយការយកចិត្តទុកដាក់បំផុត។ ប៉ុន្តែបើទោះបីជាមានការខិតខំស្រាវជ្រាវយ៉ាងណាក៏ដោយ ក៏កិច្ចការស្រាវជ្រាវនីមួយៗ រមែងតែងតែជួបប្រទេះនូវភាពខ្វះចន្លោះ និងមិនទាន់មានន័យគ្រប់ជ្រុងជ្រោយមួយរយភាគរយនៅឡើយនោះទេ។ ហេតុនេះហើយ នាងខ្ញុំទាំងពីរសង្ឃឹមថាអ្នកអាននិងអ្នកស្រាវជ្រាវទាំងអស់ធ្វើការអភ័យទោសដល់ក្រុមនាងខ្ញុំ ចំពោះកំហុសដោយចេតនានៅក្នុងប្រការណាមួយ ហើយក្រុមនាងខ្ញុំក៏សូមធ្វើការស្វាគមន៍ជានិច្ចនូវរាល់មតិរិះគន់ក្នុងន័យស្ថាបនាទាំងឡាយពីសំណាក់អ្នកអាន និងអ្នកស្រាវជ្រាវ ដើម្បីជាជំនួយឱ្យក្រុមនាងខ្ញុំមានការអភិវឌ្ឍខ្លួនកាន់តែប្រសើរនិងមានភាពរីកចម្រើនជាងមុន។

# មាតិកា

ទំព័រ


**សេចក្តីផ្តើម** ........................................ ១

**ជំពូកទី១**

**សញ្ញាណ និង លក្ខខណ្ឌទូទៅនៃការបង្កើតហ៊ីប៉ូតែកក**

**ផ្នែកទី១. សញ្ញាណទូទៅ** ........................................ ២

**កថាភាគទី១. ប្រវត្តិនៃសិទ្ធិហ៊ីប៉ូតែកនៅកម្ពុជានិង និយមន័យ** ........................................ ២

**កថាភាគទី២. គោលការណ៍ទូទៅនៃហ៊ីប៉ូតែក** ........................................ ៤

**ផ្នែកទី២. លក្ខខណ្ឌទូទៅនៃការបង្កើតហ៊ីប៉ូតែក** ........................................ ៥

**កថាភាគទី១. ការបង្កើតហ៊ីប៉ូតែក** ........................................ ៦

**កថាភាគទី២. អានុភាពនៃហ៊ីប៉ូតែក** ........................................ ៨

**ជំពូកទី២**

**ការអនុវត្ត និង ការចាត់ចែងហ៊ីប៉ូតែក**

**ផ្នែកទី១. ការអនុវត្ត និងការចាត់ចែងនៃហ៊ីប៉ូតែកធម្មតា** ........................................ ១០

**កថាភាគទី១. ការអនុវត្តហ៊ីប៉ូតែកធម្មតា** ........................................ ១០

ក.ហ៊ីប៉ូតែករួម ........................................ ១១

**កថាភាគទី២. ការចាត់ចែងហ៊ីប៉ូតែកធម្មតា** ........................................ ១២

ក.ហ៊ីប៉ូតែកបន្ត ........................................ ១៣

ខ.អនុប្បទាន ឬការបោះបង់ហ៊ីប៉ូតែក ........................................ ១៣

គ.អនុប្បទាន ឬការបោះបង់ និង ការផ្លាស់ប្តូរនូវលំដាប់នៃហ៊ីប៉ូតែក ........................................ ១៤

**ផ្នែកទី២. ការអនុវត្ត និង ការចាត់ចែងហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត** ១៤

**កថាភាគទី១. ការអនុវត្តហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត** ........................................ ១៥

ក. ការកំណត់នៅក្នុងកិច្ចសន្យាបង្កើតហ៊ីប៉ូតែក ........................................ ១៥

ខ. ការកំណត់ប្រាក់ដើមជាស្ថាពរ ........ ១៦
គ. ការកែប្រែខ្លឹមសារនៃកិច្ចសន្យា........ ១៧
**កថាភាគទី២.ការចាត់ចែងហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្ដែត** ........ ១៨
ក. មុនពេលប្រាក់ដើមត្រូវបានកំណត់ ........ ១៨
ខ. ក្រោយពេលប្រាក់ដើមត្រូវបានកំណត់........ ១៩
**ផ្នែកទី៣ នីតិវិធីនៃការអនុវត្តហ៊ីប៉ូតែក** ........ ២១
**កថាភាគទី១ ការរឹបអូស** ........ ២២
ក. ការរៀបចំដាក់ពាក្យ........ ២២
ខ. ការធ្វើពាក្យសុំ ........ ២៤
គ. ការដាក់ពាក្យសុំ........ ២៤
ឃ. ការពិនិត្យពាក្យសុំ និង ការលើកចោលពាក្យសុំ ........ ២៤
ង. ដីការសម្រេចចាប់ផ្ដើមលក់ដោយបង្ខំ........ ២៥
ច. ការផ្ទុកផ្ដាក់ឱ្យចុះបញ្ជីរឹបអូស........ ២៥
ឆ. ការចុះបញ្ជីអំពីការរឹបអូស........ ២៦
ជ. ការបញ្ជូនឯកសារចម្លងដែលមានសេចក្ដីបញ្ជាក់នៃសៀវភៅចុះបញ្ជីអចលនវត្ថុ........ ២៦
ឈ. ការបញ្ជូនដីកាសម្រេចចាប់ផ្ដើមលក់ដោយបង្ខំទៅកូនបំណុលនៃការអនុវត្ត ........ ២៦
**កថាភាគទី២ ការលក់** ........ ២៧
ក. ដីកាសម្រេចកំណត់ពេលចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែក និង ការប្រកាសជាសាធារណៈ ........ ២៧
ខ. ការទាមទារឱ្យចែកចំណែក........ ២៧
គ. ការដាស់តឿនឱ្យរាយការណ៍អំពីសិទ្ធិលើបំណុល........ ២៧
ឃ. ការវាយតម្លៃ ........ ២៨
ង. ឯកសារលំអិតអំពីវត្ថុ, ដីកាសម្រេចកំណត់តម្លៃលក់អប្បបរមា និង ការបង្គាប់ឱ្យអនុវត្តការលក់ ........ ២៨
ច. ការប្រកាសជាសាធារណៈនូវកាលបរិច្ឆេទនៃការលក់ជាអាទិ៍ និង ការទុកឯកសារលំអិតអំពីវត្ថុជាអាទិ៍ ២៩
ឆ. ការអនុវត្តការលក់ និង ការកំណត់កាលបរិច្ឆេទដើម្បីចេញដីកាសម្រេចការលក់........ ២៩

ជ. ដីកាសម្រេចអនុញ្ញាតឱ្យលក់ ឬដីកាសម្រេចមិនអនុញ្ញាតឱ្យលក់ ........ ២៩

ឈ. ការកំណត់ពេលនៃការបង់ថ្លៃលក់ និង ការបង់ថ្លៃលក់........ ៣០

ញ. ការផ្ទុកផ្ដាក់ឱ្យចុះបញ្ជី និង ការចុះបញ្ជីផ្អែកតាមការផ្ទុកផ្ដាក់........ ៣០

**កថាភាគទី៣ ការចែកចំណែក** ........ ៣០

ក. ការកំណត់កាលបរិច្ឆេទនៃការចែកចំណែក........ ៣០

ខ. ការជូនដំណឹងអំពីកាលបរិច្ឆេទនៃការចែកចំណែក និងការដាស់តឿនឱ្យដាក់លិខិតគណនា ជាដើម ៣១

គ. ការបង្កើតសេចក្តីព្រាងដើមនៃតារាងចែកចំណែក........ ៣១

ឃ. ការបើកកាលបរិច្ឆេទនៃការចែកចំណែក និង ការអនុវត្តការចែកចំណែក ........ ៣១

**ជំពូកទី៣**

**ការលក់នៃហ៊ីប៉ូតែក**

**ផ្នែកទី១ ការលក់ដោយការទាមទារ** ........ ៣៣

**ផ្នែកទី២. ការលក់ដោយអាជ្ញាយុកាល**........ ៣៤

**សេចក្ដីសន្និដ្ឋាន**........ ៣៦

**អនុសាសន៍**........ ៣៧

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

ក្នុងជីវភាពប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋម្នាក់ៗ គឺតែងតែមានជួបនៅបញ្ហាកង្វះខាតនូវឥណទាន ដោយខ្វះមិនបាន ទោះក្នុងគោលបំណង ដោះស្រាយបញ្ហាចំពោះមុខ ការពង្រីកអាជីវកម្ម ឬដោយគោលបំណងណាមួយក៏ដោយ យើងសង្កេតឃើញថា ប្រជាជនសម្រេចចិត្តជ្រើសយកការខ្ចីឥណទាន ដើម្បីដោះស្រាយបញ្ហាហិរញ្ញវត្ថុទាំងនេះ។ ក្នុងគោលដៅបង្កើនទំនុកចិត្តរវាងភាគីក្នុងកិច្ចសន្យាផ្តល់កម្ចីឥណទាននេះ ក៏ដូចជាការពារផលប្រយោជន៍គូភាគីទាំងសងខាង របបគតិយុត្តលើ សិទ្ធិប្រាតិភោគប្រត្យក្ស ត្រូវបានបង្កើតឡើង។ សិទ្ធិប្រតិភោគប្រត្យក្ស មានន័យថា កូនបំណុលប្រើប្រាស់នូវសិទ្ធប្រត្យក្ស[1] ដែលមានទៅលើវត្ថុដែលជាកម្មសិទ្ធិរបស់ខ្លួន យកទៅធានាលើបំណុលដែលខ្លួនបានខ្ចីពីភាគីម្ចាស់បំណុល។ សិទ្ធិបាននេះបានបែងចែកជា ៥ រួមមាន ការធានាសិទ្ធិឃាត់ទុក ឯកសិទ្ធិ សិទ្ធិលើការបញ្ចាំ ហ៊ីប៉ូតែក និង សិទ្ធិប្រាតិភោគដោយអនុប្បទាន។

បច្ចុប្បន្ន ក្នុងចំណោមសិទ្ធិទាំង៥ ខាងលើនេះ ហ៊ីប៉ូតែក ត្រូវបានប្រើប្រាស់ច្រើនជាងគេ គឺទាំង ធនាគារ និង គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។ ស្របពេលដែលកំណើនសេវាកម្មផ្តល់កម្ចីឥណទានដោយមានការធានាដោយវត្ថុហ៊ីប៉ូតែកមានការកើនឡើងផងនោះ ក៏នៅមានប្រជាជនជាច្រើននៅមិនទាន់ យល់ និងស្គាល់ច្បាស់នៅឡើយថាតើហ៊ីប៉ូតែកជាអ្វី។ ដោយមើលឃើញពីសក្តានុពលធនាគារ ក៏ដូចជាស្ថាប័នផ្តល់ប្រាក់កម្ចីនៅប្រទេសកម្ពុជា ព្រមទាំងតំរូវការហិរញ្ញវត្ថុក្នុងជីវភាព និងការពង្រីកអាជីវកម្មពីសំណាក់ប្រជាពលរដ្ឋដែលមានបំណងចង់ប្រើប្រាស់ប្រតិបត្តិការប្រាតិភោគហ៊ីប៉ូតែក ដូច្នេះក្រុមយើងខ្ញុំក៏បានសម្រេចចិត្តស្រាវជ្រាវ និងចងក្រងសារណានេះឡើងក្រោមប្រធានបទ **ហ៊ីប៉ូតែកធម្មតា និង ហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត** ដោយក្រុមយើងខ្ញុំនឹងធ្វើការផ្តោតសំខាន់ទៅលើ សញ្ញាណ លក្ខខណ្ឌទូទៅក្នុងការបង្កើតហ៊ីប៉ូតែក ការអនុវត្ត ការចាត់ចែង ព្រមទាំងការរលត់ទៅវិញនៃហ៊ីប៉ូតែកធម្មតា និង ហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ដែលកំពុងអនុវត្តនាពេលបច្ចុប្បន្ននៅក្នុងប្រទេសកម្ពុជា ។

ដើម្បីឲ្យមានភាពងាយស្រួលក្នុងការអធិប្បាយឲ្យកាន់តែច្បាស់អំពីប្រធានបទស្តីពី **ហ៊ីប៉ូតែកធម្មតា និង ហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត** យើងបានបែងចែកប្រធានបទជា ៣ជំពូកធំៗ គឺ៖

ជំពូកទី១៖ សញ្ញាណ និង ល័ក្ខខ័ណ្ឌទូទៅនៃការបង្កើតហ៊ីប៉ូតែក

ជំពូកទី២៖ ការអនុវត្ត និងការចាត់ចែងនៃហ៊ីប៉ូតែកធម្មតា និង ហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត

ជំពូកទី៣៖ ការរលត់ទៅវិញនៃហ៊ីប៉ូតែក ។

[1] សិទ្ធិប្រត្យក្ស គឺជាសិទ្ធិគ្រប់គ្រងដោយចំពោះលើវត្ថុ ដែលអាចអះអាងចំពោះបុគ្គលដទៃទៀតបាន។ សន្ទានុក្រមផ្នែករដ្ឋប្បវេណី, បោះពុម្ពដោយទីស្តីការគណៈរដ្ឋមន្ត្រី, ឆ្នាំ២០០៧

# ជំពូកទី១

# សញ្ញាណ និងលក្ខខណ្ឌទូទៅ

# នៃការបង្កើតហ៊ីប៉ូតេក

# ជំពូកទី១

# សញ្ញាណ និង លក្ខខ័ណ្ឌទូទៅនៃការបង្កើតហ៊ីប៉ូតែក

ហ៊ីប៉ូតែក បានជ្រាបចូលក្នុងសង្គមខ្មែរមកច្រើនសម័យកាល ប៉ុន្តែមានតែបញ្ញត្តិក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ តែប៉ុណ្ណោះដែលមានចែងលម្អិត ច្បាស់លាស់និងបែងចែកច្បាស់អំពីហ៊ីប៉ូតែកពាក់ពន្ធ័នឹង និយមន័យ,ប្រភេទ, ក៏ដូចជាលក្ខខណ្ឌ[2]ទូទៅក្នុងការបង្កើតហ៊ីប៉ូតែក, ព្រមទាំងអានុភាពនៃហ៊ីប៉ូតែក។

## ផ្នែកទី១. សញ្ញាណទូទៅ

### កថាភាគទី១. ប្រវត្តិនៃសិទ្ធិហ៊ីប៉ូតែកនៅកម្ពុជានិង និយមន័យ

ហ៊ីប៉ូតែក បានជ្រាបចូលក្នុងសង្គមខ្មែរ តាមរយៈអាណានិគមនិយមបារាំង ដោយត្រូវបានបញ្ចូលទៅក្នុងក្រមរដ្ឋប្បវេណី ឆ្នាំ១៩២០ ដែលជារបបគតិយុត្តពាក់ពន្ធ័នឹងប្បវេណីរបស់ប្រជាពលរដ្ឋខ្មែរ តាមបែបទំនើបដំបូងបង្អស់ (បញ្ញត្តិតាមទំនៀមទម្លាប់ខ្មែរ និង វិធានថ្មីតាមប្រពន្ធ័បារាំង)។ ក្រមរដ្ឋប្បវេណីនេះឲ្យនិយមន័យហ៊ីប៉ូតែកថា **"ជាប្រាតិភោគប្រត្យក្សដែលបើកឲ្យម្ចាស់បំណុលប្តឹងនៅវេលាដែលដល់កំណត់សង ហើយសុំឲ្យលក់អចលនវត្ថុនោះ ទោះនៅលើដែនរណាក្តី ដើម្បីយកប្រាក់មកសងខ្លួនជាអ្នកមានឯកសិទ្ធិ និងបុរិមាជាងម្ចាស់បំណុលឯទៀត ដោយគ្មានដកអចលនវត្ថុនោះពីកម្មសិទ្ធិករ"** ហើយការបង្កើតហ៊ីប៉ូតែកត្រូវធ្វើតាមច្បាប់បារាំង និងត្រូវធ្វើចំពោះមុខសារការីជាដាច់ខាត បើពុំនោះទេត្រូវចាត់ទុកជាមោឃៈ។

ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ(១៩៧៥-១៩៧៩) បានបំផ្លាញនូវប្រពន្ធ័គតិយុត្តទាំងស្រុង។ ក្រោយថ្ងៃរំដោះឆ្នាំ១៩៧៩ រដ្ឋអំណាចថ្មីបានរៀបចំប្រទេស ក៏ដូចជាប្រពន្ធ័ច្បាប់និង បទដ្ឋានគតិយុត្តឡើងវិញ ប៉ុន្តែនៅពេលនោះពុំទាន់មានច្បាប់ណាមួយបើកឲ្យមានប្រាតិភោគប្រត្យក្សនោះទេ ដោយហេតុថាកម្ពុជាកំពុងស្ថិតក្រោមរបបសង្គមនិយម ដែលមិនអនុញ្ញាតឲ្យមានកម្មសិទ្ធិឯកជនទេ។ បន្ទាប់មកវិសោធនកម្មរដ្ឋធម្មនុញ្ញ និងកំណែទម្រង់រដ្ឋថ្មី បានប្តូររបបកម្ពុជាមកជារបបសេដ្ឋកិច្ចទីផ្សាសេរីវិញ ដែលបើកឲ្យមានកម្មសិទ្ធិលើដីធ្លីសម្រាប់ប្រជាពលរដ្ឋវិញ។ ឆ្នាំ១៩៩២ ច្បាប់ភូមិបាលត្រូវបានអនុម័តដោយសភានៃរដ្ឋកម្ពុជា បានបញ្ជាក់លក្ខខណ្ឌ និងវិធាននានាពាក់ពន្ធ័ហ៊ីប៉ូតែក ដោយចម្លងនិយមន័យពីក្រមរដ្ឋប្បវេណីឆ្នាំ១៩២០។

នៅឆ្នាំ២០០១ ប្រទេសកម្ពុជាបានឈានទៅដល់ការ អនុម័តច្បាប់ភូមិបាលថ្មីមួយទៀតដោយរដ្ឋសភានីតិកាលទី២ ក្នុងគោលបំណងកែលម្អរបបកម្មសិទ្ធិលើអចលនវត្ថុ និងការធ្វើទំនើបកម្មលើប្រពន្ធ័ចុះបញ្ជីដីធ្លី[3]។

---

[2] ពាក្យ ល័ក្ខខ័ណ្ឌ ឬ លក្ខខណ្ឌ គឺមានន័យដូចគ្នា យោងតាមវចនានុក្រម ខ្មែរ ពុទ្ធសាសនបណ្ឌិត្យ បោះពុម្ព លើក ទី ៥(១៩៦៧-៦៨)

[3] ម៉ៅ សិលា, "ជំនួយស្មារតីៈ និយមន័យ និងការចុះបញ្ជីហ៊ីប៉ូតែកនៅកម្ពុជា",ការផ្សព្វផ្សាយរបស់សមាគមសាលាត្រាជូ, ខែមករា ឆ្នាំ ២០១៨, http://salatraju.com/post/349 , ទំព័រ១, ០៧ កក្កដា ២០២១

ច្បាប់ថ្មីនេះបានកំណត់ថា "**ហ៊ីប៉ូតែក គឺជាប្រាតិភោគភណ្ឌិកដែលបើកឲ្យម្ចាស់បំណុលប្តឹងសុំឲ្យលក់អចលនវត្ថុនោះ នៅពេលដល់កំណត់សង ទោះជាអចលនវត្ថុនោះនៅលើដៃជនណាក៏ដោយ ដើម្បីយកប្រាក់មកសងខ្លួន និងម្ចាស់បំណុលដទៃទៀតដែលមានបុព្វសិទ្ធិ និងបុរិមា ដោយមិនដកអចលនវត្ថុពីកម្មសិទ្ធិករទេ** "។[4]

ក្រោយមកទៀត ក្រសួងយុត្តិធម៌សហការជាមួយទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (ហៅកាត់ JICA) បានផ្តើមធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី តាមរយៈគម្រោងអភិវឌ្ឍន៍ប្រពន្ធ័ច្បាប់ និងយុត្តិធម៌ដែលត្រូវបានអនុម័តជាផ្លូវការនិង ត្រូវបាន **ព្រះករុណាសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ឡាយព្រះហស្តលេខាប្រកាសឲ្យប្រើក្នុងឆ្នាំ២០០៧។ បញ្ញត្តិពាក់ពន្ធ័នឹងហ៊ីប៉ូតែកមានលក្ខណៈលម្អិតច្បាស់លាស់ជាងមុន ដោយផ្អែកតាមច្បាប់ចាស់ ដែលយកតាមប្រពន្ធ័បារាំង និងផ្អែកតាមជំនួយបច្ចេកទេសរបស់JICA ដែលយកតាមប្រពន្ធ័គតិយុត្តជប៉ុន។[5] នៅក្នុងក្នុងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ហ៊ីប៉ូតែកត្រូវបានបែងចែកជាពីរប្រភេទគឺ៖ ហ៊ីប៉ូតែកធម្មតា និង ហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត។

**ហ៊ីប៉ូតែកធម្មតា** គឺជា សិទ្ធប្រាតិភោគដែលម្ចាស់បំណុលហ៊ីប៉ូតែក មានសិទ្ធិទទួលបានការសងចំពោះសិទ្ធិលើបំណុលរបស់ខ្លួន ដោយមានអាទិភាពជាងម្ចាស់បំណុលផ្សេងទៀតចំពោះអចលនវត្ថុដែលបានដាក់ជាប្រាតិភោគនៃកាតព្វកិច្ចដោយកូនបំណុល ឬតតិយជនមិនផ្ទេរការកាន់កាប់។[6]

ម្យ៉ាងទៀត សូមបញ្ជាក់ថា ហ៊ីប៉ូតែកគឺជា ការដាក់ប្រាតិភោគដោយអចលនវត្ថុ ដោយមិនមានការផ្ទេរការកាន់កាប់ទៅឲ្យម្ចាស់បំណុលហ៊ីប៉ូតែកទេ។ ការកាន់កាប់លើអចលនវត្ថុដែលជាកម្មវត្ថុនៃការដាក់ប្រាតិភោគដោយហ៊ីប៉ូតែក នៅតែឋិតក្នុងការកាន់កាប់ដោយអ្នកបង្កើតហ៊ីប៉ូតែក។

**ហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត** គឺជាសិទ្ធិដែលត្រូវបានបង្កើតឡើងដើម្បីធានាកាតព្វកិច្ចមិនកំណត់ដែលអាចកើតឡើងរវាងម្ចាស់បំណុល និងកូនបំណុល ដោយសារជួញដូរជានិរន្តន៍ដែលមានប្រភេទកំណត់ក្នុងកម្រិតនៃចំនួនអតិបរមា ដោយទំហំនៃសិទ្ធិលើបំណុលមិនកំណត់នេះ អាចត្រូវបានកំណត់នៅក្នុងកិច្ចសន្យាបង្កើតហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត។[7]

---

[4] មាត្រា ១៩៨ ច្បាប់ភូមិបាល ឆ្នាំ ២០០១

[5] ម៉ៅ សិលា, "ជំនួយស្មារតី៖ និយមន័យ និងការចុះបញ្ជីហ៊ីប៉ូតែកនៅកម្ពុជា",ការផ្សព្វផ្សាយរបស់សមាគមសាលាត្រាជូ, ខែមករា ឆ្នាំ ២០១៨, http://salatraju.com/post/349 , ទំព័រ២, ០៧ កក្កដា ២០២១

[6] មើលមាត្រា ៨៤៣ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[7] មាត្រា ៨៦៧ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

## កថាភាគទី២. គោលការណ៍ទូទៅនៃហ៊ីប៉ូតែក

ផ្អែកតាមនិយមន័យទាំងអស់ខាងលើ ហ៊ីប៉ូតែក គឺជាផ្នែកមួយនៃសិទ្ធិប្រាតិភោគប្រត្យក្ស ដែលអនុញ្ញាតឲ្យកូនបំណុល (ហៅថា អ្នកបង្កើតសិទ្ធិហ៊ីប៉ូតែក) ប្រើប្រាស់សិទ្ធិលើអចលនវត្ថុ ទៅធានាការអនុវត្តកាតព្វកិច្ចរបស់ខ្លួន នៅចំពោះមុខម្ចាស់បំណុល (ម្ចាស់សិទ្ធិហ៊ីប៉ូតែក) និងចំពោះមុខច្បាប់។ អត្ថប្រយោជន៍មួយនៃការបង្កើតហ៊ីប៉ូតែកគឺ មិនតម្រូវឲ្យមានការផ្ទេរការកាន់កាប់លើអចលនទ្រព្យនោះទេ ដែលផ្តល់ប្រយោជន៍ដល់ភាគីកូនបំណុល ឬតតិយជន (អ្នកធានា) ជាម្ចាស់ទ្រព្យក្នុងការអាស្រ័យផលលើទ្រព្យរបស់ខ្លួន។[8]

កម្មវត្ថុនៅក្នុងការបង្កើតសិទ្ធិហ៊ីប៉ូតែកមានដូចជាៈ អចលនវត្ថុ, ផលុបភោគ, សិទ្ធិជួលអចិន្ត្រៃយ៍, និងទ្រព្យសម្បត្តិផ្សេងទៀតក្នុងករណីមានច្បាប់ពិសេស[9]។

សិទ្ធិលើអចលនវត្ថុនៅទីនេះ សំដៅទៅលើ៖

- កម្មសិទ្ធិ៖ សិទ្ធិដែលកម្មសិទ្ធិករអាចប្រើប្រាស់ អាស្រ័យផល និងចាត់ចែងលើអចលនវត្ថុរបស់ខ្លួនដែលទទួលបានពីភោគៈត្រឹមត្រូវតាមច្បាប់[10]។ កម្មសិទ្ធិលើអចលនទ្រព្យត្រូវទទួលស្គាល់ តាមរយៈ ការផ្តល់ជាវិញ្ញាបនបត្រសម្គាល់អចលនវត្ថុ ដោយរដ្ឋបាលសុរិយោដី។
- សិទ្ធិភោគៈ៖ សិទ្ធិដែលបុគ្គលណាម្នាក់បានកាន់កាប់អចលនទ្រព្យយ៉ាងផ្តាច់មុខតែឯង និងបំពេញចំពោះវត្ថុនោះនូវកិច្ចការទាំងឡាយដូចដែលកម្មសិទ្ធិករលើអចលនវត្ថុបានបំពេញ[11]។ សិទ្ធិភោគៈត្រូវបានរដ្ឋទទួលស្គាល់បន្ទាប់ពីមានការបើកឲ្យមានកម្មសិទ្ធិឯកជនលើដីធ្លីវិញ ក្រោយការធ្វើកំណែទម្រង់រដ្ឋឆ្នាំ១៩៨៩។ សិទ្ធិនេះត្រូវបានទទួលតាមរយៈការផ្តលជា បណ្ណ័សម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ ឬ បណ្ណ័សម្គាល់សិទ្ធិប្រើប្រាស់ដីធ្លី។ បុគ្គលដែលទទួលបានសិទ្ធិនេះ តែមិនទាន់ទទួលបានការចុះបញ្ជីទទយលស្គាល់ជាកម្មសិទ្ធិករពេញលេញ ក៏ត្រូវចាត់ទុកជាកម្មសិទ្ធិករ ហើយដែលអាចបង្កើតសិទ្ធិប្រាតិភោគប្រត្យក្សស្របតាមបញ្ញត្តិច្បាប់ជាធរមានបាន[12]។

ចំពោះអចលនវត្ថុ ដូចជាដីឡូតិ៍ ដីឡូតិ៍លំនៅដ្ឋាន ឬដីសំណង់ផ្សេងទៀតក្នុងបុរី ក៏អាចដាក់ហ៊ីប៉ូតែកបានដែរ។[13]

---

[8] ម៉ៅ សិលា, "ជំនួយស្មារតី៖ និយមន័យ និងការចុះបញ្ជីហ៊ីប៉ូតែកនៅកម្ពុជា",ការផ្សព្វផ្សាយរបស់សមាគមសាលាត្រាជូ, ខែមករា ឆ្នាំ ២០១៨, ទំព័រ២, ០៧ កក្កដា ២០២១,ដដែល

[9] មើលមាត្រា ៨៤៣ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[10] មាត្រា ៦ ច្បាប់ភូមិបាល ឆ្នាំ ២០០១

[11] មាត្រា ៦១ ច្បាប់ភូមិបាល ឆ្នាំ ១៩៩២

[12] មាត្រា ២៤២ ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧ និង មាត្រា ១៤ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ឆ្នាំ ២០១១

[13] មាត្រា ១៩ នៃអនុក្រឹត្យលេខ ៣៩.អនក្រ.បក ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១១ ស្តីពីការគ្រប់គ្រងបុរី

ម្យ៉ាងទៀតហេតុផលដែលអនុញ្ញាតឲ្យអ្នកប្រើប្រាស់សិទ្ធិជួលអចិន្ត្រៃយ៍ ឬសិទ្ធិផលុបភោគដែលជាសិទ្ធិមានលើដីរបស់អ្នកដទៃ មកធ្វើជាកម្មវត្ថុនៃសិទ្ធិហ៊ីប៉ូតែក គឺដោយសារតែបញ្ញត្តិក្នុងក្រមរដ្ឋប្បវេណីបានចែងថា ប្រសិនបើអ្នកមានសិទ្ធិជួលអចិន្ត្រៃយ៍ ឬ សិទ្ធិផលុបភោគបានសង់សំណង់នៅលើដី ឬដាំរុក្ខជាតិ ឬដំណាំជាអាទិ៍ ដែលជាការអនុវត្តសិទ្ធិលើដីអ្នកដទៃ វត្ថុទាំងនេះមិនត្រូវបានក្លាយជាសមាសភាគនៃដីទេ[14] ដែលមានន័យថា ចំពោះអ្នកមានសិទ្ធិជួលអចិន្ត្រៃយ៍ ឬសិទ្ធិផលុបភោគអាចប្រើប្រាស់អគារ ដែលជាអចលនវត្ថុបង្កើតហ៊ីប៉ូតែកបាន[15]។

ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ប្រសិនបើមានអត្ថបទច្បាប់ពិសេសទទួលស្គាល់នូវកម្មវត្ថុផ្សេងទៀត ក៏មានអានុភាពផងដែរ ដូចជាច្បាប់ពិសេសកំណត់ថា យន្តហោះ នាវា ឬវត្ថុផ្សេងទៀតដែលអាចចុះបញ្ជី គឺជាផ្នែកមួយនៃកម្មវត្ថុហ៊ីប៉ូតែក នោះប្រសិនបើមានច្បាប់ពិសេសបែបនេះមែន កម្មវត្ថុនៃហ៊ីប៉ូតែកនឹងពង្រីកវិសាលភាព[16]។

## ផ្នែកទី២. លក្ខខណ្ឌទូទៅនៃការបង្កើតហ៊ីប៉ូតែក

ដើម្បីបង្កើតសិទ្ធិហ៊ីប៉ូតែក ភាគីដែលមានបំណងក្នុងការបង្កើតសិទ្ធិនេះ ត្រូវគោរពតាមលក្ខខណ្ឌទូទៅក្នុងការបង្កើតកិច្ចសន្យាសិទ្ធិហ៊ីប៉ូតែកគឺ៖

- **លក្ខខណ្ឌគ្រឹះ និងលក្ខខណ្ឌទម្រង់ ៖**
    - ការព្រមព្រៀងគ្នាជាលាយលក្ខណ៍អក្សរ ដោយគ្មានវិការៈ ក្នុងការបង្ហាញឆន្ទៈ[17]
    - សមត្ថភាពក្នុងការបង្ហាញឆន្ទៈ
    - កម្មវត្ថុច្បាស់លាស់ និងស្របច្បាប់ (ជាអចលនវត្ថុរបស់កូនបំណុល ឬ អ្នកធានា)
- **លក្ខខណ្ឌតតាំង ៖** តម្រូវឲ្យធ្វើជា លិខិតយថាភូត និងចុះបញ្ជីនៅឯរដ្ឋបាលរដ្ឋបាលសុរិយោដី។ លិខិតយថាភូតក្នុងកិច្ចសន្យាហ៊ីប៉ូតែក គឺជាលិខិតដែលមន្ត្រីមានសមត្ថកិច្ចធ្វើឡើងដើម្បីប្រើប្រាស់ ក្នុងនីតិវិធីនៃការចុះបញ្ជី[18]។មន្ត្រីមានសមត្ថកិច្ចនៅទីនេះ គឺសំដៅទៅលើរដ្ឋបាលឃុំ-សង្កាត់នៃទីតាំង អចលនវត្ថុ[19] និងរដ្ឋបាលសុរិយោដី ដែលមានសមត្ថកិច្ចទទួលបន្ទុកចុះបញ្ជី។

[14] មាត្រា ១២៣ ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[15] ម៉ៅ សិលា, "ជំនួយស្មារតីៈ និយមន័យ និងការចុះបញ្ជីហ៊ីប៉ូតែកនៅកម្ពុជា",ការផ្សព្វផ្សាយរបស់សមាគមសាលាត្រាជូ, ខែមករា ឆ្នាំ ២០១៨, ទំព័រ២ ,០៧ កក្កដា ២០២១,ដដែល

[16] មេធាវីអ៊ុំ ប៉ូលី, «ហ៊ីប៉ូតែក និងកំជាប់ពាក្យ» ព្រឹត្តិបត្រមេធាវីលេខ១៣ មេសា-មិថុនាឆ្នាំ២០១៧ ទំព័រ៣២

[17] មាត្រា ៣៨៥ និង ៨៤៤ ក្រមរដ្ឋវេណី ឆ្នាំ ២០០៧

[18] មាត្រា ៩ ចំណុច ខ ប្រកាសស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ឆ្នាំ ២០១១

[19] ប្រកាសអន្តរក្រសួងរវាងក្រសួងដែនដី នគរូនីយកម្ម និងសំណង់ និងក្រសួងមហាផ្ទៃ លេខ១៥៩ប្រក/ដនស/មផ ចុះថ្ងៃទី១៥ ខែមិថុនាឆ្នាំ២០១៦ ស្តីពីការកែសម្រួលប្រការ៩ នៃប្រកាសអន្តរក្រសួងលេខ២១៥ប្រក/ដនស.មផ ចុះថ្ងៃទី០៩ខែកញ្ញាឆ្នាំ២០០៥ ស្តីពីតួនាទី និងការទទួលខុសត្រូវរបស់រដ្ឋបាលឃុំ-សង្កាត់ក្នុងការចុះបញ្ជីដី

ឯកសារក្នុងការបង្កើតសិទ្ធិហ៊ីប៉ូតែក ត្រូវរៀបចំ ដូចខាងក្រោម[20]៖

- កិច្ចសន្យាខ្ចីបរិភោគ (ជាកិច្ចសន្យាឯកជនរវាងកូនបំណុល ឬ ម្ចាស់បំណុល)
- កិច្ចសន្យាបង្កើតហ៊ីប៉ូតែក[21] ឬ កិច្ចសន្យាបង្កើតហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត
- ពាក្យសុំចុះបញ្ជីអំពីការបង្កើតសិទ្ធិហ៊ីប៉ូតែក[22] ឬពាក្យសុំចុះបញ្ជីអំពីការបង្កើតសិទ្ធិហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត
- ឯកសារបញ្ជាក់អត្តសញ្ញាណរបស់បុគ្គលដែលដាក់ពាក្យសុំចុះបញ្ជី
- ឯកសារបញ្ជាក់អត្តសញ្ញាណរបស់អចលនវត្ថុ៖ វិញ្ញាបនបត្រសម្គាល់អចលនវត្ថុ ឬ បណ្ណ័សម្គាល់សិទ្ធិកាន់កាប់ដី ឬបណ្ណ័សម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី។

**កថាភាគទី១. ការបង្កើតហ៊ីប៉ូតែក**

នីតិវិធីក្នុងការបង្កើតសិទ្ធិហ៊ីប៉ូតែក ទាំងហ៊ីប៉ូតែកធម្មតា និង ហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត មានលក្ខណៈនៃការអនុវត្តនីតិវិធីដូចគ្នា។

ការចុះបញ្ជីបង្កើតសិទ្ធិហ៊ីប៉ូតែក ត្រូវធ្វើឡើងជា៣ដំណាក់កាលគឺ៖

- **ដំណាក់កាលទី១៖** ពេលរៀបចំឯកសារកិច្ចសន្យាដូចខាងលើរួចរាល់ គូភាគីដែលបានព្រមព្រៀងរួចហើយត្រូវផ្តិតស្នាមម្រាមមេដៃនៅលើកិច្ចសន្យានេះឲ្យបានត្រឹមត្រូវ ដើម្បីបញ្ជាក់ពីការព្រមព្រៀងខ្លួន។ ករណីគូភាគីណាម្នាក់ជានីតិបុគ្គល គឺតម្រូវឲ្យមានហត្ថលេខារបស់អ្នកតំណាងនិងប្រថាប់ត្រារបស់នីតិបុគ្គលនោះផងដែរ។ ជាទូទៅមេធាវីអាចធ្វើការរៀបចំកិច្ចសន្យា ចុះហត្ថលេខានិងប្រថាប់ត្រា ក្នុងនាមជាសាក្សីរបស់គូភាគីផងដែរ តែមិនមែនមានន័យថា ការណ៍នេះធ្វើឲ្យកិច្ចសន្យាក្លាយជាលិខិតយថាភូតដែលមានលក្ខខណ្ឌតតាំងនោះទេ។ សម្រាប់ពាក្យសុំចុះបញ្ជីវិញ តម្រូវឲ្យចុះហត្ថលេខា ឬផ្តិតមេដៃរួមគ្នារវាង បុគ្គលដែលមានកាតព្វកិច្ចចុះបញ្ជី និង បុគ្គលដែលមានសិទ្ធិចុះបញ្ជីប៉ុណ្ណោះ។
- **ដំណាក់កាលទី២៖** បន្ទាប់ពីការរៀបចំកិច្ចសន្យា និងឯកសារភ្ជាប់បានគ្រប់ចំនួនកំណត់ហើយ គូភាគីនៃកិច្ចសន្យា ត្រូវស្នើសុំហត្ថលេខា និងត្រារបស់ចៅសង្កាត់-មេឃុំ ដែលជាមន្ត្រីមានសមត្ថកិច្ចដើម្បីឲ្យកិច្ចសន្យាក្លាយទៅជាលិខិតយថាភូត។ ចៅសង្កាត់-មេឃុំ នឹងពិនិត្យទៅលើភាពស្របច្បាប់របស់កម្មសិទ្ធិករ និងត្រួតពិនិត្យពីស្ថានភាពនសអចលនទ្រព្យនោះ ដោយពិនិត្យទៅលើប្រវត្តិដីធ្លីនោះ ដូចជាមាន

[20] ប្រកាសអន្តរក្រសួងរវាងក្រសួងដែនដី នគរូនីយកម្ម និងសំណង់ និងក្រសួងមហាផ្ទៃ លេខ៣០ កយ.ដនស.ប្រក/១៣ ចុះថ្ងៃទី១៣ ខែមករាឆ្នាំ២០១៣ ស្តីពីនីតិវិធីនៃការចុះបញ្ជីអំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី

[21] គំរូកិច្ចសន្យាហ៊ីប៉ូតែក មានក្នុងឧបសម្ពន្ធ័ទី២.ក

[22] ពាក្យសុំចុះបញ្ជីអំពីការបង្កើតសិទ្ធិហ៊ីប៉ូតែក មានក្នុងឧបសម្ពន្ធ័ទី២.ខ

ជាប់បន្ទុកបញ្ចាំ ឬហ៊ីប៉ូតែកពីមុនមក ឬក៏មានជាប់ក្នុងពាក្យបណ្តឹង ឬដីរក្សាការពារជាដើម។ បើគ្មានពាក់ពន្ធ័នឹងបញ្ហាណាមួយទេ ចៅសង្កាត់នឹងចុះហត្ថលេខា និងប្រថាប់ត្រារបស់សង្កាត់ ដោយមានចុះលេខបញ្ជាក់ ដើម្បីឲ្យកិច្ចសន្យានេះក្លាយទៅជាលិខិតយថាភូតពេញលេញតាមផ្លូវច្បាប់តែម្តង។ បច្ចុប្បន្ន សិទ្ធិអំណាច ក្នុងនាមជាមន្ត្រីមានសមត្ថកិច្ចនេះត្រូវបានផ្តល់ជូនទៅសារការី ដើម្បីចុះហត្ថលេខា និងប្រថាប់ត្រាលើកិច្ចសន្យារបស់គូភាគី។

- **ដំណាក់កាលទី៣៖** កិច្ចសន្យាដែលមានទម្រង់ជាលិខិតយថាភូតរួចហើយ គឺត្រូវយកទៅធ្វើការដាក់ពាក្យស្នើសុំចុះបញ្ជីនៅការិយាល័យច្រកចេញចូលតែមួយ ដែលមានទីតាំងស្ថិតនៅ រដ្ឋបាលសាលារាជធានី-ខេត្ត ដែលមានអចលនវត្ថុនោះតាំងនៅ។ក្នុងការដាក់ពាក្យស្នើរសុំនេះ ឯកសារត្រូវរៀបចំឲ្យបានគ្រប់ចំនួន និងត្រឹមត្រូវតាមបទដ្ឋានគតិយុត្ត។ មន្ត្រីរដ្ឋបាលការិយាល័យច្រកចេញចូលតែមួយ រាជធានី-ខេត្ត និងធ្វើការពិនិត្យឯកសារ បន្ទាប់ពីពិនិត្យឯកសារត្រឹមត្រូវហើយ គូភាគីត្រូវបង់ប្រាក់សេវាក្នុងការចុះបញ្ជីដែលមានតម្លៃកំណត់តាមទីតាំងដែលអចលនវត្ថុតាំងនៅ[23] មន្ត្រីរដ្ឋបាលនឹងចេញបង្កាន់ដៃបង់ប្រាក់ព្រមទាំងបង្កាន់ដៃទទួលពាក្យ ជូនម្ចាស់អចលនវត្ថុ អំពីកាលបរិច្ឆេទមកទទួលឯកសារ នៅពេលរួចរាល់។ បន្ទាប់ពី ចុះលេខ និងប្រថាប់ត្រាចូលច្រក រួចរាល់ មន្ត្រីច្រកចេញចូលតែមួយ រាជធានី-ខេត្តនឹងបញ្ជូនឯកសារនោះ មកកាន់រដ្ឋបាលសុរិយោដី។ មន្ត្រីទទួលបន្ទុកនឹងធ្វើការផ្ទៀងផ្ទាត់ឯកសារ ហើយធ្វើការចុះបញ្ជីចូលទៅក្នុងសៀវភៅគោលបញ្ជីដីធ្លី ត្រង់ខ្ទង់ «បន្ទុកលើអចលនទ្រព្យ» និងបោះត្រាលេខាចារឹកនៅខាងក្រោយ វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ឬបណ្ណ័សម្គាល់សិទ្ធិកាន់កាប់ដីធ្លី ដោយបញ្ជាក់ពី គូភាគីឲ្យបានច្បាស់ ប្រាក់ដើម ការប្រាក់(គិតជា%) សំណងកាតខូចខាត (គិតជា%) លក្ខខណ្ឌភ្ជាប់សិទ្ធិលើបំណុលដែលត្រូវបានធានាតាមកិច្ចសន្យា និងកាលបរិច្ឆេទនសកិច្ចសន្យាជាទឹកខៀវ ឬទឹកខ្មៅ ហើយបោះត្រាលេខាចារឹក និងចុះកាលបរិច្ឆេទនៃការចុះបញ្ជីជាទឹកក្រហម[24]។ មន្ត្រីដែលទទួលបន្ទុកលើកិច្ចការចុះបញ្ជី ត្រូវប្រគល់បណ្ណ័កម្មសិទ្ធិដែលចុះលេខាចារឹកហើយនេះទៅកាន់ ម្ចាស់អចលនវត្ថុវិញ បន្ទាន់ពីចុះបញ្ជីរួចរាល់[25]។

[23] អនុក្រឹត្យលេខ១៨ អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតយន្តការច្រកចេញចូលតែមួយសម្រាប់ការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ និង សេចក្តីប្រកាសរបស់ក្រសួងដែនដី នគរូនីយកម្ម និងសំណង់ លេខ១៨៩៧ដនស/អរប ចុះថ្ងៃទី០៧ សីហា ២០១៨

[24] ប្រការ ១១៦ នៃប្រកាសអន្តរក្រសួងស្តីពីការចុះបញ្ជីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី

[25] ម៉ៅ សិលា, "ជំនួយស្មារតី៖ និយមន័យ និងការចុះបញ្ជីហ៊ីប៉ូតែកនៅកម្ពុជា",ការផ្សព្វផ្សាយរបស់សមាគមសាលាត្រាជូ, ខែមករា ឆ្នាំ២០១៨, ទំព័រ៤,៥,៦ ,០៧ កក្កដា ២០២១,ដដែល

## កថាភាគទី២. អានុភាពនៃហ៊ីប៉ូតែក

នៅពេលហ៊ីប៉ូតែកមានអានុភាព នាំឲ្យទឹកប្រាក់ដែលម្ចាស់បំណុលហ៊ីប៉ូតែកអាចទទួលការសងដោយមានអាទិភាពពីប្រាក់ដែលបានពីការលក់ ក្នុងករណីដែលកូនបំណុលមិនបានសងបំណុល ហើយហ៊ីប៉ូតែកនឹងត្រូវបានអនុវត្ត តាមនីតិវិធីលក់បង្ខំ ដោយរាប់បញ្ចូលទាំងករណីម្ចាស់បំណុលហ៊ីប៉ូតែកចូលរួមក្នុងការចែកចំណែក តាមនីតិវិធីលក់ដោយបង្ខំដែលត្រូវបានចាប់ផ្ដើម តាមរយៈពាក្យសុំរបស់តតិយជន ប៉ុន្តែអ្នកបង្កើតហ៊ីប៉ូតែក(កូនបំណុល) មានសិទ្ធិប្រើប្រាស់ និង អាស្រ័យផល ពីអចលនវត្ថុដែលជាកម្មវត្ថុនៃហ៊ីប៉ូតែក ហេតុនេះអ្នកបង្កើតហ៊ីប៉ូតែក អាចសាងសង់អគារឬ ដាំដំណាំជាអាទិ៍ ដោយសេរីនៅក្នុងទំហំនៃសិទ្ធិប្រើប្រាស់ និងអាស្រ័យផលរបស់ខ្លួន។ នៅក្នុងករណីនេះ ហ៊ីប៉ូតែកក៏មានអានុភាពលើអគារដែលភ្ជាប់ទៅនឹងដី និងដើមឈើដែលបានដាំលើដី ជាអាទិ៍[26] ក្រោយពេលបង្កើតហ៊ីប៉ូតែក ហើយដោយសារតែអ្នកបង្កើតហ៊ីប៉ូតែកមានសិទ្ធិប្រើប្រាស់ និងអាស្រ័យផលពីវត្ថុដែលជាកម្មវត្ថុ ហេតុនេះ អ្នកបង្កើតហ៊ីប៉ូតែក អាចរុះរើសំណង់អគារដែលភ្ជាប់នឹងដី ឬដើមឈើដែលបានដាលើដីជាអាទិ៍ ហើយប្រមូលផលដំណាំបាន ដោយផ្អែកលើសិទ្ធិរបស់ខ្លួន។

មួយវិញទៀត ក្រមរដ្ឋប្បវេណីជប៉ុនចាត់ទុកដី និងអគារជាអចលនវត្ថុផ្សេងគ្នា និងឯករាជ្យពីគ្នា ហេតុនេះ ហ៊ីប៉ូតែកដែលបានបង្កើតលើដីមិនមានអានុភាពលើអគារនោះទេ ហើយហ៊ីប៉ូតែកដែលបានបង្កើតលើអគារក៏មិន មានអានុភាពលើដីផងដែរ និងអនុញ្ញាតឲ្យគូភាគីអាចកំណត់អានុភាពនៃហ៊ីប៉ូតែកតាមការព្រមព្រៀងបាន។ ប៉ុន្តែសម្រាប់ក្រមរដ្ឋប្បវេណីនៃកម្ពុជា មិនទទួលស្គាល់ការព្រមព្រៀងបែបនេះ នោះទេ ហើយក្នុងករណីដែលតតិយជនមាន កម្មសិទ្ធិលើអគារ និងលើដីដែលបានដាក់ហ៊ីប៉ូតែក ដោយផ្អែកលើសិទ្ធិជួលអចិន្ត្រៃយ៍ ផលុបភោគឬ សិទ្ធិជួលដែលនាំ ឲ្យហ៊ីប៉ូតែកនេះ ពុំមានអានុភាពលើអគារឡើយ[27] ដោយរាប់បញ្ចូលទាំងផលកើតចេញពីវត្ថុ ដែលជាកម្មវត្ថុនៃហ៊ីប៉ូតែក ដោយហេតុថា អ្នកបង្កើតហ៊ីប៉ូតែកបន្តមានសិទ្ធិប្រើប្រាស់ និងអាស្រ័យផលពីដី ក្រោយការបង្កើតហ៊ីប៉ូតែកលើកលែង តែវត្ថុដែលជាកម្មវត្ថុនៃហ៊ីប៉ូតែកត្រូវបានលក់ដោយការអនុវត្តហ៊ីប៉ូតែក អ្នកទិញនឹងធ្វើលទ្ធកម្មនូវកម្មសិទ្ធិពេញលេញ ហើយអ្នកបង្កើតហ៊ីប៉ូតែកនឹងបាត់បង់កម្មសិទ្ធិលើវត្ថុដែលជាកម្មវត្ថុ ហេតុនេះអ្នកបង្កើតហ៊ីប៉ូតែកត្រូវបាត់បង់សិទ្ធិប្រើ ប្រាស់ និងអាស្រ័យផលដោយស្វ័យប្រវត្តិ មានន័យថា សិទ្ធិប្រើប្រាស់ និងអាស្រ័យផលរបស់អ្នកបង្កើតហ៊ីប៉ូតែកត្រូវ បានកម្រិត គឺជាស្ថានភាពដែលអចលនវត្ថុត្រូវបានរឹបអូស ដែលជាហេតុនាំឲ្យហ៊ីប៉ូតែកនឹងមានអានុភាពលើផល ដែលបានមកពីអចលនវត្ថុដែលបានដាក់ហ៊ីប៉ូតែក ក្រោយពេលដែលអចលនវត្ថុនោះត្រូវបានរឹបអូស[28]។

[26] មើលមាត្រា ៨៤៦ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[27] មើលមាត្រា ៨៤៧ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[28] មើលមាត្រា ៨៤៨ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

លើសពីនេះទៅទៀត ហ៊ីប៉ូតែកត្រូវបានបង្កើតឡើងសម្រាប់ម្ចាស់សិទ្ធិ ក្នុងគោលដៅធានាសិទ្ធិលើបំណុល ដែលមានដូចជា ប្រាក់ដើម ការប្រាក់ ធនលាភ និង សំណងនៃការខូចខាត ជាអាទិ៍ ដែលសិទ្ធិនេះត្រូវបានកម្រិត សម្រាប់អំឡុងពេលពីរឆ្នាំចុងក្រោយប៉ុណ្ណោះ និងប្រសិនបើមានហ៊ីប៉ូតែកច្រើនបង្កើតលើអចលនវត្ថុតែមួយ លំដាប់អាទិភាពនៃហ៊ីប៉ូតែក ត្រូវអានុលោមទៅតាមពេលវេលានៃការចុះបញ្ជី[29]។ ដោយឡែកសម្រាប់ ធនលាភដែលមានពីមុនមក ប្រសិនបើបានចុះបញ្ជីពិសេស ក្រោយពីបានដល់កំនត់ពេលត្រូវសង ហ៊ីប៉ូតែកនេះអាចអនុវត្តបានចាប់ពីពេលដែលបានចុះបញ្ជីដោយរាប់បញ្ចូលទាំងប្រាក់ដែលត្រូវបង់ សម្រាប់អំឡុងពេលពីរឆ្នាំចុងក្រោយ ក្នុងករណីដែលម្ចាស់សិទ្ធិហ៊ីប៉ូតែក មានសិទ្ធិទាមទារឲ្យសងសំណងនៃការខូចខាត ដែលបានកើតឡើងដោយសារ ការមិនអនុវត្តកាតព្វកិច្ច ប៉ុន្តែចំនួនសរុបសម្រាប់សំណងនៃការខូចខាត ការប្រាក់និង ធនលាភផ្សេងៗមិនអាចលើសចំនួនសរុបសម្រាប់អំឡុងពេលពីរឆ្នាំ បានឡើយ[30]។ ដោយឡែកហ៊ីប៉ូតែកមានអានុភាពលើទឹកប្រាក់ដែលអ្នកបង្កើតហ៊ីប៉ូតែក (អ្នកលក់) ត្រូវទទួលក្នុងករណីវត្ថុដែលជាកម្មវត្ថុនៃហ៊ីប៉ូតែកត្រូវបានលក់ទៅតតិយជន និងសំណងនៃការ ខូចខាតដែលអ្នកបង្កើតហ៊ីប៉ូតែកត្រូវទទួលបានដោយការបាត់បង់ ឬការខូចខាតនូវវត្ថុដែលជាកម្មវត្ថុនៃហ៊ីប៉ូតែក ហើយម្ចាស់សិទ្ធិហ៊ីប៉ូតែកអាចអនុវត្តហ៊ីប៉ូតែក ចំពោះទឹកប្រាក់ទាំងនេះបាន ដែលជាស្ថានភាពបង្កើតឲ្យមានអានុភាពនៃហ៊ីប៉ូតែកទៅលើទឹកប្រាក់ទាំងនោះដោយឧបាទេសកម្ម ដោយហេតុថាប្រាក់ទាំងនោះអាចចាត់ទុកជាប្រាក់ដែលបានមកពីការផ្លាស់ប្តូរនៃកម្មវត្ថុនៃហ៊ីប៉ូតែក ហើយសម្រាប់ ឧបាទេសកម្មត្រូវរាប់បញ្ចូលទាំងផលដែលកើតឡើងពីវត្ថុដែលជាកម្មវត្ថុនៃហ៊ីប៉ូតែក ក្រោយការរឹបអូសវត្ថុ[31]ដែល ជាកម្មវត្ថុនៃហ៊ីប៉ូតែកនោះដោយនីតិវិធី នៃការអនុវត្តហ៊ីប៉ូតែក ត្រូវអនុលោមតាមមាត្រា៥០៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី[32] និង មានបកស្រាយក្នុងជំពូកទី២ បន្តទៅនេះ ផ្នែកទី៣ និយាយអំពី នីតិវិធីនៃការអនុវត្តហ៊ីប៉ូតែក ។

[29] មើលមាត្រា ៨៥១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[30] មើលមាត្រា ៨៥២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[31] មើលមាត្រា ៨៤៩ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[32] មេធាវី អ៊ីវ ប៉ូលី, សិទ្ធិប្រាតិភោគប្រត្យក្ស ដោយគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា,មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ ,ទំព័រ២៨-២៩

# ជំពូកទី២

# ការអនុវត្ត និងការចាត់ចែង

# នៃហ៊ីប៉ូតែក

# ជំពូកទី២

# ការអនុវត្ត និងការចាត់ចែងនៃហ៊ីប៉ូតែក

## ផ្នែកទី១. ការអនុវត្ត និងការចាត់ចែងនៃហ៊ីប៉ូតែកធម្មតា

ការអនុវត្ត និងការចាត់ចែងនៃហ៊ីប៉ូតែកធម្មតា ត្រូវបានចងក្រង និងចែងអោយអនុវត្តគោរពតាមក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដែលមានពាក់ព័ន្ធមាត្រាមួយចំនួន ចាប់ពីមាត្រា ៨៥៣ ដល់មាត្រា ៨៧១។ ក្រៅពីក្រមរដ្ឋប្បវេណី ក៏នៅមានច្បាប់ដទៃចែងផងដែរ ដូចជា ច្បាប់ភូមិបាល ក្រមនីតិវិធីព្រហ្មទណ្ឌ ក្រឹត្យច្បាប់លេខ ៣៨ ក្រមរដ្ឋប្បវេណីចាស់ឆ្នាំ១៩២០ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗទៀត។

### កថាភាគទី១. ការអនុវត្តហ៊ីប៉ូតែកធម្មតា

ការអនុវត្តហ៊ីប៉ូតែកធម្មតា នឹងត្រូវបានចាប់ផ្តើមក្នុងករណីដែលម្ចាស់បំណុលមិនបានទទួលសំណងនូវសិទ្ធិលើបំណុលរបស់ខ្លួន។ យោងតាមមាត្រា ៨៥៣ បានចែងកំណត់ថា ម្ចាស់បំណុលអាចអនុវត្តហ៊ីប៉ូតែកបានក្នុងករណីដែលកាតព្វកិច្ចដែលត្រូវបានធានាពុំបានសង នោះម្ចាស់បំណុលហ៊ីប៉ូតែកអាចដាក់ពាក្យសុំអោយលក់ដោយបង្ខំនូវអចលនវត្ថុហ៊ីប៉ូតែកទៅតុលាការបាន។[33] ត្រង់ចំណុចនេះ ក្រមរដ្ឋប្បវេណីចាស់ មាត្រា ១៣២៣ ក៏បានចែងក្នុងអត្ថន័យដូចគ្នាដែរ គឺហ៊ីប៉ុតែក នឹងត្រូវបានអនុវត្តនៅវេលាដែលដល់កំណត់សង ហើយម្ចាស់បំណុលអាចប្តឹង សុំអោយលក់អចលនវត្ថុនោះ ទោះនៅលើដៃនរណាក្តី ក្នុងគោលបំណងយកប្រាក់សងដោយសារពួកគេជាអ្នកមានឯកសិទ្ធិ និង បុរិមាជាងម្ចាស់បំណុលឯទៀតដោយគ្មានដកអចលនវត្ថុនេះពីកម្មសិទ្ធិករឡើយ។[34] ដូចនេះ យើងអាចមើលឃើញថា ម្ចាស់បំណុលមានឯកសិទ្ធិ ក្នុងការដាក់ពាក្យសុំអោយលក់ដោយបង្ខំនូវអចលនវត្ថុហ៊ីប៉ូតែកទៅតុលាការបាន ពោលគឺនៅពេលដែលពួកគេមិនបានទទួលសំណងនូវសិទ្ធិលើបំណុលដែលបានបង្កើតឡើងពីអ្នកបង្កើតហ៊ីប៉ូតែក។

ចំពោះកូនបំណុល មិនអាចក្លាយជាអ្នកទិញនៅក្នុងការលក់ដោយបង្ខំនោះទេ តែម្ចាស់បំណុលហ៊ីប៉ូតែក និងតតិយជនដែលបានធ្វើលទ្ធកម្ម អាចក្លាយជាអ្នកទិញបាន ផ្អែកលើមាត្រា ៨៥៥។ ក្នុងករណីដែលតតិយជនបានធ្វើលទ្ធកម្ម បានចេញចំណាយជាចាំបាច់សម្រាប់ការគ្រប់គ្រង និងថែរក្សាវត្ថុ ឬចំណាយបង្កើនតម្លៃចំពោះអចលនវត្ថុហ៊ីប៉ូតែក តតិយជននោះនឹងទទួលបានសំណងនូវចំណាយនោះពីថ្លៃលក់ដោយបង្ខំ ដោយមានអាទិ-ភាពជាងម្ចាស់បំណុលហ៊ីប៉ូតែក។[35] ក្រៅពីនេះ ក្នុងករណីដែលម្ចាស់បំណុលហ៊ីប៉ូតែកដែលមានលំដាប់ទាប

---

[33] មើលមាត្រា ៨៥៣ ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[34] មាត្រា ១៣២៣ ក្រមរដ្ឋប្បវេណីចាស់ ឆ្នាំ ១៩២០

[35] មើលមាត្រា ៨៥៦ ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

ដាក់ពាក្យសុំលក់ដោយបង្ខំ ហ៊ីប៉ូតែកដែលមានលំដាប់ខ្ពស់ជាងមិនត្រូវរលត់ដោយសារការលក់បង្ខំនោះទេ។[36] ដូចនេះ យើងអាចសរុបមកថា ការដាក់ពាក្យសុំលក់ដោយបង្ខំ អាចអនុវត្តបានតែចំពោះម្ចាស់បំណុលហ៊ីប៉ូតែក និង តតិយជនដែលបានធ្វើលទ្ធកម្មលើអចលនវត្ថុប៉ុណ្ណោះ ហើយវានឹងមានអានុភាពទៅលើអ្នកដែលបានដាក់ពាក្យសុំប៉ុណ្ណោះ ហេតុដូចនេះហើយទើបម្ចាស់ហ៊ីប៉ូតែកដែលមានលំដាប់ខ្ពស់ជាងមិនត្រូវបានរលត់ដោយសារការលក់បង្ខំនោះទេ ទោះបីម្ចាស់បំណុលហ៊ីប៉ូតែកដែលមានលំដាប់ទាបជាងបានដាក់ពាក្យសុំលក់ដោយបង្ខំក៏ដោយ។

ការអនុវត្តហ៊ីប៉ូតែកដោយក្នុងនោះមានអគារជាកម្មសិទ្ធិរបស់តតិយជន ត្រូវបែងចែកជាពីរករណី យោងតាមមាត្រា ៨៥៤ (កថា.២)[37]៖

- សិទ្ធិជួលអចិន្ត្រៃយ៍ ផលុបភោគ ឬ សិទ្ធិជួលរបស់តតិយជន អាចតតាំងជាមួយម្ចាស់បំណុលហ៊ីប៉ូតែកបាន គឺពិនិត្យលើពេលវេលានៃការចុះបញ្ជីហ៊ីប៉ូតែក នោះម្ចាស់បំណុលហ៊ីប៉ូតែកអាចសុំអោយលក់ដោយបង្ខំបានតែដីប៉ុណ្ណោះ មិនអាចសុំអោយលក់ទាំងអគារបានទេ

- សិទ្ធិជួលអចិន្ត្រៃយ៍ ផលុបភោគ ឬ សិទ្ធិជួលរបស់តតិយជន មិនអាចតតាំងជាមួយនឹងម្ចាស់បំណុលហ៊ីប៉ូតែកបាន គឺពិនិត្យលើពេលវេលានៃការចុះបញ្ជីហ៊ីប៉ូតែក នោះម្ចាស់បំណុលហ៊ីប៉ូតែកអាចសុំអោយលក់ដោយបង្ខំបានទាំងដី និងអគារ។

ចំពោះករណីទាំងពីរនេះ យើងអាចសង្កេតឃើញថាការអនុវត្តហ៊ីប៉ូតែកដោយក្នុងនោះមានអគារជាកម្មសិទ្ធិរបស់តតិយជន គឺទាក់ទងនឹងការពិនិត្យមើលលើពេលវេលានៃការចុះបញ្ជីហ៊ីប៉ូតែកលើអចលនវត្ថុនោះ ប្រសិនបើអគារនោះត្រូវបានសាងសង់ក្រោយពេលហ៊ីប៉ូតែកត្រូវបានបង្កើត នោះម្ចាស់បំណុលហ៊ីបូតែកអាចលក់ដោយបង្ខំទាំងដី និងអគារនោះបាន ហើយបើតតិយជន អាចបញ្ជាក់ពីសិទ្ធិជួលអចិន្ត្រៃយ៍ ផលុបភោគ ឬ សិទ្ធិជួលរបស់ខ្លួនដោយតតាំងជាមួយម្ចាស់បំណុលនេះបាន នោះម្ចាស់បំណុលហ៊ីប៉ូតែកអាចសុំលក់ដោយបង្ខំបានតែដីហ៊ីប៉ូតែកប៉ុណ្ណោះ។

**ក.ហ៊ីប៉ូតែករួម**

ហ៊ីប៉ូតែករួម គឺជាហ៊ីប៉ូតែកលើអចលនវត្ថុច្រើន ដើម្បីធានាសិទ្ធិលើបំណុលតែមួយ។ ហ៊ីប៉ូតែករួមត្រូវបានអនុវត្តតាមករណីដូចតទៅ៖

[36] មើលមាត្រា ៥១០ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[37] មាត្រា ៨៥៤ កថាខណ្ឌទី ២ ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

- ករណីនៃការចែកចំណែកព្រមគ្នាៈ មានន័យថា បន្ទុកនៃសិទ្ធិលើបំណុលត្រូវចែកទៅតាមសមាមាត្រនៃតម្លៃនៃអចលនវត្ថុនីមួយៗ

- ករណីនៃការចែកចំណែកមិនព្រមគ្នាៈ ម្ចាស់បំណុលហ៊ីប៉ូតែកអាចទទួលការសង ចំពោះសិទ្ធិលើបំណុលទាំងអស់ ដោយប្រាក់ដែលបានមកពីការលក់ដោយបង្ខំ។ ករណីនេះ ម្ចាស់បំណុលដែលមានលំដាប់បន្ទាប់ អាចអនុវត្តហ៊ីប៉ូតែករបស់ម្ចាស់បំណុលដែលមានលំដាប់នៅខាងលើ ដោយឧបាទោសកម្ម រហូតដល់ចំនួនទឹកប្រាក់ដែលម្ចាស់បំណុលលំដាប់ខាងលើនោះ ត្រូវទទួលការសងចំពោះអចលនវត្ថុផ្សេងទៀត។[38]

ច្បាប់ភូមិបាល ក៏បានចែងទាក់ទងនឹងចំណុចនេះផងដែរ គឺមាត្រា ២០៤។ មាត្រានេះ បានបញ្ជាក់ថា ប្រសិនបើកម្មសិទ្ធិករនៃទ្រព្យដាក់ហ៊ីប៉ូតែកមិនសងបំណុលនៅពេលដល់កំណត់ត្រូវសង ម្ចាស់បំណុលម្នាក់អាចប្តឹងសុំអោយដាក់លក់ទ្រព្យនោះបាន ដោយមិនគិតពីលំដាប់នៃហ៊ីប៉ូតែករបស់គេឡើយ ហើយម្ចាស់បំណុលហ៊ីប៉ូតែកនានានឹងត្រូវទទួលបានសំណងនៅពេលនេះដែរ តាមលំដាប់នៃហ៊ីប៉ូតែកនីមួយៗ។[39]

ដូចនេះយើងមើលឃើញថា ការអនុវត្តហ៊ីប៉ូតែករួម គឺត្រូវធ្វើតាមករណី២យ៉ាងដូចខាងលើៈ ការចែកចំណែកព្រមគ្នា និង ការចែកចំណែកមិនព្រមគ្នា។ ហើយតាមរយៈករណីទាំងពីរនេះ ក៏បានបង្ហាញអោយឃើញថា សិទ្ធីលើបំណុលមានទំហំខុសគ្នាផងដែរ ដោយករណីទីមួយ ត្រូវចែកតាមសមមាត្រនៃតម្លៃរបស់អចលនវត្ថុនីមួយៗ និងករណីទីពីរ ដោយការអនុវត្តការលក់ដោយបង្ខំដោយម្ចាស់បំណុលហ៊ីប៉ូតែកម្នាក់ ហើយការទទួលបានការសងចំពោះអចលនវត្ថុហ៊ីប៉ូតែកនោះ នឹងត្រូវអនុវត្តដោយការផ្តល់នូវឋានៈមួយដែលបុគ្គលម្នាក់នឹងទទួលជំនួសបុគ្គលណាមួយតាមផ្លូវច្បាប់។

### កថាភាគទី២. ការចាត់ចែងហ៊ីប៉ូតែកធម្មតា

ការចាត់ចែងហ៊ីប៉ូតែកធម្មតា នឹងមានអានុភាពនៅពេលដែលបានធ្វើតាមល័ក្ខខ័ណ្ឌស្របតាមមាត្រា ៨៦២ គឺត្រូវមានការព្រមព្រៀងតាមលិខិតយថាភូត និងចុះបញ្ជីបន្ថែម។[40] ការកំណត់បែបនេះ គឺដោយសារករណីនៅពេលមានការតតាំង ដែលវាជាប្រយោជន៍ដល់ភាគីទាំងអស់។ លុះត្រាតែម្ចាស់បំណុលហ៊ីប៉ូតែកបានជូនដំណឹងទៅកូនបំណុលដែលមានកាតព្វកិច្ចចម្បង ឬបានទទួលការយល់ព្រមពីកូនបំណុលដែលមាន

[38] មើលមាត្រា ៨៥៧ ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[39] មាត្រា ២០៤ ច្បាប់ភូមិបាល ឆ្នាំ ២០០១

[40] មើលមាត្រា ៨៦២ ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

កាតព្វកិច្ចចម្បង អ្នកធានា អ្នកបង្កើតហ៊ីប៉ូតែក និង ប្រតិសិទ្ធិរបស់ជនទាំងនោះ ទើបការចាត់ចែងហ៊ីប៉ូតែកអាចមានការតតាំងទៅកូនបំណុលនោះបាន។

ប្រភេទនៃការចាត់ចែងហ៊ីប៉ូតែកធម្មតាមានបី គឺហ៊ីប៉ូតែកបន្ត (មាត្រា ៨៥៩) អនុប្បទាន ឬការបោះបង់ចោលនូវហ៊ីប៉ូតែក (មាត្រា ៨៦០) និង អនុប្បទាន ឬការបោះបង់ និងការផ្លាស់ប្តូរនូវលំដាប់នៃហ៊ីប៉ូតែក (មាត្រា ៨៦១)។

**ក.ហ៊ីប៉ូតែកបន្ត**

យោងតាមមាត្រា ៨៥៩ បានកំណត់ថា ហ៊ីប៉ូតែកបន្ត គឺជាការដែលម្ចាស់បំណុលហ៊ីប៉ូតែកអាចយកហ៊ីប៉ូតែករបស់ខ្លួន ធ្វើជាប្រាតិភោគសម្រាប់កាតព្វកិច្ច ពោលគឺធានាកាតព្វកិច្ចរបស់ខ្លួន ឬតតិតយជន។[41]

ចំពោះហ៊ីប៉ូតែកបន្ត ម្ចាស់បំណុលហ៊ីប៉ូតែកបន្តអាចទទួលការសងចំពោះសិទ្ធិលើបំណុលទាំងអស់បានត្រឹមកម្រិតនៃចំនួនទឹកប្រាក់ដែលត្រូវចែកអោយម្ចាស់បំណុលហ៊ីប៉ូតែក ក្នុងករណីពេលដែលចែកចំណែកនូវប្រាក់ដែលបានមកពីការលក់ដោយបង្ខំនូវអចលនវត្ថុហ៊ីប៉ូតែក។ តែប្រសិនបើសិទ្ធិលើបំណុលនោះមិនទាន់ដល់ពេលកំណត់ត្រូវសងទេ ម្ចាស់បំណុលហ៊ីប៉ូតែកបន្ត អាចទាមទារត្រឹមតែ ការតម្កល់ចំនួនទឹកប្រាក់ដែលខ្លួនអាចទទួលការសងប៉ុណ្ណោះ។

លើសពីនេះ ហ៊ីប៉ូតែកបន្តក៏អាចកើតមានច្រើនបន្តបន្ទាប់គ្នាលើអចលនវត្ថុហ៊ីប៉ូតែកតែមួយបានដែរ ដែលនាំអោយ ម្ចាស់បំណុលហ៊ីប៉ូតែកទាំងអស់ប្រើសិទ្ធិលើបំណុលតាមលំដាប់ជាអាទិភាពនៃការចុះលេខាចារិកហ៊ីប៉ូតែករបស់ខ្លួន។[42]

ដូចនេះ យើងអាចសរុបមកថា ហ៊ីប៉ូតែកបន្ត គឺអាចកើតឡើងដោយការដែលម្ចាស់បំណុលហ៊ីប៉ូតែកយកអចលនវត្ថុហ៊ីប៉ូតែកទៅដាក់ធ្វើជាហ៊ីប៉ូតែកបន្ត ពោលគឺដាក់ធានាកាតព្វកិច្ចរបស់ខ្លួន ឬ តតិយជន ដែលវាអាចកើតមានច្រើនបន្តបន្ទាប់គ្នា។

**ខ.អនុប្បទាន ឬការបោះបង់ហ៊ីប៉ូតែក**

ល័ក្ខខ័ណ្ឌនៃអនុប្បទាន ឬការបោះបង់ហ៊ីប៉ូតែក ត្រូវធ្វើឡើងរវាងម្ចាស់បំណុលហ៊ីប៉ូតែក និងម្ចាស់បំណុលធម្មតា ចំពោះកូនបំណុលតែម្នាក់។[43] ករណីអនុប្បទានហ៊ីប៉ូតែក គឺអនុប្បទានិកនៃហ៊ីប៉ូតែកអាចអនុវត្តហ៊ីប៉ូតែកដែលបានទទួលនោះ ដោយយកធ្វើជាប្រាតិភោគនៃសិទ្ធិលើបំណុលរបស់ខ្លួន។

[41] មើលមាត្រា ៨៥៩ ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[42] មាត្រា ២០៣ ច្បាប់ភូមិបាល ឆ្នាំ ២០០១

[43] មើលមាត្រា ៨៦០ ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

ករណីការបោះបង់ហ៊ីប៉ូតែក គឺបុគ្គលណាដែលបានបោះបង់ហ៊ីប៉ូតែកមិនអាចអះអាងអានុភាពនៃហ៊ីប៉ូតែកនោះចំពោះបុគ្គលដែលបានទទួលនូវការបោះបង់នោះឡើយ។

### គ.អនុប្បទាន ឬការបោះបង់ និង ការផ្លាស់ប្តូរនូវលំដាប់នៃហ៊ីប៉ូតែក

ល័ក្ខខ័ណ្ឌនៃអនុប្បទាន ឬការបោះបង់ និងការផ្លាស់ប្តូរនូវលំដាប់នៃហ៊ីប៉ូតែក ត្រូវធ្វើឡើងរវាងម្ចាស់បំណុលហ៊ីប៉ូតែក ចំពោះកូនបំណុលតែម្នាក់។[44]

ករណីអនុប្បទានលំដាប់ហ៊ីប៉ូតែក គឺម្ចាស់បំណុលហ៊ីប៉ូតែកអាចទទួលអនុប្បទាននូវលំដាប់ហ៊ីប៉ូតែក។

ចំណុចនេះមានន័យថា ម្ចាស់បំណុលហ៊ីប៉ូតែកអាចទទួលបានការសងដោយមានអាទិភាពជាងម្ចាស់បំណុលហ៊ីប៉ូតែកដែលបានធ្វើអនុប្បទាននូវលំដាប់ហ៊ីប៉ូតែកនូវចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលទាំងអស់ ពីប្រាក់ដែលបានមកពីការលក់ដោយបង្ខំនូវអចលនវត្ថុនោះ ត្រឹមកម្រិតនៃចំនួនទឹកប្រាក់សរុបនៃចំណែកដែលត្រូវចែងអោយទៅម្ចាស់បំណុលហ៊ីប៉ូតែកទាំងពីរនោះ។

ចំពោះការបោះបង់លំដាប់ហ៊ីប៉ូតែកវិញ គឺម្ចាស់បំណុលហ៊ីប៉ូតែកដែលទទួលការបោះបង់លំដាប់នៃហ៊ីប៉ូតែកអាចទទួលការសងដោយមានសមភាពជាមួយម្ចាស់បំណុលដែលបានលះបង់លំដាប់ហ៊ីប៉ូតែកនោះ តាមសមាមាត្រនៃចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុល នៅក្នុងទំហំនៃចំនួនទឹកប្រាក់សរុបនៃចំណែកដែលត្រូវចែកអោយទៅម្ចាស់បំណុលហ៊ីប៉ូតែកទាំងពីរនោះ។

រីឯការផ្លាស់ប្តូរលំដាប់ហ៊ីប៉ូតែកវិញ គឺដើម្បីអោយមានអានុភាព ត្រូវមានការយល់ព្រមពីបុគ្គលដែលមានទំនាក់ទំនងនឹងផលប្រយោជន៍ចំពោះការផ្លាស់ប្តូរនោះ។

## ផ្នែកទី២. ការអនុវត្ត និង ការចាត់ចែងហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត

មុននឹងឈានដល់ការបកស្រាយអំពីការអនុវត្ត និង ការចាត់ចែងហ៊ីប៉ូតែកធានាលើបំណុលអណ្តែត យើងគួរយល់នូវនិយមន័យរបស់វាជាមុនសិន។

ហ៊ីប៉ូតែកដើម្បីធានាលើបំណុលអណ្តែត គឺជាហ៊ីប៉ូតែកមួយប្រភេទដែលអាចបង្កើតដើម្បីធានាកាតព្វកិច្ចមិនកំណត់ ដែលកើតមានឡើងរវាងម្ចាស់បំណុល និងកូនបំណុល ដោយសារការជួញដូរជានិរន្តរ៍ ដែលមានប្រភេទជាកំណត់ក្នុងកម្រិតនៃចំនួនអតិបរមា។[45]

---

[44] មើលមាត្រា ៨៦១ ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[45] ១៧៤. ហ៊ីប៉ូតែកធានាបំណុលអណ្តែត សន្ទានុក្រមពាក្យច្បាប់ រដ្ឋប្បវេណី និង នីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៧

ដូចនេះ ហ៊ីប៉ូតែកដើម្បីធានាលើបំណុលអណ្តែត គឺជាការធានាកាតព្វកិច្ចមួយដែលបានបង្កើតឡើង ក្នុងគោលបំណងធានាសិទ្ធិលើបំណុលដែលបានកើតចេញពីការជួញដូរជានិរន្តរ៍ ដែលស្ថិតក្នុងការកំណត់កម្រិតជាក់លាក់មួយ។

## កថាភាគទី១. ការអនុវត្តហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត

បន្ទាប់ពីបានយល់ច្បាស់ពីនិយមន័យនូវហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតហើយ នោះជំហ៊ានបន្ទាប់គឺការអនុវត្តហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត។

ការអនុវត្តហ៊ីប៉ូតែកនេះ គឺចាំបាច់ត្រូវមានការកំណត់ច្បាស់លាស់នៅក្នុងកិច្ចសន្យាបង្កើតហ៊ីប៉ូតែក និងការកំណត់ប្រាក់ដើមជាស្ថាពរ។ ហើយក្រៅពីនេះ ការអនុវត្តហ៊ីប៉ូតែកនេះ ក៏អាចមានការកែប្រែខ្លឹមសារនៃកិច្ចសន្យាបានផងដែរ។

### ក. ការកំណត់នៅក្នុងកិច្ចសន្យាបង្កើតហ៊ីប៉ូតែក

ការអនុវត្តហ៊ីប៉ូតែកប្រភេទនេះ ត្រូវកំណត់ក្នុងកិច្ចសន្យាបង្កើតហ៊ីប៉ូតែក ដែលក្នុងនោះត្រូវកំណត់អោយបានច្បាស់ពីទំហំនៃសិទ្ធិលើបំណុល គឺការកំណត់ការជួញដូរជានិរន្តរ៍ មានន័យថា សិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត នឹងកើតមានឡើងដោយការសង។ ដូចនេះទំហំនៃសិទ្ធិលើបំណុលត្រង់ចំនុចនេះ គឺចង់បង្ហាញថា ម្ចាស់បំណុលអាចអនុវត្តសិទ្ធិលើបំណុលបានក្នុងកម្រិតចំនួនអតិបរមាចំពោះប្រាក់ដើមដែលបានកំណត់ជាស្ថាពរ ការប្រាក់ ឬ ធនលាភផ្សេងទៀត និងការសងនូវការខូចខាតដែលបណ្តាលមកពីការមិនអនុវត្តកាតព្វកិច្ច និយាយអោយខ្លី គឺម្ចាស់បំណុលហ៊ីប៉ូតែកធានាបំណុលអណ្តែតអាចទទួលការសងដោយមានអាទិភាពលើម្ចាស់បំណុលផ្សេងទៀត។

ចំពោះទំហំនៃសិទ្ធិមិនកំណត់ ដែលត្រូវបានធានាដោយហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ត្រូវតែកំណត់នៅក្នុងកិច្ចសន្យាបង្កើតហ៊ីប៉ូតែកផងដែរ។[46]

ក្នុងករណីនេះ នៅពេលអចលនវត្ថុហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតត្រូវបានលក់ នោះម្ចាស់បំណុលហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតគឺ មានភាពចាំបាច់ត្រូវតែកំណត់នូវសិទ្ធិលើបំណុលដែលអាចទទួលការសងដោយមានអាទិភាពពីប្រាក់នៃការលក់អចលនវត្ថុហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតនោះ។

[46] មើលមាត្រា ៨៦៧ កថាខណ្ឌ២ ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

ដូចបានរៀបរាប់នៅខាងលើ ម្ចាស់បំណុលហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតអាចទទួលបាននូវការសងដោយមានអាទិភាព ចំពោះការប្រាក់ និងសំណងនៃការខូចខាត ត្រូវស្ថិតក្រោមចំនួនអតិបរមា ហើយគ្មានកំណត់អំឡុងពេល២ឆ្នាំចុងក្រោយ ដូចទៅនិងកិច្ចសន្យាហ៊ីប៉ូតែកធម្មតាទេ។

### ខ. ការកំណត់ប្រាក់ដើមជាស្ថាពរ

ដើម្បីអនុវត្តហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត សិទ្ធិលើបំណុលដែលអាចទទួលការសងដោយមានអាទិភាពត្រូវតែកំណត់អោយបានច្បាស់លាស់ ដែលនីតិវិធីនេះហៅថា ការកំណត់ប្រាក់ដើមជាស្ថាពរ។ វាជាលក្ខណៈពិសេសនៃហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ដែលការកំណត់ប្រាក់ដើមជាស្ថាពរនេះហើយ ធ្វើអោយហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតមានលក្ខណៈច្បាស់លាស់ ទៅលើចំនួននៃតួលេខនៃបំណុល ពីព្រោះ វាប្រៀបបាននឹងការទូទាត់បញ្ជីនៃការជួញដូរជានិរន្តរ៍ រវាងកូនបំណុល និងម្ចាស់បំណុល ឬជាការកំណត់នូវបំណុលដែលកូនបំណុលបានជាប់ជំពាក់កន្លងមក។

នីតិវិធីនៃការកំណត់ប្រាក់ដើមជាស្ថាពរនេះ គឺ កើតចេញពីការកំណត់រវាងគូភាគីនៅក្នុងកិច្ចសន្យាបង្កើតហ៊ីប៉ូតែក។ ត្រង់ករណីនេះ គូភាគីអាចកំណត់នូវកាលបរិច្ឆេទនៃការកំណត់ប្រាក់ដើមជាស្ថាពរនៅក្នុងកិច្ចសន្យាដោយត្រូវស្ថិតក្នុងអំឡុងពេល ៥ឆ្នាំ គិតចាប់ពីថ្ងៃដែលបានកំណត់ ហើយគូភាគីក៏អាចប្តូរកាលបរិច្ឆេទបានដែរ តែត្រូវស្ថិតក្នុងអំឡុងពេល ៥ឆ្នាំដដែល គិតចាប់ពីថ្ងៃដែលបានប្តូរ។[47] ហេតុដូចនេះ ការកំណត់ប្រាក់ដើមជាស្ថាពរ គឺជាការចាំបាច់ដើម្បីអនុវត្តកិច្ចសន្យាហ៊ីប៉ូតែកនេះ។

ចំពោះករណីដែលគូភាគីមិនបានកំណត់នៅក្នុងកិច្ចសន្យា គឺភាគីអាចធ្វើការទាមទារអោយកំណត់បានដូចគ្នា៖

- អ្នកបង្កើតហ៊ីប៉ូតែក៖ អាចទាមទារអោយកំណត់ប្រាក់ដើមជាស្ថាពរបាន ក្នុងករណី ២ គឺ៖
  - បើបានហួសក្នុងអំឡុងពេល ៣ឆ្នាំ គិតចាប់ពីថ្ងៃដែលបានបង្កើតហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត
  - បើប្រាក់ដើមត្រូវបានធានាលែងកើតមានទៀត ដោយសារការផ្លាស់ប្តូរទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានា ការបញ្ចប់ការជួញដូរ ឬ ហេតុផ្សេងទៀត។
- ម្ចាស់បំណុលហ៊ីប៉ូតែក៖ អាចទាមទារអោយកំណត់ប្រាក់ដើមជាស្ថាពរពេលណាក៏បាន ក្នុងករណីដែលមិនមានកំណត់នូវកាលបរិច្ឆេទកំណត់ប្រាក់ដើមជាស្ថាពរប៉ុណ្ណោះ។

[47] មើលមាត្រា ៨៧១ ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

ដូចនេះ នៅពេលមានការទាមទារតាមរបៀបខាងលើ ប្រាក់ដើមដែលត្រូវបានធានានឹងត្រូវកំណត់ជាស្ថាពរ នៅពេលដែលអំឡុងពេល ២ សប្តាហ៍បានកន្លងផុត គឺគិតចាប់ពីពេលទាមទារនោះតទៅ។

ទោះបីជាបានចែង ឬមិនបានចែងអំពីកាលបរិច្ឆេទនៃការកំណត់ប្រាក់ដើមជាស្ថាពរនៅក្នុងកិច្ចសន្យាក៏ដោយ បើមានមូលហេតុដូចមានចែងក្នុងមាត្រា ៨៨៥ នៃក្រមរដ្ឋប្បវេណី នោះប្រាក់ដើមដែលត្រូវបានធានា ត្រូវកំណត់ជាស្ថាពរ ដោយសារៈ

- ម្ចាស់បំណុលហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត បានដាក់ពាក្យសុំលក់ដោយបង្ខំចំពោះអចលនវត្ថុដែលបានដាក់ហ៊ីប៉ូតែក
- ម្ចាស់បំណុលហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត បានរឹបអូសចំពោះអចលនវត្ថុហ៊ីប៉ូតែក ដោយយោងតាមការចាត់ចែងចំពោះពន្ធតឹងទារ
- ក្នុងអំឡុងពេល ២សប្តាហ៍កន្លងហួស ចាប់ពីពេលដែលម្ចាស់បំណុលហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត បានដឹងពីការចាប់ផ្តើមនីតិវិធីនៃការលក់ដោយបង្ខំ ឬការរឹបអូសដោយយោងតាមការចាត់ចែងចំពោះពន្ធទាមទារ ចំពោះអចលនវត្ថុហ៊ីប៉ូតែកតែប៉ុណ្ណោះ
- កូនបំណុល ឬ អ្នកបង្កើតហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតដែលបានទទួលសេចក្តីប្រកាសអំពីធនក្ស័យ។[48]

ត្រង់ចំនុចនេះដែរ ប្រព័ន្ធនីតិវិធីអនុវត្តដោយបង្ខំ ចំពោះអចលនវត្ថុដែលមានអាទិភាពលើម្ចាស់បំណុលនៃការអនុវត្តមិនត្រូវបានរលត់ដោយការលក់នោះទេ គឺត្រូវបានទទួលបន្តដោយអ្នកទិញ ដោយសារច្បាប់របស់ប្រទេសយើង អនុវត្តតាមគោលការណ៍ទទួលបន្ត។

### គ. ការកែប្រែខ្លឹមសារនៃកិច្ចសន្យា

បន្ទាប់ពីបានសិក្សាទៅលើការកំណត់ក្នុងកិច្ចសន្យា និងការកំណត់ប្រាក់ដើមជាស្ថាពរ និងកាលបរិច្ឆេទនៃការកំណត់ប្រាក់ដើមជាស្ថាពររួចមក យើងសង្កេតឃើញថា ការកែប្រែខ្លឹមសារនៃកិច្ចសន្យា អាចកើតមានឡើងផងដែរ ដោយសារមានការកែប្រែទៅលើទំហំនៃសិទ្ធិលើបំណុល និងការកែប្រែចំនួនអតិបរមាជាដើម។

ដោយយោងតាមមាត្រា ៨៦៩ នៃក្រមរដ្ឋប្បវេណី បានកំណត់ថា ក្នុងចន្លោះពេលទៅទល់នឹងពេលដែលប្រាក់ដើមត្រូវបានកំណត់ជាស្ថាពរ ភាគីនៃកិច្ចសន្យាអាចកែប្រែទំហំនៃសិទ្ធិលើបំណុលតាមការព្រមព្រៀងបាន ហើយការកែប្រែនេះត្រូវចុះបញ្ជីនៅមុនពេលប្រាក់ដើមត្រូវបានកំណត់ជាស្ថាពរ។[49] បញ្ញត្តនេះអាចអនុវត្ត ចំពោះករណីដែលទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានាត្រូវបានកែប្រែ ដោយសារកាកែប្រែខ្លឹមសារនៃការជួញដូរ

[48] មើលមាត្រា ៨៨៥ កថាខណ្ឌ១ ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[49] មាត្រា ៨៦៩ ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

ជានិរន្តរ៍។ ក៏ប៉ុន្តែ ហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ត្រូវបានចាត់ទុកដូចគ្នានឹងហ៊ីប៉ូតែកធម្មតា នៅពេលដែលប្រាក់ដើមត្រូវបានកំណត់ជាស្ថាពរ ដែលជាហេតុនាំអោយ ក្រោយពេលនោះ ទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត មិនអាចកែប្រែបាននោះទេ។ ក្រៅពីនេះ ការកែប្រែទំហំនៃសិទ្ធិលើបំណុលអណ្តែត ពុំចាំបាច់ទទួលការយល់ព្រមពីម្ចាស់បំណុលហ៊ីប៉ូតែកដែលមានអាទិភាពទាបជាងទេ ដោយសារតែម្ចាស់បំណុលហ៊ីប៉ូតែកនោះគួរតែត្រៀមខ្លួនរួចជាស្រេចថា ម្ចាស់បំណុលហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតត្រូវមានអាទិភាពក្នុងទំហំនៃចំនួនអតិបរមា នៃហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ហើយមិនត្រូវទទួលរងការខូចខាតណាមួយទេ ទោះបីមានការកែប្រែទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតដែលមានអាទិភាពខ្ពស់ជាងក៏ដោយ។

ចំពោះការកែប្រែចំនួនអតិបរមា បានចែងកំណត់ក្នុងមាត្រា ៨៧០ ក្រមរដ្ឋប្បវេណីដូចតទៅ៖

- ភាគីនៃកិច្ចសន្យា អាចកែប្រែចំនួនអតិបរមានៃហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតតាមការព្រមព្រៀង
- ត្រូវមានការយល់ព្រមពីសំណាក់ជនដែលមានទំនាក់ទំនងនឹងផលប្រយោជន៍
- ដើម្បីអោយមានល័ក្ខខ័ណ្ឌតតាំងចំពោះបុគ្គលក្រៅពីជនដែលបានផ្តល់ការយល់ព្រម ត្រូវធ្វើការចុះបញ្ជី។

យោងតាមមាត្រា ៨៨៦ នៃក្រមរដ្ឋប្បវេណី បានកំណត់ពីការទាមទារបន្ថយចំនួនអតិបរមាថា នៅក្រោយពេលប្រាក់ដើមត្រូវបានកំណត់ជាស្ថាពរ អ្នកបង្កើតហ៊ីប៉ូតែកអាចទាមទារអោយបន្ថយចំនួនអតិបរមានៃហ៊ីប៉ូតែកមកត្រឹមចំនួននៃកាតព្វកិច្ចដែលមានអត្ថិភាពបច្ចុប្បន្ន បូកនឹងចំនួននៃការប្រាក់ និងផលលាភផ្សេងទៀត ព្រមទាំងចំនួននៃសំណងការខូចខាតដោយសារការមិនអនុវត្តកាតព្វកិច្ច ដែលត្រូវកើតឡើងក្នុងអំឡុងពេល ២ឆ្នាំ ក្រោយពេលដែលប្រាក់ដើមត្រូវបានកំណត់ជាស្ថាពរ។[50]

ដូចនេះយើងអាចសិក្សាបានថា ការកែប្រែខ្លឹមសារនៃកិច្ចសន្យាហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត អាចកែប្រែដោយសារការកែប្រែនូវទំហំនៃសិទ្ធិ និង ការកែប្រែចំនួនអតិបរមាដែលកើតចេញពីការព្រមព្រៀង តែប្រសិនបើប្រាក់ដើមត្រូវបានកំណត់ជាស្ថាពរ នោះទំហំនៃសិទ្ធិមិនអាចកែប្រែបានទេ។

### កថាភាគទី២.ការចាត់ចែងហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត

ការចាត់ចែងហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតមាន ២ ដំណាក់កាល គឺមុនពេលប្រាក់ដើមត្រូវបានកំណត់ និង ក្រោយពេលប្រាក់ដើមត្រូវបានកំណត់។

[50] មើលមាត្រា ៨៨៦ ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

### ក. មុនពេលប្រាក់ដើមត្រូវបានកំណត់

យោងតាមមាត្រា ៨៧៦ នៃក្រមរដ្ឋប្បវេណីបានចែងថា នៅមុនពេលប្រាក់ដើមត្រូវបានកំណត់ជាស្ថាពរ ម្ចាស់បំណុលហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត មិនអាចធ្វើការចាត់ចែងដែលបានកំណត់នៅក្នុងកថាខណ្ឌទី១ នៃមាត្រា៨៦០ (អនុប្បទាន ឬ ការបោះបង់នូវហ៊ីប៉ូតែក) ឬ កថាខណ្ឌទី១ នៃមាត្រា ៨៦១ (អនុប្បទាន ឬការបោះបង់ និងការផ្លាស់ប្តូរនូវលំដាប់នៃហ៊ីប៉ូតែក) បានទេ។[51]

ដូចនេះយើងអាចនិយាយបានថា ការចាត់ចែងហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត មុនពេលប្រាក់ដើមត្រូវបានកំណត់ជាស្ថាពរអាចធ្វើលើហ៊ីប៉ូតែកបន្តបាន និងអាចធ្វើលើអនុប្បទានហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតបាន ដោយទទួលការយល់ព្រមពីអ្នកបង្កើតហ៊ីប៉ូតែកប៉ុណ្ណោះ។

### ខ. ក្រោយពេលប្រាក់ដើមត្រូវបានកំណត់

ការចាត់ចែងហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ក្រោយពេលប្រាក់ដើមត្រូវបានកំណត់ជាស្ថាពរ អាចចាត់ចែងលើហ៊ីប៉ូតែកទាំងបីប្រភេទបាន ពីព្រោះនៅពេលដែលប្រាក់ដើមត្រូវបានកំណត់ជាស្ថាពរនោះ ហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតត្រូវបានក្លាយទៅជាហ៊ីប៉ូតែកធម្មតាវិញ។

ក្រៅពីនេះ ក្រមរដ្ឋប្បវេណីក៏បានចែងពីបញ្ញត្តិផ្សេងៗ ដែលទាក់ទងនឹងហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ដូចជាសិទ្ធិរួមលើហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត អានុភាពនៃអនុប្បទានហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតដោយម្ចាស់បំណុលហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតដែលទទួលបានអនុប្បទាន ឬ ការបោះបង់លំដាប់នៃហ៊ីប៉ូតែក ហ៊ីប៉ូតែករួមដើម្បីធានាបំណុលអណ្តែត មាត្រាស្តីពីការកែប្រែ អនុប្បទាន និងការកំណត់ជាស្ថាពរ នូវហ៊ីប៉ូតែករួមដើម្បីធានាបំណុលអណ្តែត និង ហ៊ីប៉ូតែកតម្រួតដើម្បីធានាបំណុលអណ្តែតផងដែរ។

យោងតាមមាត្រា ៧៦៩ នៃក្រមរដ្ឋប្បវេណី ហ៊ីប៉ូតែកដើម្បីធានាលើបំណុលអណ្តែត គឺជាករណីលើកលែងនៃភាពបន្ទាប់បន្សំនៃសិទ្ធិប្រាតិភោគប្រត្យក្ស។[52]

ចំពោះ សិទ្ធិរួមលើហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត គឺ ម្ចាស់សិទ្ធិរួមលើហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ត្រូវទទួលបាននូវការសងតាមសមាមាត្រនៃសិទ្ធិលើបំណុលនីមួយៗ។ ម្ចាស់សិទ្ធិរួមលើហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត អាចធ្វើអនុប្បទាននូវសិទ្ធិរបស់ខ្លួន ដោយយោងតាមបញ្ញត្តិនៃមាត្រា ៨៧៧ (អនុប្បទានហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត) ដោយការយល់ព្រមពីម្ចាស់សិទ្ធិរួមឯទៀត។ តែក្នុងករណី មានការកំណត់

[51] មើលមាត្រា ៨៧៦ ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[52] ដកស្រង់ចេញពីការសេចក្តីកំណត់មាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគទី៤: គន្ថីទី៦, ជំពូកទី៥: ផ្នែកទី៧

ចំណែកភាគផ្សេងពីករណីខាងលើមុនពេលប្រាក់ដើមត្រូវបានកំណត់ជាស្ថាពរ ឬ បើមានការកំណត់ថា ជនណាម្នាក់អាចទទួលការសង ដោយមានអាទិភាពជាងជនឯទៀត ត្រូវអនុទ្បោមតាមការកំណត់នោះ។[53]

ប្រសិនបើ ម្ចាស់បំណុលហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត បានទទួលអនុប្បទាន ឬ ការបោះបង់លំដាប់នៃហ៊ីប៉ូតែកពីម្ចាស់បំណុលហ៊ីប៉ូតែកធម្មតា ហើយបានធ្វើអនុប្បទានហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតទាំងមូល ឬ មួយផ្នែក នោះនៅពេលក្រោយមក អនុប្បទានិកត្រូវទទួលផលប្រយោជន៍នៃអនុប្បទាន ឬ ការបោះបង់លំដាប់នៃហ៊ីប៉ូតែក។[54]

យោងតាមមាត្រា ៨៨១ បានចែងកំណត់អំពីករណីហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ត្រូវបានបង្កើតលើអចលនវត្ថុជាច្រើន ពោល គឺហ៊ីប៉ូតែករួមដើម្បីធានាបំណុលអណ្តែត។ ត្រង់បញ្ញត្តិនេះ មាត្រាដែលចែងអំពីហ៊ីប៉ូតែករួមធម្មតា គឺមាត្រា ៨៥៧ និង មាត្រា ៨៥៨ ត្រូវបានយកមកអនុវត្ត ប្រសិនបើល័ក្ខខ័ណ្ឌពីរត្រូវបានបំពេញ។[55] ល័ក្ខខ័ណ្ឌទី១ គឺហ៊ីប៉ូតែករួមដើម្បីធានាបំណុលអណ្តែត ត្រូវបានបង្កើតឡើង ដើម្បីធានាសិទ្ធិលើបំណុលតែមួយដូចគ្នា ពោលគឺ ទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានា កូនបំណុល និង កម្រិតនៃចំនួនអតិបរមាដូចគ្នា។ ល័ក្ខខ័ណ្ឌទី២ គឺការចុះបញ្ជីត្រូវបានធ្វើឡើងដើម្បីបង្ហាញថា ហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតត្រូវបានបង្កើតឡើងលើអចលនវត្ថុជាច្រើនដើម្បីធានាសិទ្ធិលើបំណុលដូចគ្នា។

ក្រៅពីការកែប្រែខ្លឹមសារនៃកិច្ចសន្យាបង្កើតហ៊ីប៉ូតែក ក្រមរដ្ឋប្បវេណី ក៏បានចែងពីការកែប្រែ អនុប្បទាន និងការកំណត់ជាស្ថាពរនូវហ៊ីប៉ូតែករួមដើម្បីធានាបំណុលអណ្តែតដែរ គឺមាត្រា ៨៨២។[56] បញ្ញត្តិនេះ គឺជាបញ្ញត្តិពិសេស ដែលបានចែងថា បើទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានាកូនបំណុល ឬ ចំនួនអតិបរមាត្រូវបានកែប្រែ ឬ ហ៊ីប៉ូតែករួមដើម្បីធានាបំណុលអណ្តែត ត្រូវបានធ្វើអនុប្បទានទាំងមូល ឬមួយផ្នែក ការកែប្រែ ឬ អនុប្ប-ទាននេះ នឹងមិនត្រូវមានអានុភាពទេ ប្រសិនបើមិនបានចុះបញ្ជីចំពោះអចលនវត្ថុដែលពាក់ព័ន្ធទាំងអស់។ ហើយ ប្រាក់ដើមត្រូវតែកំណត់ជាស្ថាពរ ទោះបីជាហេតុដែលនាំអោយកំណត់ប្រាក់ដើមជាស្ថាពរ បានកើតឡើងចំពោះអចលនវត្ថុតែមួយក៏ដោយ។

ហ៊ីប៉ូតែកតម្រួតដើម្បីធានាបំណុលអណ្តែត បានចែងថា ជនដែលជាម្ចាស់បំណុលហ៊ីប៉ូតែកតម្រួតដើម្បីធានបំណុលអណ្តែត អាចអនុវត្តសិទ្ធិជាអាទិភាពចំពោះប្រាក់ថ្លៃលក់នៃអចលនវត្ថុនីមួយៗបាន ពោលគឺ អាច

[53] មើលមាត្រា ៨៧៩ ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧
[54] មើលមាត្រា ៨៨០ ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧
[55] មើលមាត្រា ៨៨១ ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧
[56] មើលមាត្រា ៨៨២ ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

ទទួលការសងដោយមានអាទិភាពបាន រហូតដល់ចំនួនអតិបរមាសម្រាប់អចលនវត្ថុនីមួយៗ ពីទឹកប្រាក់ដែលបានពីអចលនវត្ថុនីមួយៗ។

## ផ្នែកទី៣. នីតិវិធីនៃការអនុវត្តហ៊ីប៉ូតែក

ដោយសារតែ ហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតបានក្លាយជាហ៊ីប៉ូតែកធម្មតានៅពេលដែលប្រាក់ដើមត្រូវបានកំណត់ជាស្ថាពរ ហេតុដូចនេះទើបនីតិវិធីនៃការអនុវត្តគឺមានទម្រង់ និងដំណាក់ដូចគ្នា ចំនួន៧ ដំណាក់កាល គឺ៖

- ដំណាក់កាលទី១៖ ការរៀបចំការដាក់ពាក្យ
- ដំណាក់កាលទី២៖ ការធ្វើពាក្យសុំ
- ដំណាក់កាលទី៣៖ ការដាក់ពាក្យសុំ
- ដំណាក់កាលទី៤៖ ការពិនិត្យពាក្យសុំ
- ដំណាក់កាលទី៥៖ ការលើកចោលពាក្យសុំ
- ដំណាក់កាលទី៦៖ ដីកាសម្រេចចាប់ផ្តើមលក់ដោយបង្ខំ
- ដំណាក់កាលទី៧៖ ការផ្ទុកផ្តាក់អោយចុះបញ្ជីរឹបអូស
- ដំណាក់កាលទី៨៖ ការចុះបញ្ជីអំពីការរឹបអូស
- ដំណាក់កាលទី៩៖ ការបញ្ជូនឯកសារចម្លង ដែលមានសេចក្តីបញ្ជាក់នៃសៀវភៅចុះបញ្ជីអចលនវត្ថុ
- ដំណាក់កាលទី១០៖ ការបញ្ជូនដីកាសម្រេចចាំផ្តើមលក់ដោយបង្ខំទៅកូនបំណុលនៃការអនុវត្ត
- ដំណាក់កាលទី១១៖ ដីកាសម្រេចកំណត់ពេលចុងក្រោយសម្រាប់ការទាមទារអោយចែកចំណែក និងការប្រកាសជាសាធារណៈ
- ដំណាក់កាលទី១២៖ ការទាមទារអោយចែកចំណែក
- ដំណាក់កាលទី១៣៖ ការដាស់តឿនអោយរាយការណ៍អំពីសិទ្ធិលើបំណុល
- ដំណាក់កាលទី១៤៖ ការវាយតម្លៃ
- ដំណាក់កាលទី១៥៖ ឯកសារលំអិតអំពីវត្ថុ
- ដំណាក់កាលទី១៦៖ ដីកាសម្រេចកំណត់តម្លៃលក់អប្បបរមា
- ដំណាក់កាលទី១៧៖ ការបង្គាប់អោយអនុវត្តការលក់
- ដំណាក់កាលទី១៨៖ ការប្រកាសជាសាធារណៈនូវកាលបរិច្ឆេទនៃការលក់ជាអាទិ៍ និង ការទុកឯកសារលំអិតអំពីវត្ថុជាអាទិ៍

- ដំណាក់កាលទី១៩៖ ការអនុវត្តការលក់
- ដំណាក់កាលទី២០៖ ការកំណត់កាលបរិច្ឆេទដើម្បីចេញដីកាសម្រេចការលក់
- ដំណាក់កាលទី២១៖ ដីកាសម្រេចអនុញ្ញាតឱ្យលក់ ឬ ដីកាសម្រេចមិនអនុញ្ញាតឱ្យលក់
- ដំណាក់កាលទី២២៖ ការកំណត់ពេលនៃការបង់ថ្លៃលក់
- ដំណាក់កាលទី២៣៖ ការបង់ថ្លៃលក់
- ដំណាក់កាលទី២៤៖ ការផ្ទុកផ្តាក់អោយចុះបញ្ជី
- ដំណាក់កាលទី២៥៖ ការចុះបញ្ជីផ្អែកតាមការផ្ទុកផ្តាក់
- ដំណាក់កាលទី២៦៖ ការកំណត់កាលបរិច្ឆេទនៃការចែកចំណែក
- ដំណាក់កាលទី២៧៖ ការជូនដំណឹងអំពីកាលបរិច្ឆេទអំពីការចែកចំណែក និងការដាស់តឿនលិខិតគណនាជាដើម
- ដំណាក់កាលទី២៨៖ ការបង្កើតសេចក្តីព្រាងដើមនៃតារាងចែកចំណែក
- ដំណាក់កាលទី២៩៖ ការបើកកាលបរិច្ឆេទនៃការចែកចំណែក និង ការអនុវត្តការចែកចំណែក។

ដំណាក់កាលដែលបានរៀបរាប់ខាងលើទាំងអស់នេះ ត្រូវបានបែងចែកចេញជា ៣ កថាភាគដូចតទៅ៖

- កថាភាគទី១ ការរឹបអូស ចាប់ពីដំណាក់កាលទី១ ដល់ដំណាក់កាលទី១០
- កថាភាគទី២ ការលក់ ចាប់ពីដំណាក់កាលទី១១ ដល់ដំណាក់កាលទី២៥
- កថាភាគទី៣ ការចែកចំណែក ចាប់ពីដំណាក់កាលទី២៦ ដល់ដំណាក់កាលទី២៩។

## កថាភាគទី១ ការរឹបអូស

នៅក្នុងកថាភាគទី១ការអនុវត្តនីតិវិធីនៃការរឹបអូស គឺមានចំនួនដប់ដំណាក់កាលដូចដែលបានបញ្ជាក់ពីខាងលើ។

### ក. ការរៀបចំដាក់ពាក្យ

ដំណាក់កាលនេះ គឺម្ចាស់បំណុលហ៊ីប៉ូតែកត្រូវរៀបចំការដាក់ពាក្យដោយមានឯកសារមួយចំនួនដូចជា៖

- រូបមន្តអនុវត្ត
- លិខិតបញ្ជាក់អំពីការបញ្ជូន
- ឯកសារចម្លងយថាភូតនៃលិខិតអនុវត្ត
- ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នៃសៀវភៅចុះបញ្ជីអចលនវត្ថុ។

យោងតាមមាត្រា ៣៥៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី បានចែងថា[57]៖

១. ការអនុវត្តដោយបង្ខំត្រូវបានធ្វើឡើងដោយផ្អែកលើឯកសារសម្លងយថាភូតនៃលិខិតអនុវត្តដែលភ្ជាប់ជាមួយនឹងរូបមន្តអនុវត្ត។ ប៉ុន្តែក្នុងករណីដែលយកឯកសារដែលបានកំណត់ដូចខាងក្រោមនេះជាលិខិតអនុវត្តការអនុវត្តដោយបង្ខំ ដោយយកភាគីដែលបានកំណត់ក្នុងលិខិតអនុវត្តនោះធ្វើជាម្ចាស់បំណុលនៃការអនុវត្ត ឬកូនបំណុលនៃការអនុវត្តត្រូវធ្វើឡើង ដោយផ្អែកលើឯកសារចម្លងនៃលិខិតយថាភូតនៃលិខិតអនុវត្តនោះ៖

ក. សាលក្រមនៃបណ្តឹងរឿងក្តីចំនួនទឹកប្រាក់តិចដែលចូលជាស្ថាពរ

ខ. សាលក្រមនៃបណ្តឹងរឿងក្តីចំនួនទឹកប្រាក់តិចដែលភ្ជាប់ការប្រកាសអោយអនុវត្តជាបណ្តោះអាសន្ន

គ. ដីកាសម្រេចដាស់តឿនដែលភ្ជាប់ការប្រកាសអោយអនុវត្តជាបណ្តោះអាសន្ន។

២. រូបមន្តអនុវត្តត្រូវផ្តល់ដោយក្រឡាបញ្ជីនៃតុលាការដែលមានសំណុំរឿងនោះតាមពាក្យសុំ។ ប៉ុន្តែចំពោះលិខិតអនុវត្តដែលបានកំណត់នៅក្នុងចំណុច ច កថាខណ្ឌទី២ មាត្រា ៣៥០ (លិខិតអនុវត្ត) នៃក្រមនេះត្រូវផ្តល់ដោយសារការីដែលរក្សាទុកនូវលិខិតដើមនោះ។

យោងតាមមាត្រាខាងលើ យើងអាចនិយាយបានថា ម្ចាស់បំណុលនៃការអនុវត្តត្រូវដាក់នូវឯកសារយថាភូតនៃលិខិតអនុវត្ត បូករួមនឹងពាក្យសុំអោយផ្តល់រូបមន្តអនុវត្ត ទៅអោយតុលាការដែលមានសំណុំរឿង ឬសារការីដែលជាអ្នករក្សាទុកនូវលិខិតដើមនោះ។ បន្ទាប់មកក្រឡាបញ្ជី ឬសារការីនឹងធ្វើការផ្ទៀងផ្ទាត់និងត្រួតពិនិត្យទៅលើច្បាប់ដើមនៃលិខិតអនុវត្ត និងពាក្យសុំនោះ ថាមានបានសរសេរអំពីអត្ថិភាពនៃប្រាតិភោគឬអត់ព្រមទាំងពិនិត្យលើសាលក្រមនោះបានចូលជាស្ថាពរ ឬនៅ។ ចុងក្រោយ នៅពេលដែលពិនិត្យរួចរាល់ហើយយល់ថាត្រឹមត្រូវ នោះក្រឡាបញ្ជី ឬសារការី នឹងផ្តល់រូបមន្តអនុវត្តលើឯកសារចម្លងយថាភូតនៃលិខិតអនុវត្តនោះ។

ចំពោះលិខិតបញ្ជាក់អំពីការបញ្ជូន យោងតាមមាត្រា ៣៦០ នៃក្រមនីតិវិធីរដ្ឋប្បវេណី យើងអាចនិយាយបានថា មុននឹងដាក់ពាក្យសុំអនុវត្តហ៊ីប៉ូតែក ម្ចាស់បំណុលត្រូវបញ្ជូននូវឯកសារចម្លងដែលមានសេចក្តីបញ្ជាក់ ឬឯកសារចម្លងយថាភូតនៃលិខិតអនុវត្ត ទៅកូនបំណុលនៃការអនុវត្ត។ ក្រៅពីនេះ ចំពោះករណីដែលបានផ្តល់រូបមន្តអនុវត្តពិសេស ម្ចាស់បំណុលក៏ត្រូវបញ្ជូននូវរូបមន្តអនុវត្ត និងឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នៃឯកសារដែលបានដាក់ដើម្បីទទួលបានរូបមន្តអនុវត្តពិសេស ទៅកូនបំណុលដូចគ្នាដែរ។ រួចមក ទើបម្ចាស់បំណុលហ៊ីប៉ូ-តែកទទួលបានលិខិតបញ្ជាក់ពីការបញ្ជូន ដោយភ្ជាប់លិខិតនោះជាមួយនឹងពាក្យសុំឱ្យអនុវត្តហ៊ីប៉ូតែក។

[57] មាត្រា ៣៥៤ ក្រមនីតិវិធិរដ្ឋប្បវេណី ឆ្នាំ ២០០៦

ការអនុវត្តហ៊ីប៉ូតែកចាំបាច់មានលិខិត២ប្រភេទ[58] ពីព្រោះតុលាការ និងសារការីជាអ្នករក្សាទុកនូវច្បាប់ដើមនៃលិខិតអនុវត្តហ៊ីប៉ូតែក ទើបបានជាម្ចាស់បំណុលហ៊ីប៉ូតែកត្រូវរៀបចំឯកសារយថាភូត ដូចតទៅ៖

- សាលក្រម ឬ សាលដីកាដែលបានបញ្ជាក់អំពីអត្ថិភាពនៃសិទ្ធិប្រាតិភោគ ឬ លិខិតដែលមានអានុភាពដូចសាលក្រម ឬសាលដីកាស្ថាពរនោះ ដូចជា សាលក្រមបង្គាប់ឱ្យផ្តល់តាវកាលិកជាដើម។
- លិខិតយថាភូតដែលធ្វើឡើងដោយសារការីដែលបានបញ្ជាក់អំពីអត្ថិភាពនៃសិទ្ធិប្រាតិភោគ ដូចជា លិខិតយថាភូតនៃកិច្ចសន្យាបង្កើតហ៊ីប៉ូតែកជាដើម។

ចំពោះករណីនេះដែរ នៅពេលរៀបចំឯលសារចម្លងយថាភូតនៃលិខិតអនុវត្តវានឹងមានភាពងាយស្រួលដោយមិនចាំបាច់ប្តឹងទៅតុលការ ប្រសិនបើលិខិតយថាភូតនោះធ្វើឡើងដោយសារការី។ ក្រៅពីឯកសារដែលបានបញ្ជាក់ខាងលើ គឺត្រូវមានឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នៃសៀវភៅចុះបញ្ជីផងដែរ។

**ខ. ការធ្វើពាក្យសុំ**

យោងតាមមាត្រា ៥០៩ នៃក្រមនីតិវិធីរដ្ឋប្បវេណីបានចែងពាក់ព័ន្ធនឹងចំណុចដែលត្រូវសរសេរនៅក្នុងពាក្យសុំឱ្យអនុវត្តសិទ្ធិប្រាតិភោគចំពោះអចលនវត្ថុជាអាទិ៍។[59] ការធ្វើពាក្យសុំ គឺជាដំណាក់កាលទី២នៃការរឹបអូសដែលម្ចាស់បំណុលនៃការអនុវត្តត្រូវធ្វើពាក្យឱ្យអនុវត្តហ៊ីប៉ូតែក ហើយពាក្យសុំនោះត្រូវធ្វើឡើងជាលាយល័ក្ខណ៍អក្សរផងដែរ។

**គ. ការដាក់ពាក្យសុំ**

យោងតាម មាត្រា ៣៧២ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី បានចែងថា ក្នុងករណីដែលដាក់ពាក្យសុំអោយអនុវត្តដោយបង្ខំទៅតុលាការអនុវត្ត ម្ចាស់បំណុលនៃការអនុវត្តត្រូវបង់ពន្ធចំនួន១០.០០០ (មួយម៉ឺន) រៀលទៅតុលាការ។[60] ក្រៅពីនេះ មាត្រា ៣៧៥ ដែលចែងអំពីការបង់សោហ៊ុយជាមុននៅពេលដាក់ពាក្យសុំផងដែរ។[61]

វាជាដំណាក់កាលទី៣ ដែលម្ចាស់បំណុលហ៊ីប៉ុតែក ត្រូវដាក់ពាក្យសុំអោយអនុវត្តហ៊ីប៉ូតែក និងឯកសារភ្ជាប់ទៅតុលាការអនុវត្ត និងបង់ពន្ធដាក់ពាក្យសុំ ចំនួន មួយម៉ឺនរៀល ព្រមទាំងធ្វើការបង់សោហ៊ុយជាមុនថែមទៀត។

[58] មាត្រា ៤៩៦ និង មាត្រា ៥០៩ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦
[59] មើលមាត្រា ៥០៩ នៃក្រមនីតិរដ្ឋប្បវេណី ឆ្នាំ ២០០៦
[60] មាត្រា ៣៧២ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៦
[61] មើលមាត្រា ៣៧៥ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៦

### ឃ. ការពិនិត្យពាក្យសុំ និង ការលើកចោលពាក្យសុំ

ការពិនិត្យពាក្យសុំ និង ការលើកចោលពាក្យសុំ ក៏បានចែងនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីដែរដូចជា៖

- មាត្រា ៣៣៥ ដែលចែងអំពី ការអនុវត្តដូចគ្នាតាមបញ្ញត្តិពីគន្លឹទី២ ដល់គន្លឹទី៤
- មាត្រា ២១៣ ដែលចែងអំពី ការជូនដំណឹងអំពីដីកាសម្រេច។[62]

ចំពោះដំណាក់កាលទី៤ និងទី៥ នេះ គឺតុលាការអនុវត្តនឹងត្រូវធ្វើការពិនិត្យលើខ្លឹមសារនៃពាក្យសុំអោយអនុវត្តហ៊ីប៉ូតែក ឯកសារភ្ជាប់ ពន្ធដាក់ពាក្យសុំ និងការបង់សោហ៊ុយជាមុន។ ត្រង់ចំណុចនេះមាន២ករណី៖ ករណីទីមួយ នៅពេលដែលតុលការត្រួតពិនិត្យហើយ ថាពាក្យសុំមានភាពត្រឹមត្រូវ នោះតុលាការអនុវត្តនឹងចេញដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំ។ ករណីទីពីរ ប្រសិនបើ ពាក្យសុំមានភាពមិនត្រឹមត្រូវ នោះតុលាការនឹងចេញដីកាសម្រេចលើកចោលពាក្យសុំនោះ។ ចំពោះករណីទី២នេះ តុលាការអនុវត្តគ្រាន់តែជូនដំណឹងទៅម្ចាស់បំណុលដោយមធ្យោបាយសមរម្យ រួចនីតិវិធីនឹងត្រូវបានបញ្ចប់ ចំណែកឯកូនបំណុលហ៊ីប៉ូតែកមិនចាំបាច់ជូនដំណឹងទេ។

### ង. ដីកាសម្រេចចាប់ផ្តើមលក់ដោយបង្ខំ

បន្ទាប់ពីបានចេញដីកាសម្រេចចាបើផ្តើមលក់ដោយបង្ខំ តុលាការអនុវត្តត្រូវជូនដំណឹងដោយមធ្យោបាយសមរម្យទៅម្ចាស់បំណុលហ៊ីប៉ូតែកអំពីដីកានេះ ហើយក្រឡាបញ្ជីត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់នូវហេតុការណ៍ និង វិធីនៃការជូនដំណឹងនោះដាក់ក្នុងសំណុំរឿងអំពីការណ៍ដែលបានជូនដំណឹង។ ត្រង់ចំណុចនេះ យើងសិក្សារយោងតាមមាត្រា ២១៣ កថាខណ្ឌទី៣ គឺនៅពេលជូនដំណឹងអំពីដីកាសម្រេច ក្រឡាបញ្ជីត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់នូវហេតុការណ៍ និង វិធីនៃការជូនដំណឹងនោះដាក់ក្នុងសំណុំរឿង។[63]

### ច. ការផ្ទុកផ្តាក់ឱ្យចុះបញ្ជីរឹបអូស

ដោយយោងតាមមាត្រា ៤២០ កថាខណ្ឌ១ នៃក្រមនីតិវិធីរដ្ឋប្បវេណីបានចែងថា បើដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំត្រូវបានចេញ ក្រឡាបញ្ជីត្រូវផ្ទុកផ្តាក់ឱ្យស្ថាប័នដែលមានសមត្ថកិច្ចចុះបញ្ជី អំពីការរឹបអូសដែលពាក់ព័ន្ធនឹងដីកាសម្រេចចាប់ផ្តើមនោះជាបន្ទាន់។[64] លើសពីនេះ ប្រការ៤ កថាខណ្ឌ១ នៃប្រកាសអន្តរក្រសួងស្តីពីការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណី ក៏បានចែងថា ចំពោះការចុះបញ្ជីដែលបាន

[62] មើលមាត្រា ៣៣៥ និង មាត្រា ២១៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[63] មាត្រា ២១៣ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[64] មាត្រា ៤២០ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

បញ្ញត្តនៅក្នុងកថាខណ្ឌទី១ នៃប្រការ២ (គោលបំណង) ក្រឡាបញ្ជីត្រូវធ្វើលិខិតផ្ទុកផ្តាក់ទៅរដ្ឋបាលសុរិយោដី រាជធានី ខេត្ត។[65]

ដំណាក់កាលនេះ គឺជាដំណាក់កាលបន្ទាប់ពីតុលាការអនុវត្តបានចេញដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំ ដែលក្រឡាបញ្ជីមានតួនាទីធ្វើលិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជីពីការរឹបអូសនូវអចលនវត្ថុហ៊ីប៉ូតែកនោះអោយបានឆាប់រហ័ស បន្ទាប់មកទៀតត្រូវបញ្ជូនលិខិតនេះទៅកាន់អាជ្ញាធរពាក់ព័ន្ធ គឺរដ្ឋបាលសុរិយោដី រាជធានី/ខេត្ត ដែលអចលនវត្ថុនោះស្ថិតនៅ។

**ឆ. ការចុះបញ្ជីអំពីការរឹបអូស**

យោងតាម មាត្រា ៤២០ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី និង ប្រការ២ នៃប្រកាសអន្តរក្រសួងស្តីពីការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណី។[66]

ដូចនេះ ការចុះបញ្ជីអំពីការរឹបអូស នឹងត្រូវធ្វើឡើងនៅក្រោយពេលដែលមន្ត្រីចុះបញ្ជីបានទទួលលិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជីហើយ។

**ជ. ការបញ្ជូនឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នៃសៀវភៅចុះបញ្ជីអចលនវត្ថុ**

យោងតាមប្រការ ៣៨ (ការផ្ញើរឯកសារចម្លងដែលមានសេចក្តីបញ្ជាក់ទៅក្រឡាបញ្ជី) នៃប្រកាសអន្តរក្រសួងស្តីពីការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណី បានចែងថា បន្ទាប់ពីបានចុះបញ្ជីតាមលិខិតផ្ទុកផ្តាក់របស់ក្រឡាបញ្ជីរួចហើយ រដ្ឋបាលសុរិយោដីរួចហើយ រដ្ឋបាលសុរិយោដីត្រូវថតចម្លងចេញពីសៀវភៅគោលបញ្ជីដីធ្លី ឬ សៀវភៅចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍ ឬ សៀវភៅចុះបញ្ជីផលុបភោគដែលបានចុះនោះ ដោយមានសេចក្តីបញ្ជាក់របស់ប្រធានរដ្ឋបាលសុរិយោដី រាជធានី ខេត្ត ថា "បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម" រួចផ្ញើទៅក្រឡាបញ្ជីដែលបានធ្វើលិខិតផ្ទុកផ្តាក់នោះ។[67]

ដំណាក់កាលទី៩នេះ គឺជាដំណាក់កាលបន្ទាប់ដែលរដ្ឋបាលសុរិយោដីមានតួនាទីបញ្ជូនលិខិតផ្ទុកផ្តាក់ដែលបានផ្ញើរួច ក្រោយពីបានចុះបញ្ជីអំពីការរឹបអូស ទៅក្រឡាបញ្ជីដោយមានភ្ជាប់ជាមួយនឹងសេចក្តីបញ្ជាក់ពិប្រធានរដ្ឋបាលសុរិយោដី រាជធានី/ខេត្ត ដោយបានបញ្ជាក់លើឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នៃសៀវភៅចុះបញ្ជីអចលនវត្ថុថា បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម។

[65] ប្រការ៤ កថាខណ្ឌទី១ នៃប្រកាសអន្តរក្រសួងស្តីពីការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណី

[66] មើលមាត្រា ៤២០ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦ និង ប្រការ ២ នៃប្រកាសអន្តរក្រសួងស្តីពីការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណី

[67] ប្រការ ៣៨ នៃប្រកាសអន្តរក្រសួងស្តីពីការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណី

### ឈ. ការបញ្ជូនដីកាសម្រេចចាប់ផ្តើមលក់ដោយបង្ខំទៅកូនបំណុលនៃការអនុវត្ត

យោងតាមមាត្រា ៤១៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី ដែលបានចែងអំពីដីកាសម្រេចចាប់ផ្តើមជាអាទិ៍។[68]

ដំណាក់កាលនេះ ជាដំណាក់កាលចុងក្រោយនៃនីតិវិធីនៃការរឹបអូស ដែលតុលាការអនុវត្តនឹងបញ្ជូនដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំទៅកូនបំណុលនៃការអនុវត្ត ក្រោយពីពេលបានត្រួតពិនិត្យមើលឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នៃសៀវភៅចុះបញ្ជីអចលនវត្ថុដែលទទួលបានពីរដ្ឋបាលសុរិយោដី និងបន្ទាប់ពីបានធ្វើការបញ្ជាក់អំពីការសម្រេចឱ្យចុះបញ្ជីអំពីការរឹបអូសហើយ។

### កថាភាគទី២ ការលក់

នៅក្នុងកថាភាគនេះ យើងនឹងសិក្សាទៅលើនីតិវិធីនៃការលក់អចលនវត្ថុនោះ ដែលមានដំណាក់កាលទាំងអស់ចំនួន ១៤ដំណាក់កាល គឺចាប់ពីដំណាក់កាលទី១១ រហូតដល់ទី២៥។

### ក. ដីកាសម្រេចកំណត់ពេលចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែក និង ការប្រកាសជាសាធារណៈ

យោងតាមមាត្រា ៤២២ កថាខណ្ឌទី១ និង ទី២ បានចែងអំពីការកំណត់ពេលចុងក្រោយសម្រាប់ការទាមទារអោយចែកចំណែក និង ការផ្លាស់ប្តូរពេលកំណត់នោះ។[69]

ដូចនេះ នៅពេលបានធ្វើការបញ្ជាក់អំពីការសម្រេចឱ្យចុះបញ្ជីអំពីការរឹបអូសរួច តុលាការអនុវត្តគឺជាអ្នកកំណត់ពេលចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែក ព្រមទាំងជាអ្នកប្រកាសជាសាធារណៈអំពីការណ៍ដែលដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំត្រូវបានចេញ និង អំពីពេលកំណត់ចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែក។

### ខ. ការទាមទារឱ្យចែកចំណែក

ដោយយោងតាមមាត្រា ៤២៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី បានចែងអំពីការទាមទារឱ្យចែកចំណែក ដែលមាន៤កថាខណ្ឌដូចមានក្នុងក្រមនោះ។[70]

យើងសង្កេតឃើញថា ម្ចាស់បំណុលអាចមានច្រើនអ្នក ដូចនេះហើយទើបដំណាក់កាលទី១១ អនុញ្ញាតអោយម្ចាស់បំណុលផ្សេងទៀត អាចទាមទារឱ្យចែកចំណែកក្នុងអំឡុងពេលចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែកនោះបានផងដែរ។

[68] មើលមាត្រា ៤១៩ នៃក្រមនីតិរដ្ឋប្បវេណី ឆ្នាំ ២០០៦

[69] មើលមាត្រា ៤២២ កថាខណ្ឌទី១ និង ទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[70] មើលមាត្រា ៤២៦ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៦

**គ. ការដាស់តឿនឱ្យរាយការណ៍អំពីសិទ្ធិលើបំណុល**

មាត្រា ៤២២ កថាខណ្ឌទី២ ក៏បានចែងបញ្ជាក់អំពីការដាស់តឿនឱ្យរាយការណ៍អំពីសិទ្ធិលើបំណុលដែរ គឺ ក្រៅពីមានតួនាទីចេញដីកាម្រេចកំណត់ពេលចុងក្រោយសម្រាប់ការទាមទារឱ្យចែកចំណែក និងប្រកាសជាសាធារណៈហើយ តុលាការអនុវត្តក៏ត្រូវដាស់តឿនម្ចាស់បំណុលដែលបានកំណត់អោយរាយការណ៍អំពីសិទ្ធិលើបំណុលរបស់ខ្លួន។

**ឃ. ការវាយតម្លៃ**

យោងតាម មាត្រា ៤៣០ កថាខណ្ឌទី១ បានចែងថា តុលាការអនុវត្តត្រូវជ្រើសតាំងអ្នកវាយតម្លៃ និងបង្គាប់ឱ្យវាយតម្លៃអចលនវត្ថុដោយផ្អែកលើការស្រាវជ្រាវអំពីសណ្ឋាននៃអចលនវត្ថុ ទំនាកទំនងនៃការកាន់កាប់ និងស្ថានភាពបច្ចុប្បន្នឯទៀត និង កថាខណ្ឌទី៥ បានចែងថា អ្នកវាយតម្លៃត្រូវដាកជូនតុលាការអនុវត្តជាលាយលក្ខណ៍អក្សរ នូវលទ្ធផលនៃការស្រាវជ្រាវអំពីស្ថានភាពបច្ចុប្បន្ននៃអចលនវត្ថុ និង ការវាយតម្លៃអចលនវត្ថុនោះ។[71]

យើងអាចនិយាយបានថា តុលាការអនុវត្ត នឹងជ្រើសតាំងអ្នកវាយតម្លៃ ដោយបង្គាប់អោយវាយតម្លៃលើអចលនវត្ថុហ៊ីប៉ូតែកនោះ ផ្អែកទៅលើការស្រាវជ្រាវអំពីសណ្ឋាននៃអចលនវត្ថុ ទំនាក់ទំនងនៃការកាន់កាប់ និងស្ថានភាពបច្ចុប្បន្នជាដើម។ នោះបន្ទាប់ពីទទួលបានបង្គាប់ពីតុលាការរួច អ្នកវាយតម្លៃត្រូវធ្វើការស្រាវជ្រាវដូចបានរៀបរាប់មុននេះ និងធ្វើការវាយតម្លៃអំពីចំនួនទឹកប្រាក់ និងចុងក្រោយត្រូវសរសេរចូលក្នុងរបាយការណ៍វាយតម្លៃ ហោយដាក់ទៅតុលាការអនុវត្ត។

**ង. ឯកសារលំអិតអំពីវត្ថុ, ដីកាសម្រេចកំណត់តម្លៃលក់អប្បបរមា និង ការបង្គាប់ឱ្យអនុវត្តការលក់**

ឯកសារលំអិតអំពីវត្ថុ និង ដីកាសម្រេចកំណត់តម្លៃលក់អប្បបរមា គឺមានចែងក្នុងមាត្រា ៤៣៤ ( ឯកសារលំអិតវត្ថុ) កថាខណ្ឌទី១ និង មាត្រា ៤៣២ (ដីកាសម្រេចកំណត់តម្លៃលក់អប្បបរមា ជាអាទិ៍) កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី។[72]

ដូចនោះ ដំណាក់កាលទី១៤ គឺតុលាការអនុវត្តត្រូវចាប់ផ្តើមធ្វើឯកសារលំអិតអំពីវត្ថុនោះផងដែរ។ ក្រោយពីទទួលបានរបាយការណ៍វាយតម្លៃលើអចលនវត្ថុហ៊ីប៉ូតែកនោះរួច តុលាការអនុវត្តត្រូវកំណត់តម្លៃលក់អប្បបរមាដោយផ្អែកលើរបាយការណ៍នោះ។ បន្ទាប់ពីអនុវត្តដំណាក់កាល១៤ និង ១៥បានអនុវត្តរួច នោះតុលាការអនុវត្ត នឹង

[71] មាត្រា ៤៣០ កថាខណ្ឌទី១ និង ទី៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[72] មាត្រា ៤៣៤ កថាខណ្ឌទី១ និង មាត្រា ៤៣២ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

កំណត់កាលបរិច្ឆេទ ព្រមទាំងទីកន្លែងលក់ ដោយបង្គាប់ឱ្យអាជ្ញាសាលាអនុវត្តការលក់នោះ ដោយយោងតាមមាត្រា ៤៣៦ កថាខណ្ឌទី៣។

**ច. ការប្រកាសជាសាធារណៈនូវកាលបរិច្ឆេទនៃការលក់ជាអាទិ៍ និង ការទុកឯកសារលំអិតអំពីវត្ថុជាអាទិ៍**

យោងតាមមាត្រា ៤៣៦ កថាខណ្ឌទី៤បានចែងថាក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ ខាងលើនេះ ក្រឡាបញ្ជីត្រូវផ្សាយជាសាធារណៈនូវសេចក្តីសង្ខេបនៃអចលនវត្ថុដែលបានត្រូវលក់ តម្លៃលក់អប្បបរមា ព្រមទាំងកាលបរិច្ឆេទ និង ទីកន្លែងលក់។[73]

ដោយជាគួនាទីបន្ទាប់ ក្រឡាបញ្ជីនឹងធ្វើការប្រកាសជាសាធារណៈនូវកាលបរិច្ឆេទនៃការលក់ ទីកន្លែង សញ្ញាណ និង តម្លៃលក់អប្បបរមានៃអចលនវត្ថុនោះ។ ចំណែកឯ ឯកសារលំអិតអំពីវត្ថុ និង ឯកសារចម្លងនៃរបាយការណ៍វាយតម្លៃត្រូវទុកនៅតុលាការអនុវត្ត។[74]

**ឆ. ការអនុវត្តការលក់ និង ការកំណត់កាលបរិច្ឆេទដើម្បីចេញដីកាសម្រេចការលក់**

ដូចនេះ ដំណាក់កាលទី១៩ គឺការអនុវត្តការលក់ដោយអាជ្ញាសាលា ដោយធ្វើការលក់ឡៃឡុងតាមរយៈស្រោមសំបុត្រក្តី ឬ ផ្ទាល់មាត់ក្តី នៅកាលបរិច្ឆេទនៃការលក់ ហើយប្រសិនបើមានជនណាមានបំណងទិញ ជននោះត្រូវដាក់ប្រាក់ធានាដូចបានកំណត់ រួចធ្វើសំណើទិញ។[75] ក្រោយមកទៀត អាជ្ញាសាលា នឹងប្រកាសនូវការបញ្ចប់កាលបរិច្ឆេទនៃការលក់ឡៃឡុងតាមវិធីដដែល បន្ទាប់ពីបានកំណត់អ្នកស្នើទិញ និង បានប្រកាសនូវនាម និង នាមករណ៍ ព្រមទាំងថ្លៃលក់ឡៃឡុងនោះរួច និង ចុងក្រោយអាជ្ញាសាលានឹងធ្វើកំណត់ហេតុនៃលក់នោះដាក់ទៅតុលាការអនុវត្តភ្លាម។[76]

ត្រង់ដំណាក់កាលទី២០ តុលាការអនុវត្ត នឹងជូនដំណឹងអំពីកាលបរិច្ឆេទនោះ ទៅជនដែលពាក់ព័ន្ធនឹងផលប្រយោជន៍ នៅក្រោយពេលដែលបានកំណត់អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា និង កាលបរិច្ឆេទដើម្បីចេញដីកាសម្រេចការលក់។[77]

[73] មាត្រា ៤៣៦ កថាខណ្ឌទី៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[74] មើលមាត្រា ៤៣៤ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[75] មើលមាត្រា ៤៣៧ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[76] មើលមាត្រា ៤៣៩ កថាខណ្ឌទី១ និង ទី៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[77] មើលមាត្រា ៤៤០ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

**ជ. ដីកាសម្រេចអនុញ្ញាតឱ្យលក់ ឬដីកាសម្រេចមិនអនុញ្ញាតឱ្យលក់**

យោងតាមមាត្រា៤៤០ កថាខណ្ឌទី១ បានចែងថា តុលាការអនុវត្តត្រូវបើកកាលបរិច្ឆេទដើម្បីចេញដីកាសម្រេចការលក់ ហើយត្រូវប្រកាសអំពីការអនុញ្ញាត ឬ មិនអនុញ្ញាតឱ្យលក់។[78]

ដូចនេះ យើងសង្កេតឃើញថា តុលាការអនុវត្ត គឺជាអ្នកបើកកាលបរិច្ឆេទដើម្បីចេញដីកាសម្រេចការលក់ និងជាអ្នកប្រកាសអំពីការអនុញ្ញាត ឬ មិនអនុញ្ញាតឱ្យលក់។

**ឈ. ការកំណត់ពេលនៃការបង់ថ្លៃលក់ និង ការបង់ថ្លៃលក់**

ការកំណត់ពេលនៃការបង់ថ្លៃលក់ គឺតុលាការអនុវត្តត្រូវកំណត់ឱ្យបានឆាប់រហ័សដោយស្ថិតក្នុងអំឡុងពេលមួយខែគិតចាប់ពីថ្ងៃដែលដីកាសម្រេចអនុញ្ញាតឱ្យលក់បានចូលជាស្ថាពរ ព្រមទាំងត្រូវជូនដំណឹងទៅអ្នកទិញផងដែរ។[79]

ចំពោះការបង់ថ្លៃវិញ គឺអ្នកទិញត្រូវបង់ថ្លៃលក់ដែលជាប្រាក់នៅសល់បន្ទាប់ពីដកប្រាក់ធានាចេញពីចំនួនប្រាក់នៃសំណើរទិញ ទៅឱ្យតុលាការអនុវត្តក្នុងពេលដែលបានកំណត់។[80]

**ញ. ការផ្ទុកផ្តាក់ឱ្យចុះបញ្ជី និង ការចុះបញ្ជីផ្អែកតាមការផ្ទុកផ្តាក់**

បន្ទាប់ពី អ្នកទិញបានបង់ថ្លៃលក់ហើយ ក្រឡាបញ្ជីនឹងផ្ទុកផ្តាក់ឱ្យរដ្ឋបាលសុរិយោដីចុះបញ្ជី។ មើលមាត្រា ៤៤៨ ដូចនេះ ដំណាក់កាលចុងក្រោយនៃការលក់ គឺមន្ត្រីចុះបញ្ជី នឹងធ្វើការចុះបញ្ជីផ្អែកតាមលិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជីនោះ។

**កថាភាគទី៣ ការចែកចំណែក**

បន្ទាប់ពីអនុវត្តនូវការរឹបអូស នឹង ការលក់រួចមក យើងនឹងសិក្សាទៅលើនីតិវិធីនៃការចែកចំណែកដូចខាងក្រោម។

**ក. ការកំណត់កាលបរិច្ឆេទនៃការចែកចំណែក**

យោងតាមមាត្រា ៤៨៨ កថាខណ្ឌទី១ ចំណុច គ បានចែងថា ក្នុងការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ ពេលដែលមានការបង់ថ្លៃលក់តាមបញ្ញត្តិនៃមាត្រា ៤៤៧ (ការបង់ថ្លៃលក់) ឬ ពេលដែលដីកាសម្រេចអនុញ្ញាតឱ្យលក់បានចូលជាស្ថាពរ នៅក្នុងករណីដែលមានការស្នើសុំ ដោយយោងតាមបញ្ញត្តិនៃវាក្យខណ្ឌទី១ កថាខណ្ឌទី៣ មាត្រា ៤៤៧ (ការបង់ថ្លៃលក់) នៃក្រមនេះ។[81]

[78] មាត្រា ៤៤០ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[79] មើលមាត្រា ៤៤៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[80] មើលមាត្រា ៤៤៧ កថាខណ្ឌទី១ និង ទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[81] មើលមាត្រា ៤៨៨ កថាខណ្ឌទី១ ចំណុច គ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

ដូចនេះ បន្ទាប់ពីមានការបង់ថ្លៃលក់ ឬ បន្ទាប់ពីពេលដែលដីកាសម្រេចអនុញ្ញាតឱ្យលក់បានចូលជាស្ថាពរចំពោះករណីដែលមានការស្នើសុំបង់តែចំនួនខ្វះ តុលាការអនុវត្តនឹងត្រូវកំណត់កាលបរិច្ឆេទនៃការចែកចំណែកនោះ។

### ខ. ការជូនដំណឹងអំពីកាលបរិច្ឆេទនៃការចែកចំណែក និងការដាស់តឿនឱ្យដាក់លិខិតគណនា ជាដើម

បន្ទាប់ពីបានកំណត់កាលបរិច្ឆេទនៃការចែកចំណែករួច ដំណាក់កាលទី២៧នេះ គឺតុលាការអនុវត្តនឹងធ្វើការជូនដំណឹងដូចតទៅ៖

- ការជូនដំណឹងអំពីទីកន្លែង និង កាលបរិច្ឆេទនៃការចែកចំណែក ទៅកាន់ម្ចាស់បំណុលនៃការអនុវត្តដែលទទួលការចែកចំណែកនោះ ព្រមទាំងទៅកាន់កូនបំណុលនៃការអនុវត្តផងដែរ យោងតាមមាត្រា ៤៨៨ កថាខណ្ឌទី១ ចំណុច គ។
- ការកោះហៅម្ចាស់បំណុលនៃការអនុវត្តដែលទទួលការចែកចំណែក និងកូនបំណុលនៃការអនុវត្ត យោងតាមមាត្រា ៤៩០ កថាខណ្ឌទី២ ចំណុច គ។

ក្រោយមកទើប ក្រឡាបញ្ជី ធ្វើការដាស់តឿនដល់ម្ចាស់បំណុលនៃការអនុវត្តដែលទទួលការចែកចំណែកឱ្យផ្តល់លិខិតគណនាអំពីប្រាក់ដើមនៃសិទ្ធិលើបំណុល ការប្រាក់រហូតដល់កាលបរិច្ឆេទនៃការចែកចំណែក ព្រមសោហ៊ុយសម្រាប់ការអនុវត្តទៅតុលាកាអនុវត្តក្នុងអំឡុងពេលមួយសប្តាហ៍។[82]

### គ. ការបង្កើតសេចក្តីព្រាងដើមនៃតារាងចែកចំណែក

ចំពោះដំណាក់កាលនេះ តុលាការអនុវត្ត នឹងបង្កើតសេចក្តីព្រាងដើមនៃតារាងចែកចំណែក ដែលជាឯកសារដែលមានសរសេរអំពីការគណនាចំណែកសម្រាប់ម្ចាស់បំណុលនីមួយៗ គឺតុលាការនឹងគណនាចំណែកសម្រាប់ម្ចាស់បំណុលទាំងអស់ ហើយក្រឡាបញ្ជីនឹងគណនានូវចំនួនទឹកប្រាក់នៃសោហ៊ុយសម្រាប់ការអនុវត្តមុនពេលកាលបរិច្ឆេទនៃការចែកចំណែក។

### ឃ. ការបើកកាលបរិច្ឆេទនៃការចែកចំណែក និង ការអនុវត្តការចែកចំណែក

ដូចនេះ ដំណាក់កាលចុងក្រោយនៃការចែកចំណែក គឺតុលាកាអនុវត្តនឹងបើកកាលបរិច្ឆេទនៃការចែកចំណែក ព្រមទាំងការអនុវត្តការចែកចំណែកផងដែរ។ ត្រង់ចំណុចនេះដែរ តុលាការអនុវត្ត នឹងធ្វើការចែកចំណែកតែផ្នែក

[82] មើលមាត្រា ៤៨៨ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

ដែលគ្មានការតវ៉ា ដោយផ្អែកលើតារាងចែកចំណែក។[83] ប៉ុន្តែបើមានមូលហេតុដូចចែងក្នុងមាត្រា ៤៩៤ តុលាការនឹងមិនធ្វើការចែកចំណែកនោះទេ តែនឹងធ្វើការផ្អាកទុកទឹកប្រាក់នោះសិន។

សរុបមក យើងសង្កេតឃើញថានីតិវិធីក្នុងការអនុវត្តហ៊ីប៉ូតែកគឺត្រូវបំពេញតាមដំណាក់កាលខាងលើទាំងអស់ដូចបានរៀបរាប់តាំងពី កថាភាគទី១ រហូតដល់ កថាភាគទី៣។ ហេតុដែលត្រូវបំពេញតាមដំណាក់កាលនីមួយៗ គឺដើម្បីភាពងាយស្រួលក្នុងការដោះស្រាយពេលមានការតតាំង និងដើម្បីទទួលបានការការពារពីរបបគតិយុត្ត។

[83] មើលមាត្រា ៤៩១ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

# ជំពូកទី៣

# ការរលត់នៃហ៊ីប៉ូតែក

# ជំពូកទី៣
# ការរលត់នៃហ៊ីប៉ូតែក

ការរលត់ទៅនៃហ៊ីប៉ូតែក អាចធ្វើតាមវិធីផ្សេងៗពីគ្នា ដោយអាស្រ័យទៅលើច្បាប់របស់ប្រទេសនោះ។ ជាក់ស្តែង តាមក្រមរដ្ឋប្បវេណីរបស់ជប៉ុន ការរលត់ហ៊ីប៉ូតែកអាចកើតចេញពីការសងដោយថ្លៃលក់ ដែលវាជានីតិវិធីមួយសម្រាប់សម្រួលដល់ការរលត់នៃហ៊ីប៉ូតែក ក្រៅពីនេះ គេក៏មានប្រព័ន្ធវិសុទ្ធកម្មដែរ តែដោយសារការអនុវត្តប្រព័ន្ធនេះផ្តល់ជាបន្ទុកខ្លាំងពេកទៅលើម្ចាស់បំណុលហ៊ីប៉ូតែក ទើបគេធ្វើវិសោធនកម្មច្បាប់នៅឆ្នាំ២០០៣ ដោយមកប្រើប្រព័ន្ធនៃការទាមទារអោយរលត់ហ៊ីប៉ូតែក ជំនួសវិសុទ្ធកម្មវិញ។[84]

ចំពោះប្រទេសកម្ពុជាវិញ ក្រមរដ្ឋប្បវេណី បានកំណត់នូវប្រព័ន្ធនៃការសងដោយថ្លៃលក់តែមួយគត់នៃការទាមទារអោយរលត់ហ៊ីប៉ូតែក តែ តតិតយជន និង ម្ចាស់បំណុលដែលបានធ្វើលទ្ធកម្មលើអចលនវត្ថុដែលបានដាក់ហ៊ីប៉ូតែក ក៏អាចរំលត់ហ៊ីប៉ូតែកដោយសេរី តាមរយៈការព្រមព្រៀង ឯកភាពគ្នាបានដែរ។[85]

## ផ្នែកទី១ ការរលត់ដោយការទាមទារ

ការរលត់ដោយការទាមទារ សំដៅទៅលើការសងដោយថ្លៃលក់ពីតតិយជនដែលធ្វើលទ្ធកម្មលើអចលនវត្ថុហ៊ីប៉ូតែកអោយទៅម្ចាស់បំណុលហ៊ីប៉ូតែក តាមរយៈការទាមទាររបស់ម្ចាស់បំណុលហ៊ីប៉ូតែក។ ដោយយោងតាមមាត្រា ៨៦៤ នៃក្រមរដ្ឋប្បវេណី បានកំណត់ថា ហ៊ីប៉ូតែកនឹងត្រូវរលត់ ប្រសិនបើតតិយជនដែលបានទិញកម្មសិទ្ធិ មានសិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគចំពោះអចលនវត្ថុហ៊ីប៉ូតែក សងថ្លៃលក់អចលនវត្ថុដែលខ្លួនត្រូវបង់ ដើម្បីធ្វើលទ្ធកម្មអចលនវត្ថុនោះតាមការទាមទាររបស់ម្ចាស់បំណុលហ៊ីប៉ូតែក ដូចនេះហ៊ីប៉ូតែកនឹងត្រូវបានរលត់។[86] ក្រៅពីនេះ ម្ចាស់បំណុលហ៊ីប៉ូតែក ក៏អាចធ្វើការតតាំងហ៊ីប៉ូតែកជាមួយតតិយជននេះបានដែរ ករណីបើបានចុះបញ្ជីហ៊ីប៉ូតែកនោះ ដូចនេះម្ចាស់បំណុលហ៊ីប៉ូតែកមិនចាំបាច់ធ្វើការទាមទារជានិច្ចនេះទេ មានន័យថា គេអាចទាមទារអោយសងថ្លៃលក់ នៅពេលណាដែលគេយល់ថា អាចប្រមូលសិទ្ធិលើបំណុលរបស់ខ្លួនបាន។[87]

ចំពោះហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ក៏ត្រូវបានក្រមរដ្ឋប្បវេណីចែងពិសេស ពីការទាមទារអោយរំលត់ហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតផងដែរ។ យោងតាមមាត្រា ៨៨៧ បានចែងកំណត់ថា បើចំនួននៃ

[84] ដកស្រង់ចេញពីការសេចក្តីកំណត់មាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគទី៤: គន្ថីទី៦, ជំពូកទី៥: ផ្នែកទី៦

[85] ដកស្រង់ចេញពីការសេចក្តីកំណត់មាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគទី៤: គន្ថីទី៦, ជំពូកទី៥: ផ្នែកទី៦

[86] មើលមាត្រា ៨៦៤ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[87] ដកស្រង់ចេញពីការសេចក្តីកំណត់មាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគទី៤: គន្ថីទី៦, ជំពូកទី៥: ផ្នែកទី៦: កថាភាគទី១

កាតព្វកិច្ចនៅក្រោយពេលប្រាក់ដើមត្រូវបានកំណត់ជាស្ថាពរ លើសពីចំនួនអតិបរមានៃហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត អ្នកដែលបានធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើអចលនវត្ថុដែលបានបង្កើតហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ឬ តតិយជនដែលបានធ្វើលទ្ធកម្មនូវសិទ្ធិជួលអចិន្ត្រៃយ៍ ឬ សិទ្ធិជួលដែលអាចតតាំងជាមួយនឹងតតិយជនចំពោះអចលនវត្ថុហ៊ីប៉ូតែក អាចទាមទារអោយរំលត់ហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតនោះបានដោយបង់ប្រាក់ដែលស្មើនឹងចំនួនអតិបរមា ឬ ដោយតម្កល់ប្រាក់នោះជាដើម។[88]

លើសពីនេះ ហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតដែលមានការចុះបញ្ជីដែលបានកំណត់នៅក្នុងមាត្រា ៨៨១ (ហ៊ីប៉ូតែករួមដើម្បីធានាបំណុលអណ្តែត) នៃក្រមរដ្ឋប្បវេណី ត្រូវបានរលត់នៅពេលដែលមានការទាមទារដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ៨៨៧ ចំពោះអចលនវត្ថុមួយផងដែរ។

ចំពោះ កូនបំណុលដែលមានកាតព្វកិច្ចចម្បង អ្នកធានា និង ប្រតិសិទ្ធិ មិនអនុញ្ញាតអោយធ្វើការទាមទារអោយរំលត់ហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតទេ ពីព្រោះ បុគ្គលទាំងនេះមានជាប់ករណីយកិច្ចក្នុងការសងកាតព្វកិច្ច។ ក្រៅពីនេះ កថាខណ្ឌទី ៣ នៃមាត្រា ៨៨៧ បានកំណត់ថាតតិយជនដែលបានធ្វើលទ្ធកម្មនូវកម្មសិទ្ធិ ឬ សិទ្ធិផ្សេងទៀត ដោយភ្ជាប់នឹងល័ក្ខខ័ណ្ឌបង្អង់ មិនអាចធ្វើការទាមទារអោយរំលត់ នៅក្នុងពេលដែលពុំដឹងថាល័ក្ខខ័ណ្ឌនោះត្រូវបានបំពេញ ឬមិនទាន់បានបំពេញ។[89]

## ផ្នែកទី២. ការរលត់ដោយអាជ្ញាយុកាល

យោងតាមមាត្រា ៨៦៥ នៃក្រមរដ្ឋប្បវេណី បានកំណត់ថា ប្រសិនបើសិទ្ធិលើបំណុលត្រូវបានធានាដោយហ៊ីប៉ូតែកនោះមិនបានរលត់ព្រមគ្នាទេ នោះហ៊ីប៉ូតែកមិនរលត់ដោយអាជ្ញាយុកាល ចំពោះកូនបំណុល និងអ្នកដែលបានបង្កើតហ៊ីប៉ូតែកឡើយ។[90] មាត្រានេះបាន បញ្ជាក់ចំពោះអាជ្ញាយុកាលនៃការរំលត់ហ៊ីប៉ូតែក គឺហ៊ីប៉ូតែកមិនត្រូវបានរលត់ដោយអាជ្ញាយុកាល ឬការឯករាជ្យពីសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែកនោះឡើយ ពោលគឺ ទោះបីម្ចាស់បំណុលបានធ្វើ ឬមិនបានធ្វើនីតិវិធីផ្អាកអាជ្ញាយុកាលចំពោះហ៊ីប៉ូតែកក្តី ក៏ហ៊ីប៉ូតែកមិនត្រូវបានរលត់ឡើយ។ យ៉ាងណាមិញ មាត្រានេះមានអត្ថប្រយោជន៍ ចំពោះករណីដែលកូនបំណុលនៃសិទ្ធិលើបំណុលដែលត្រូវបានធានា មិនដូចគ្នានឹងអ្នកដែលទទួលបន្ទុកនូវហ៊ីប៉ូតែក គឺម្ចាស់បំណុលហ៊ីប៉ូតែកគ្រាន់តែធ្វើនីតិវិធីផ្អាកអាជ្ញាយុកាល ចំពោះកូនបំណុលនៃសិទ្ធិលើបំណុលដែលត្រូវបានធានាទៅបានហើយ។

ក្រៅពីមាត្រា ៨៦៥ ក្រមរដ្ឋប្បវេណីក៏មានចែងនូវ មាត្រាផ្សេងមួយទៀតដែរ គឺការរលត់ហ៊ីប៉ូតែកដោយលទ្ធកម្មនូវអចលនវត្ថុហ៊ីប៉ូតែកដោយអាជ្ញាយុកាល។ យោងតាមមាត្រា ៨៦៦ បានចែងថា ហ៊ីប៉ូតែកនឹងត្រូវ

[88] ដកស្រង់ចេញពីការសេចក្តីកំណត់មាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគទី៤: គន្ថីទី៦, ជំពូកទី៥: ផ្នែកទី៧

[89] មើលមាត្រា ៨៨៧ ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[90] មើលមាត្រា ៨៦៥ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

រលត់ នៅពេលដែលបុគ្គលក្រៅពីកូនបំណុល ឬក្រៅពីអ្នកដែលបានបង្កើតហ៊ីប៉ូតែក បានកាន់កាប់អចលនវត្ថុហ៊ីប៉ូតែក ដោយមានល័ក្ខខ័ណ្ឌចាំបាច់សម្រាប់អាជ្ញាយុកាលនៃការទទួលសិទ្ធិ ហើយមាត្រានេះ នឹងមិនត្រូវយកមកអនុវត្តឡើយ ប្រសិនបើតតិយជនដែលបានធ្វើលទ្ធកម្មលើអចលនវត្ថុហ៊ីប៉ូតែក បានដឹងនៅពេលដែលខ្លួនបានធ្វើលទ្ធកម្មរួច។[91]

មូលហេតុនៃការបង្កើតមាត្រានេះឡើង គឺដោយសារលទ្ធកម្មនៃកម្មសិទ្ធិដោយអាជ្ញាយុកាល គឺមិនមែនជាលទ្ធកម្មបន្តនោះទេ តែវាជាលទ្ធកម្មកម្មសិទ្ធិដំបូង ពោលគឺកម្មសិទ្ធិពេញលេញដោយគ្មានបន្ទុក តែប្រសិនបើគេអនុវត្តលទ្ធកម្មបន្ត នោះមានន័យថាគេអនុវត្តលើកម្មសិទ្ធិដែលមានបន្ទុកហ៊ីប៉ូតែក មិនកម្មសិទ្ធិពេញលេញដោយគ្មានបន្ទុកនោះទេ និង ដោយសារហ៊ីប៉ូតែក គឺជាសិទ្ធិប្រត្យក្ស ដែលគេអាចយកមកតតាំងចំពោះតតិយជននៅពេលចុះបញ្ជី ដែលម្ចាស់បំណុលនៅតែអាចអះអាងហ៊ីប៉ូតែករបស់ខ្លួនបាន ចំពោះអ្នកទិញអចលនវត្ថុដែលបានដាក់ហ៊ីប៉ូតែក ទោះបីអ្នកទិញនោះមិនដឹងពីអត្ថិភាពនៃហ៊ីប៉ូតែកក៏ដោយ។

ដូចនេះ យើងមើលឃើញថា ការរលត់នៃហ៊ីប៉ូតែក គឺមានល័ក្ខខណ្ឌដូចគ្នា ទីមួយដោយការទាមទារ និងទីពីរដោយការរលត់នូវសិទ្ធិលើបំណុលព្រមគ្នា។

[91] មើលមាត្រា ៨៦៦ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

# សេចក្ដីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

បន្ទាប់ពីបានធ្វើការសិក្សាបកស្រាយយ៉ាងក្បោះក្បាយ ទៅលើប្រធានបទនៃសារណានេះដែលបានលើកយកមកសិក្សាទាំងហ៊ីប៉ូតែកធម្មតា និងហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតខាងលើនេះហើយ យើងសង្កេតឃើញថា ហ៊ីប៉ូតែកទាំងពីរប្រភេទនេះ ពិតជាមានសារៈសំខាន់ និងតម្លៃដូចគ្នារៀងខ្លួន។ ទាំងហ៊ីប៉ូតែកធម្មតា និងហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត បានបង្ហាញអោយឃើញថា វាគឺជាវិធីសាស្ត្រមួយដ៏ប្រសើរ ដែលមនុស្សអាចយកវាទៅប្រើប្រាស់ក្នុងវិស័យពាណិជ្ជកិច្ច ដូចជាការពង្រីកអាជីវកម្ម ជួញដូរជំនួញ ការខ្ចីឥណទានជាដើម និងការយល់ដឹងទៅលើផ្នែករដ្ឋប្បវេណី ដូចជា កាតព្វកិច្ច និងការទទួលខុសត្រូវនានា របស់អ្នកបង្កើតហ៊ីប៉ូតែក និង ម្ចាស់ហ៊ីប៉ូតែក ផងដែរ។

តាមរយៈការស្វែងយល់នៃប្រធានបទនេះ ក្រុមនាងខ្ញុំសង្កេតឃើញថែមទៀតថា មិនមែនរាល់អចលនវត្ថុទាំងអស់សុទ្ធតែអាចចុះបញ្ជីហ៊ីប៉ូតែកបាននោះទេ ដែលក្នុងនេះបានបញ្ជាក់យ៉ាងច្បាស់ថា ទាល់តែអចលនវត្ថុដែលបានចុះបញ្ជីស្របច្បាប់ ចេញដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងបានបំពេញនីតិវិធីចុះបញ្ជីហ៊ីប៉ូតែកទើបអាចអនុវត្តហ៊ីប៉ូតែក និងអាចតតាំងជាមួយតតិយជនបាន។ ដោយសារការចុះបញ្ជីនេះហើយ ទើបបង្ហាញអោយកាន់តែច្បាស់ទៀតថា ការដាក់ធានាកាតព្វកិច្ច តាមរយៈសិទ្ធិប្រាតិភោគប្រត្យក្សមួយនេះ មានលក្ខណៈជាបទដ្ឋានគតិយុត្ត ដែលមានបង្កើតនូវចំណងគតិយុត្តរវាងអ្នកបង្កើតហ៊ីប៉ូតែក និងម្ចាស់បំណុលហ៊ីប៉ូតែក ដែលនាំអោយមានភាពងាយស្រួលដល់ដំណើរការនៃការតតាំងរវាងគូភាគី ឬតតិយជនដែលបានធ្វើលទ្ធកម្មលើអចលនវត្ថុហ៊ីប៉ូតែកនោះ។ អ្វីដែលកាន់តែពិសេសពីការសិក្សាលើប្រធានបទសារណាមួយនេះ គឺបានឆ្លុះបញ្ចាំងអោយយើងបានឃើញ និងស្វែងយល់ទៅលើការអនុវត្តច្បាប់ យុត្តសាស្ត្រ និងការប្រព្រឹត្តទៅនៃការចុះបញ្ជីហ៊ីប៉ូតែកជាដើម ដែលការណ៍នេះ បច្ចុប្បន្នប្រជាពលរដ្ឋភាគច្រើនពុំទាន់បានដឹង និងយល់ច្បាស់នៅឡើយទៅលើ អ្វីជាហ៊ីប៉ូតែក ហើយការអនុវត្តហ៊ីប៉ូតែកនេះមានល័ក្ខខ័ណ្ឌបែបណាខ្លះ ផ្ទុយទៅវិញឃើញថាប្រជាជនទូទៅបានប្រើប្រាស់វាយ៉ាងទូលំទូលាយ លើកត្តានានា ជាក់ស្តែង ការជឿទំនិញជាប្រចាំរវាងអ្នកជំនួញ ការខ្ចីឥណទានពីធនាគារ ឬ មីក្រូហិរញ្ញវត្ថុជាដើម ។

ជារួមយើងឃើញថា ហ៊ីប៉ូតែក គឺជាសិទ្ធិប្រាតិភោគប្រត្យក្សមួយដែលបានផ្តល់ផលប្រយោជន៍ទៅដល់គូភាគីទាំងសងខាងនៅក្នុងកិច្ចសន្យា ទាំងម្ចាស់បំណុល និង កូនបំណុល។ សម្រាប់កិច្ចគតិយុត្តពាក់ពន្ធ័នឹងការចុះបញ្ជីបង្កើតសិទ្ធិ ក៏ដូចជា ដំណើរការនៃ ការអនុវត្ត ការចាត់ចែង ការលត់ ព្រមទាំង អានុភាពនៃហ៊ីប៉ូតែក ទាំងហ៊ីប៉ូតែកធម្មតា និងហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត សុទ្ធសឹងជាគោលការណ៍ ដែលមានចែងនៅក្នុងបញ្ញត្តិច្បាប់របស់កម្ពុជា ដែលតម្រូវឲ្យបុគ្គលដែលមានកាតព្វកិច្ចក្នុងការអនុវត្ត ត្រូវតែបំពេញនូវកិច្ចគតិយុត្តខាងលើឲ្យបានពេញលេញ និង ត្រឹមត្រូវ ទើបអាចធានាបាននូវការការពារសិទ្ធិរបស់ខ្លួនស្របតាមវិធានច្បាប់បាន។

# អនុសាសន៍

# អនុសាសន៍

ក្រុមនាងខ្ញុំបានមើលឃើញពីវឌ្ឍនភាពនៃការដាក់ធានាកាតព្វកិច្ចតាមរយៈហ៊ីប៉ូតែកនេះ និងដើម្បីចូលរួមជាចំណែកមួយក្នុងការជម្រុញអោយការអនុវត្ត និងប្រព្រឹត្តទៅនៃហ៊ីប៉ូតែកអោយកាន់តែមានប្រសិទ្ធិភាព និងភាពរីកចម្រើនលើសពីនេះ យើងខ្ញុំទាំងពីរសូមចូលរួមជាមួយនឹងគំនិតបន្តិចបន្តួចជាយោបល់ ដោយសូមសំណូមពរទៅដល់រាជរដ្ឋាភិបាល និងសមត្ថកិច្ចពាក់ព័ន្ធនៃព្រះរាជាណាចក្រកម្ពុជាដូចតទៅៈ

១. ធានាអោយបាននូវការចុះបញ្ជីហ៊ីប៉ូតែកទាំងអស់ប្រកបដោយប្រសិទ្ធិភាព ដើម្បីធានាដល់ការពាររបបគតិយុត្តអោយកាន់តែរឹងមាំ

២. ធានាអោយបាននូវការត្រួតពិនិត្យនូវការចុះបញ្ជីហ៊ីប៉ូតែកទាំងអស់ប្រកបដោយភាពត្រឹមត្រូវ ស្របតាមច្បាប់ ដើម្បីអោយការអនុវត្តហ៊ីប៉ូតែកមានលក្ខណៈត្រឹមត្រូវស្របតាមច្បាប់

៣. ធានាអោយបាននូវការដោះស្រាយពីសមត្ថកិច្ចពាក់ព័ន្ធនៅពេលមានការតតាំង ដើម្បីធានាដល់តម្លាភាព ការលុបបំបាត់ការកេងប្រវ័ញ្ច ការបំពានដោយអំណាច បក្សពួកនិយម និងអំពើពុករលួយគ្រប់រូបភាព ដែលអាចប៉ះពាល់ដល់ប្រសិទ្ធិភាពនៃការអនុវត្តច្បាប់ និងអាចអោយសាធារណៈជនអស់ជំនឿលើច្បាប់

៤. បង្កើតវគ្គបណ្តុះបណ្តាលខ្លី ឬ តាមរយៈវីដេអូអប់រំខ្លីៗ ដែលអាចចាក់ផ្សាយតាមរយៈទូរទស្សន៍ជាដើម ដើម្បីអោយសាធារណៈជនបានយល់ដឹងពីនីតិវិធី ក៏ដូចជាដំណើរការនៃ ការចុះបញ្ជីហ៊ីប៉ូតែកអោយបានត្រឹមត្រូវ និងបានដឹងថាស្ថាប័នណាជាអ្នកមានសមត្ថកិច្ចទាក់ទងនឹងនីតិវិធីនេះ។

យើងខ្ញុំទាំងពីរសង្ឃឹមថា សំណូមពរទាំងបួនខាងលើនេះនឹងអាចជួយដល់ការអនុវត្ត និងប្រព្រឹត្តិទៅនៃការដាក់ធានាកាតព្វកិច្ចតាមរយៈហ៊ីប៉ូតែកនៅក្នុងប្រទេសកម្ពុជា យើងកាន់តែល្អប្រសើរ នឹងមានប្រសិទ្ធិភាពលើសពីនេះទៀត ពីព្រោះវានឹងផ្តល់ជាប្រយោជន៍ដល់ការអភិវឌ្ឍកាន់តែខ្លាំងជាងនេះនាពេលអនាគត ហើយក្រុមនាងខ្ញុំក៏សង្ឃឹមថាសំណូមពរទាំងនេះនឹងត្រូវបានយកទៅពិចារណា និងត្រួតពិនិត្យដោយអាជ្ញាធរពាក់ព័ន្ធទាំងអស់ផងដែរ។

# ឯកសារយោង

## ឯកសារយោង

### ក. ច្បាប់ និង លិខិតបទដ្ឋានគតិយុត្ត

- ក្រមរដ្ឋប្បវេណីចាស់ ឆ្នាំ ១៩២០
- ច្បាប់ភូមិបាល ឆ្នាំ ២០០១
- ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦
- ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧
- ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ឆ្នាំ ២០១១
- សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ ៤: គន្ថីទី៦
- **អនុក្រឹត្យ**
    - អនុក្រឹត្យលេខ ៣៩.អនក្រ.បក ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១១ ស្តីពីការគ្រប់គ្រងបុរី
    - អនុក្រឹត្យលេខ១៨ អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតយន្តការច្រកចេញចូលតែមួយសម្រាប់ការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- **ប្រកាស**
    - ប្រកាសអន្តរក្រសួងលេខ ៥៩ ប្រក/ដនស./១១ ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១១ ស្តីពីការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណី
    - ប្រកាសអន្តរក្រសួងលេខ ៣០ កយ.ដនស.ប្រក/១៣ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៣ ស្តីពីការចុះបញ្ជីអអំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី
    - ប្រកាសអន្តរក្រសួងលេខ ១៥៩ ប្រក/ដនស./មផ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលប្រការ ៩ នៃប្រកាសអន្តរក្រសួងលេខ ២១៥ ប្រក/ដនស.មផ ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០៥ ស្តីពីតួនាទី និងការទទួលខុសត្រូវរបស់រដ្ឋបាលឃុំ សង្កាត់ ក្នុងការចុះបញ្ជីដីធ្លី
    - ប្រកាសស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីឆ្នាំ២០១១
- **លិខិតបទដ្ឋានគតិយុត្តផ្សេងទៀត**
    - សទ្ទានុក្រមពាក្យច្បាប់ ខ្មែរ~អង់គ្លេស~បារាំង រដ្ឋប្បវេណី និង នីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៧
    - សេចក្តីណែនាំលេខ ០២ ដនស/សជ ចុះថ្ងៃទី ២៨ ខែឧសភា ឆ្នាំ២០០៤ ស្តីពីការចុះបញ្ជីដីបន្ត
    - សេចក្តីជម្រាបរបស់ក្រសួងដែនដី នគរូនីយកម្ម និងសំណង់ លេខ១៨៩៧ដនស/អរប ចុះថ្ងៃទី ០៧ សីហា ២០១៨ ជូនដល់ប្រធានមន្ទីរដែនដី នគរូនីយកម្ម និងសំណង់ រាជធានីខេត្ត

### ខ. ប្រភពពីឯកសារ

▪ សាស្ត្រាចារ្យ Urakawa Michitaro , សិក្ខាសិលាស្ដីពី ការធានាកាតព្វកិច្ច មាន១៨ទំព័រ
▪ មេធាវី អ៊ីវ ប៉ូលី «សិទ្ធិប្រាតិភោគប្រត្យក្ស» ដោយគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ,មជ្ឈមណ្ឌលបណ្ដុះបណ្ដាលវិជ្ជាជីវៈមេធាវី ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ ,៥០ទំព័រ

**គ. ប្រភពពីគេហទំព័រ**

▪ SHIMANUKI Masaoជំនាញការ JICA, នីតិវិធីនៃការអនុវត្តហ៊ីប៉ូតែក, (ថ្ងៃទី៦-២៧ ខែ ឧសភា ឆ្នាំ ២០១៦)ដកស្រង់ពី៖ នីតិវិធីនៃការអនុវត្តហ៊ីប៉ូតែក-1.pdf (ggi.law) ,០៧ កក្កដា ២០២១
▪ ម៉ៅ សិលា, "ជំនួយស្មារតី៖ និយមន័យ និងការចុះបញ្ជីហ៊ីប៉ូតែកនៅកម្ពុជា",ការផ្សព្វផ្សាយរបស់សមាគមសាលាត្រាជូ, (ខែមករា ឆ្នាំ២០១៨), ដកស្រង់ពី៖ http://salatraju.com/post/349 , ០៧ កក្កដា ២០២១
▪ មេធាវីអ៊ីវ ប៉ូលី, «ហ៊ីប៉ូតែក និងកំជាប់ពាក្យ» ព្រឹត្តិបត្រមេធាវីលេខ១៣ មេសា-មិថុនាឆ្នាំ២០១៧ , https://www.bakc.org.kh/images/Bulletin ,៣៧ទំព័រ ,០៧ កក្កដា ២០២១

# ឧបសម្ព័ន្ធ

# បញ្ជីឧបសម្ព័ន្ធ

**ឧបសម្ព័ន្ធ១** **រូបភាព**

ឧបសម្ព័ន្ធ១.ក វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុ

ឧបសម្ព័ន្ធ១.ខ បណ្ណ័សំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ

ឧបសម្ព័ន្ធ១.គ បណ្ណ័សំគាល់សិទ្ធិកាន់កាប់ និងប្រើប្រាស់ដីធ្លី

ឧបសម្ព័ន្ធ១.ឃ វិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុ ឬប្លង់សំណាង់

ឧបសម្ព័ន្ធ១.ង វិញ្ញាបនប័ត្រសម្គាល់ម្ចាស់ចំណែកឯកជន

ឧបសម្ព័ន្ធ១.ច វិញ្ញាបនប័ត្រសំគាល់សិទ្ធិជួលរយៈពេលវែង

ឧបសម្ព័ន្ធ១.ឆ វិញ្ញាបនប័ត្រសម្គាល់កម្មសិទ្ធិសមូហភាព

ឧបសម្ព័ន្ធ១.ជ បង្កាន់ដៃទទួលពាក្យបង្កើតហ៊ីប៉ូតែក និង បង្កាន់ដៃបង់ប្រាក់

**ឧបសម្ព័ន្ធ២** **គំរូឯកសារ**

ឧបសម្ព័ន្ធ២.ក កិច្ចសន្យាបង្កើតហ៊ីប៉ូតែក

ឧបសម្ព័ន្ធ២.ខ ពាក្យសុំចុះបញ្ជីអំពីការបង្កើតហ៊ីប៉ូតែក

ឧបសម្ព័ន្ធ២.គ ពាក្យសុំចុះបញ្ជីអំពីការបង្កើតហ៊ីប៉ូតែករួម

ឧបសម្ព័ន្ធ២.ឃ ពាក្យសុំចុះបញ្ជីអំពីការបង្កើតហ៊ីប៉ូតែកបន្ត

ឧបសម្ព័ន្ធ២.ង ពាក្យសុំចុះបញ្ជីអំពីការផ្ទេរហ៊ីប៉ូតែក

ឧបសម្ព័ន្ធ២.ច ពាក្យសុំចុះបញ្ជីអំពីឧបាទេសកម្មហ៊ីប៉ូតែករួម

ឧបសម្ព័ន្ធ២.ឆ ពាក្យសុំចុះបញ្ជីអំពីអនុប្បទានហ៊ីប៉ូតែក

ឧបសម្ព័ន្ធ២.ជ ពាក្យសុំចុះបញ្ជីអំពីការបោះបង់ហ៊ីប៉ូតែក

ឧបសម្ព័ន្ធ២.ឈ ពាក្យសុំចុះបញ្ជីអំពីអនុប្បទានលំដាប់ហ៊ីប៉ូតែក

ឧបសម្ព័ន្ធ២.ញ ពាក្យសុំចុះបញ្ជីអំពីការបោះបង់លំដាប់ហ៊ីប៉ូតែក

ឧបសម្ព័ន្ធ២.ដ ពាក្យសុំចុះបញ្ជីអំពីការផ្លាស់ប្តូរលំដាប់ហ៊ីប៉ូតែក

| | |
|---|---|
| ឧបសម្ព័ន្ធ២.ឋ | ពាក្យសុំចុះបញ្ជីអំពីការផ្លាស់ប្តូរ ឬការកែតម្រូវហ៊ីប៉ូតែក |
| ឧបសម្ព័ន្ធ២.ឌ | ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីអំពីហ៊ីប៉ូតែក |
| ឧបសម្ព័ន្ធ២.ឍ | ពាក្យសុំចុះបញ្ជីអំពីការបង្កើតហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត |
| ឧបសម្ព័ន្ធ២.ណ | ពាក្យសុំចុះបញ្ជីអំពីការបង្កើតហ៊ីប៉ូតែករួមដើម្បីធានាបំណុលអណ្តែត |
| ឧបសម្ព័ន្ធ២.ត | ពាក្យសុំចុះបញ្ជីអំពីការផ្ទេរហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត |
| ឧបសម្ព័ន្ធ២.ថ | ពាក្យសុំចុះបញ្ជីអំពីការបែងចែកនិងអនុប្បទានហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត |
| ឧបសម្ព័ន្ធ២.ទ | ពាក្យសុំចុះបញ្ជីអំពីការផ្លាស់ប្តូរចំនួនទឹកប្រាក់អតិបរមាទាក់ទងនឹងហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត |
| ឧបសម្ព័ន្ធ២.ធ | ពាក្យសុំចុះបញ្ជីអំពីការផ្លាស់ប្តូរទំហំសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត |
| ឧបសម្ព័ន្ធ២.ន | ពាក្យសុំចុះបញ្ជីអំពីការផ្លាស់ប្តូរកាលបរិច្ឆេទដែលប្រាក់ដើមត្រូវបានកំណត់ជាស្ថាពរនៃហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត |
| ឧបសម្ព័ន្ធ២.ប | ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីអំពីហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត |
| **ឧបសម្ព័ន្ធ៣** | **ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធ** |
| ឧបសម្ព័ន្ធ៣.ក | ប្រកាសអន្តរក្រសួងលេខ ១៥៩ ប្រក/ដនស/មផ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលប្រការ ៩ នៃប្រកាសអន្តរក្រសួងលេខ ២១៥ ប្រក/ដនស.មផ ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០៥ ស្តីពីតួនាទី និងការទទួលខុសត្រូវរបស់រដ្ឋបាលឃុំ សង្កាត់ ក្នុងការចុះបញ្ជីដីធ្លី |
| ឧបសម្ព័ន្ធ៣.ខ | អនុក្រឹត្យលេខ១៨ អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតយន្តការច្រកចេញចូលតែមួយសម្រាប់ការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ |
| ឧបសម្ព័ន្ធ៣.គ | សេចក្តីជម្រាបរបស់ក្រសួងដែនដី នគរូនីយកម្ម និងសំណង់ លេខ១៨៩៧ដនស/អរប ចុះថ្ងៃទី ០៧ សីហា ២០១៨ ជូនដល់ប្រធានមន្ទីរដែនដី នគរូនីយកម្ម និងសំណង់ រាជធានីខេត្ត |

# ឧបសម្ព័ន្ធ១

## រូបភាព

# ឧបសម្ព័ន្ធ១.ក

វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុ

1. ឈ្មោះហៅក្រៅ ប្លង់ L-MAP (ខាងមុខ និងខាងក្រោយ)



## ឧបសម្ព័ន្ធ១.ខ

បណ្ណ័សំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ

## 2- ឈ្មោះហៅក្រៅ ប្លង់ដាច់ដោយដុំ (ខាងមុខ)




## 2- ឈ្មោះហៅក្រៅ ប្លង់ដាច់ដោយដុំ (ខាងក្រោយ)



# ឧបសម្ព័ន្ធ១.គ

បណ្ណសំគាល់សិទ្ធិកាន់កាប់ និងប្រើប្រាស់ដីធ្លី

## 3- ឈ្មោះហៅក្រៅ ប្លង់ស្លាបមាន់ (ខាងមុខ)


បណ្ណសំគាល់សិទ្ធិ
កាន់កាប់ប្រើប្រាស់ដីធ្លី

## 3- ឈ្មោះហៅក្រៅ ប្លង់ស្លាបមាន់ (ខាងក្រោយ)



# ឧបសម្ព័ន្ធ១.ឃ

វិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុ ឬប្លង់សំណាង

## 4- ឈ្មោះហៅក្រៅ ប្លង់សំណាង (ខាងមុខ)




## 4- ឈ្មោះហៅក្រៅ ប្លង់សំណាង (ខាងក្រោយ)



## **ឧបសម្ព័ន្ធ១.ខ**

វិញ្ញាបនប័ត្រសម្គាល់ម្ចាស់ចំណែកឯកជន

# 5- ឈ្មោះហៅក្រៅ ប្លង់ចំណែកឯកជន (ខាងមុខ និងក្រោយ)



**ឧបសម្ព័ន្ធ១.ច**

វិញ្ញាបនប័ត្រសំគាល់សិទ្ធិជួលរយៈពេលវែង

# 6- ឈ្មោះហៅក្រៅ ប្លង់ជួលរយៈពេលវែង (ខាងមុខ និងក្រោយ)



វិញ្ញាបនប័ត្រសំគាល់សិទ្ធិជួលរយៈពេលវែង

22 NOV 2012

No. 0460913



## ឧបសម្ព័ន្ធ១.ឥ

វិញ្ញាបនប័ត្រសម្គាល់កម្មសិទ្ធិសមូហភាព

# 9. ឈ្មោះហៅក្រៅ ប្លង់សហកម្មសិទ្ធ (ខាងមុខ និងក្រោយ)






# ឧបសម្ព័ន្ធ១.៩

## បង្កាន់ដៃទទួលពាក្យបង្កើតហ៊ីប៉ូតែក និង បង្កាន់ដៃបង់ប្រាក់



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលរាជធានីភ្នំពេញ
អង្គភាពច្រកចេញចូលតែមួយ

**បង្កាន់ដៃទទួលពាក្យ**

បានទទួលពាក្យស្នើសុំ ពីឈ្មោះ ៖ ហែម ស្រីទូច
អាសយដ្ឋាន ៖
លេខទូរស័ព្ទ ៖ 069593265 ☑ម្ចាស់ ☐អ្នកតំណាង
កម្មវត្ថុស្នើសុំសេវា ៖ បង្កើតហ៊ីប៉ូតែក( 2574,ចោមចៅ ពោធិ៍សែនជ័យ)
កាលបរិច្ឆេទទទួលពាក្យស្នើសុំ ៖ 29/04/2020
កាលបរិច្ឆេទមកទទួលអាជ្ញាប័ណ្ណ ឬ លិខិតអនុញ្ញាត ៖
លេខទូរស័ព្ទបុគ្គលិកទទួលប្រគល់ឯកសារ ៖
098 545 704

បុគ្គលិកទទួលប្រគល់ឯកសារ
ពិសី

លេខទូរស័ព្ទសម្រាប់ការប្ដឹងតវ៉ានានា៖
855(12) 798 983 / 858 511 / 833 775



គំរូលេខ ០១ សហវ/ខមព

280-1-00081558

MEF19000083505

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
អង្គភាព ច្រកចេញចូលតែមួយ

**បង្កាន់ដៃបង់ប្រាក់**

(ប្រគល់ជូនអ្នកបង់ប្រាក់)

ទទួលពី ............ អង្គភាព ............
ចំនួនទឹកប្រាក់ជាលេខ 200,000
ជាអក្សរ ............
អត្ថន័យចំណូល ............ មាតិកាថវិកា ............
ថ្ងៃទី 29 ខែ 4 ឆ្នាំ 2020
អ្នកប្រមូលចំណូល

បង្កាន់ដៃនេះត្រូវបានបោះពុម្ព និងគ្រប់គ្រងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្របតាមអនុក្រឹត្យលេខ ៨២អនក្រ. ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥

# ឧបសម្ព័ន្ធ២

## គំរូឯកសារ

# ឧបសម្ព័ន្ធ២.ក

កិច្ចសន្យាបង្កើតហ៊ីប៉ូតែក

**កិច្ចសន្យាបង្កើតហ៊ីប៉ូតែក**

អ្នកតែងលិខិត............

លេខ.........................

មន្ទីរ ដ.ន.ស.ស រាជធានីភ្នំពេញ

ក្រដាសពុម្ពលេខ................

ទីទុកឯកសារ

## កិច្ចសន្យាបង្កើតហ៊ីប៉ូតែក

**១. ឈ្មោះ និង អាសយដ្ឋានរបស់ភាគីនៃកិច្ចសន្យា**

(១) កូនបំណុលឈ្មោះ:[១]..............................................ភេទ..........ថ្ងៃខែឆ្នាំកំណើត[២] ..................
សញ្ជាតិ................ទីលំនៅភូមិ...................... សង្កាត់........................ ខណ្ឌ........................ រាជធានីភ្នំពេញ
[៣] (តទៅហៅថាភាគី-ក-) ។

កូនបំណុលឈ្មោះ:[១]..............................................ភេទ..........ថ្ងៃខែឆ្នាំកំណើត[២]..................
សញ្ជាតិ................ទីលំនៅភូមិ...................... សង្កាត់........................ ខណ្ឌ........................ រាជធានីភ្នំពេញ
[៣] (តទៅហៅថាភាគី-ក-) ។

ឬអ្នកធានាដោយវត្ថុឈ្មោះ:[១]......................................ភេទ..........ថ្ងៃខែឆ្នាំកំណើត[២] ..............
សញ្ជាតិ................ទីលំនៅភូមិ...................... សង្កាត់........................ ខណ្ឌ........................ រាជធានីភ្នំពេញ
[៣] (តទៅហៅថាភាគី-ក-) ។

អ្នកធានាដោយវត្ថុឈ្មោះ:[១]........................................ភេទ..........ថ្ងៃខែឆ្នាំកំណើត[២] .................
សញ្ជាតិ................ទីលំនៅភូមិ...................... សង្កាត់........................ ខណ្ឌ........................ រាជធានីភ្នំពេញ
[៣] (តទៅហៅថាភាគី-ក-) ។

(២) ម្ចាស់បំណុលឈ្មោះ:[១]........................................ភេទ..........ថ្ងៃខែឆ្នាំកំណើត[២]................
សញ្ជាតិ................ទីលំនៅភូមិ...................... សង្កាត់........................ ខណ្ឌ........................ រាជធានីភ្នំពេញ
[៣] (តទៅហៅថាភាគី-ខ-) ។

---

ក្នុងករណីនីតិបុគ្គល ត្រូវសរសេរ:

[១]នាមករណ៍របស់នីតិបុគ្គល

[២]ថ្ងៃ ខែ ឆ្នាំ នៃការបង្កើតនីតិបុគ្គល

[៣]អាសយដ្ឋានដែលជាទីស្នាក់ការរបស់នីតិបុគ្គល។

២.សិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែក

កូនបំណុលឈ្មោះ[១]..............................................ភេទ..........ថ្ងៃខែឆ្នាំកំណើត[២]..................
សញ្ជាតិ..........ទីលំនៅភូមិ...................... សង្កាត់......................... ខណ្ឌ......................... រាជធានីភ្នំពេញ[៣] ។

(១) មូលហេតុ និងកាលបរិច្ឆេទនៃកិច្ចសន្យា......................................................................

(២)ចំនួនប្រាក់ដើម............................(ដុល្លារឬរៀល) សរសេរជាអក្សរ...........................................

(៣)អត្រាការប្រាក់...........................% ក្នុងមួយឆ្នាំ  សរសេរជាអក្សរ...........................................

(៤))សំណងការខូចខាត...................% ក្នុងមួយឆ្នាំ  សរសេរជាអក្សរ...........................................

(៥) លក្ខខណ្ឌ (ប្រសិនបើមានលក្ខខណ្ឌដូចមានចែងនៅក្នុងមាត្រា ៣២៥ នៃក្រមរដ្ឋប្បវេណី)............
..........................................................................................................................
..........................................................................................................................

ភាគី ក និង ភាគី ខ បានព្រមព្រៀងគ្នាបង្កើតហ៊ីប៉ូតែក...................(ហ៊ីប៉ូតែកធម្មតា ឬ ហ៊ីប៉ូតែករួម) លើសិទ្ធិនៃចំនុច ៣ ដើម្បីធានា សិទ្ធិលើបំណុលដែលមានចែងនៅចំណុចទី ២ ខាងលើ ។

៣.អត្តសញ្ញាណអចលនវត្ថុ ឬ សិទ្ធិ ដែលជាកម្មវត្ថុនៃហ៊ីប៉ូតែក

(១) ទីតាំងអចលនវត្ថុ:ភូមិ...................... សង្កាត់...........................ខណ្ឌ...................
រាជធានីភ្នំពេញ ។

(២)លេខក្បាលដី:..............................................................................................

(៣)លេខប័ណ្ណ:..................................................................................................

(លេខវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុ ឬ ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ ឬ ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី ឬ វិញ្ញាបនប័ត្រសម្គាល់សិទ្ធិជួលអចិន្ត្រៃយ៍ ឬ វិញ្ញាបនប័ត្រសម្គាល់ផលុបភោគ)

(១) ទីតាំងអចលនវត្ថុ:ភូមិ...................... សង្កាត់...........................ខណ្ឌ...................
រាជធានីភ្នំពេញ ។

(២)លេខក្បាលដី:..............................................................................................

(៣)លេខប័ណ្ណ:..................................................................................................

(លេខវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុ ឬ ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ ឬ ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី ឬ វិញ្ញាបនប័ត្រសម្គាល់សិទ្ធិជួលអចិន្ត្រៃយ៍ ឬ វិញ្ញាបនប័ត្រសម្គាល់ផលុបភោគ)

៨ ខសន្យាផ្សេងទៀត (ប្រសិនបើមាន) ៖

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

កិច្ចសន្យានេះធ្វើជា ០៣ ច្បាប់ នៅថ្ងៃទី..................ខែ...............ឆ្នាំ............ ចំពោះមុខយើងជា

.................................. (ចៅសង្កាត់ ឬ អភិបាលខណ្ឌ ឬ សារការី)

បានអានសេចក្តីនៃកិច្ចសន្យានេះឲ្យគូភាគីស្តាប់ចំពោះមុខសាក្សី

ឈ្មោះ...................................អាយុ.........ឆ្នាំ ទីលំនៅ សង្កាត់..........................ខណ្ឌ..........................
រាជធានីភ្នំពេញ ។

ឈ្មោះ...................................អាយុ.........ឆ្នាំ ទីលំនៅ សង្កាត់..........................ខណ្ឌ..........................
រាជធានីភ្នំពេញ ។

លេខបញ្ជាក់.................

ស្នាមមេដៃស្តាំ ស្នាមមេដៃស្តាំ ហត្ថលេខានិងត្រាមន្ត្រីដែលបញ្ជាក់

ភាគី-ក- ភាគី-ខ- សាក្សី សាក្សី

# ឧបសម្ព័ន្ធ២.ខ

## ពាក្យសុំចុះបញ្ជីអំពីការបង្កើតហ៊ីប៉ូតែក

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

មន្ទីរ ដ.ន.ស.ស រាជធានីភ្នំពេញ

**ពាក្យសុំចុះបញ្ជីអំពីការបង្កើតហ៊ីប៉ូតែក**

យើងខ្ញុំឈ្មោះ.................................................ភេទ.............អាយុ........ឆ្នាំ[១] អាសយដ្ឋានបច្ចុប្បន្ននៅ ផ្ទះលេខ...........ផ្លូវលេខ.............ភូមិ.................សង្កាត់.............................ខណ្ឌ..............................រាជធានីភ្នំពេញ (បុគ្គលមានសិទ្ធិចុះបញ្ជី) និងឈ្មោះ..............................................ភេទ.............អាយុ........ឆ្នាំ[២] អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ...........ផ្លូវលេខ.............ភូមិ.................សង្កាត់.............................ខណ្ឌ...................... រាជធានីភ្នំពេញ (បុគ្គលមានកាតព្វកិច្ចចុះបញ្ជី)។

**<u>សូមគោរពជូន</u>**

**លោកប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដី រាជធានីភ្នំពេញ**

**<u>កម្មវត្ថុ</u>** ៖ សំណើសុំចុះបញ្ជីអំពីការបង្កើតហ៊ីប៉ូតែក

**<u>យោង</u>** ៖ -កិច្ចសន្យា..................................ចុះថ្ងៃទី...........ខែ...................ឆ្នាំ............

- កិច្ចសន្យាបង្កើតហ៊ីប៉ូតែក ចុះថ្ងៃទី...........ខែ...................ឆ្នាំ..............

តាមកម្មវត្ថុនិងយោងខាងលើ យើងខ្ញុំសូមស្នើសុំចុះបញ្ជីអំពីការបង្កើតហ៊ីប៉ូតែកដូចខាងក្រោម៖

ក-គោលបំណងនៃការចុះបញ្ជី៖

- ការបង្កើតហ៊ីប៉ូតែកលើកម្មសិទ្ធិ ឬ
- ការបង្កើតហ៊ីប៉ូតែកលើសិទ្ធិជួលអចិន្ត្រៃយ៍ ឬ
- ការបង្កើតហ៊ីប៉ូតែកលើផលុបភោគ

ខ- មូលហេតុ ៖

- កិច្ចសន្យា..................................ចុះថ្ងៃទី............ខែ.................ឆ្នាំ...............
- កិច្ចសន្យាបង្កើតហ៊ីប៉ូតែក ចុះថ្ងៃទី..........ខែ...................ឆ្នាំ..............

គ- បុគ្គលមានសិទ្ធិចុះបញ្ជី

– ឈ្មោះ ..................................................................................................................

– ថ្ងៃ ខែ ឆ្នាំកំណើត និងទីកន្លែងកំណើត ..................................................................

– អាសយដ្ឋាន ............................................................................................................

– ឈ្មោះឪពុក ...........................................ឈ្មោះម្តាយ .......................................

–បុគ្គលមានកាតព្វកិច្ចចុះបញ្ជី

– ឈ្មោះ ..................................................................................................................

– ថ្ងៃ ខែ ឆ្នាំកំណើត និងទីកន្លែងកំណើត ..................................................................

– អាសយដ្ឋាន ............................................................................................................

– ឈ្មោះឪពុក ...........................................ឈ្មោះម្តាយ.......................................

ឃ– ចំណុចដែលត្រូវផ្លាស់ប្តូរ

– ចំនួនទឹកប្រាក់អតិបរមាថ្មី ..............................................................................

ង– អត្តសញ្ញាណនៃអចលនវត្ថុ

– ទីតាំងដី...............................................................................................................

– លេខក្បាលដី ឬ លេខប័ណ្ណ.............................................................................

ឯកសារភ្ជាប់ : ដូចមានចែងក្នុងប្រការ ២៧

អាស្រ័យហេតុនេះសូមលោក/លោកស្រីប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានី/ខេត្ត..................... មេត្តាពិនិត្យ និងសម្រេចអនុញ្ញាតឲ្យចុះបញ្ជីតាមសំណើខាងលើដោយអនុគ្រោះ។

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ

អ្នកមានកាតព្វកិច្ចចុះបញ្ជី ឬតំណាង
*(ស្នាមម្រាមដៃ)*

អ្នកមានសិទ្ធិចុះបញ្ជី ឬតំណាង
*(ស្នាមម្រាមដៃ)*

ឯកសារភ្ជាប់ ៖ ..........................................................................

## ឧបសម្ព័ន្ធ២.ធ

ពាក្យសុំចុះបញ្ជីអំពីការផ្លាស់ប្តូរទំហំសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

### ពាក្យសុំចុះបញ្ជី អំពីការផ្លាស់ប្តូរទំហំសិទ្ធិលើបំណុល ដែលត្រូវបានធានាដោយហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត

យើងខ្ញុំ ឈ្មោះ.................. ភេទ................ អាយុ.........ឆ្នាំ[1] អាសយដ្ឋានបច្ចុប្បន្ននៅ ផ្ទះលេខ..........ផ្លូវលេខ...........ភូមិ................ឃុំ/សង្កាត់...................ក្រុង/ស្រុក/ខណ្ឌ.............. រាជធានី/ខេត្ត......................(បុគ្គលមានសិទ្ធិចុះបញ្ជី) និង ឈ្មោះ.................. ភេទ............... អាយុ.........ឆ្នាំ[2] អាសយដ្ឋានបច្ចុប្បន្ននៅផ្ទះលេខ..............ផ្លូវលេខ..............ភូមិ...............ឃុំ/ សង្កាត់................ក្រុង/ស្រុក/ខណ្ឌ........................ រាជធានី/ខេត្ត.......................(បុគ្គលមានកាតព្វកិច្ចចុះបញ្ជី)។

**សូមគោរពជូន**

លោក/លោកស្រីប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានី/ខេត្ត[3]....

កម្មវត្ថុ ៖ សំណើសុំចុះបញ្ជីអំពីការផ្លាស់ប្តូរទំហំសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែក ដើម្បីធានាបំណុលអណ្តែត

យោង ៖ មូលហេតុ និងកាលបរិច្ឆេទ.......................................................................

តាមកម្មវត្ថុ និងយោងខាងលើ យើងខ្ញុំសូមស្នើសុំចុះបញ្ជីអំពីទំហំសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ដូចខាងក្រោម ៖

ក– គោលបំណងនៃការចុះបញ្ជី ៖

– ការផ្លាស់ប្តូរទំហំសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត លេខ....... លើកម្មសិទ្ធិ ឬ

– ការផ្លាស់ប្តូរទំហំសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត លេខ....... លើសិទ្ធិជួលអចិន្ត្រៃយ៍ ឬ

---

[1] និង[2] ក្នុងករណីបុគ្គលមានសិទ្ធិចុះបញ្ជី ឬ បុគ្គលមានកាតព្វកិច្ចចុះបញ្ជីជានីតិបុគ្គល ត្រូវសរសេរនាមករណ៍ និងអាសយដ្ឋានដែលជាទីស្នាក់ការរបស់នីតិបុគ្គលនោះ។

[3] ក្នុងករណីពាក្យសុំចុះបញ្ជីដាក់នៅរដ្ឋបាលសុរិយោដីក្រុង/ស្រុក/ខណ្ឌ ត្រូវសរសេរបន្ថែមថា ៖ "តាមរយៈ លោក/លោកស្រីប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល ក្រុង/ស្រុក/ខណ្ឌ..................."

ចំណាំ ៖ សូមជម្រាបថា ៖ ដើម្បីជៀសវាងការយឺតយ៉ាវក្នុងការទទួលបាននូវលំដាប់អាទិភាពជាយថាហេតុ ម្ចាស់សិទ្ធិអាចដាក់ពាក្យសុំចុះបញ្ជីទៅរដ្ឋបាលសុរិយោដី រាជធានី/ខេត្ត ដោយផ្ទាល់តែម្តងក៏បានដែរ (សូមមើលប្រការ ៥ ដល់ប្រការ ៨ នៃប្រកាសអន្តរក្រសួងស្តីពី នីតិវិធីនៃការចុះបញ្ជីនៃសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណីលេខ ៣០ កយដនស-ប្រក/១៣ ចុះថ្ងៃទី ២៩ ខែមករា ឆ្នាំ ២០១៣)។

– ការផ្លាស់ប្តូរទំហំសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត លេខ...... លើផលុបភោគ

ខ– មូលហេតុ និងកាលបរិច្ឆេទ

– កិច្ចសន្យាផ្លាស់ប្តូរ ចុះថ្ងៃទី...........ខែ............ឆ្នាំ............

គ– បុគ្គលមានសិទ្ធិចុះបញ្ជី

– ឈ្មោះ ...........................................................................................

– ថ្ងៃ ខែ ឆ្នាំកំណើត និងទីកន្លែងកំណើត ..................................................

– អាសយដ្ឋាន ..............................................................................

– ឈ្មោះឪពុក ..............................ឈ្មោះម្តាយ ................................

–បុគ្គលមានកាតព្វកិច្ចចុះបញ្ជី

– ឈ្មោះ ...........................................................................................

– ថ្ងៃ ខែ ឆ្នាំកំណើត និងទីកន្លែងកំណើត ..................................................

– អាសយដ្ឋាន ..............................................................................

– ឈ្មោះឪពុក ..............................ឈ្មោះម្តាយ................................

ឃ– ចំណុចដែលត្រូវផ្លាស់ប្តូរ

– ទំហំសិទ្ធិលើបំណុលដែលត្រូវបានធានាថ្មី.............................................

ង– អត្តសញ្ញាណនៃអចលនវត្ថុ

– ទីតាំងដី.............................................................................

– លេខក្បាលដី ឬ លេខប័ណ្ណ..........................................................

ឯកសារភ្ជាប់ : ដូចមានចែងក្នុងប្រការ ២៧

អាស្រ័យហេតុនេះសូមលោក/លោកស្រីប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានី/ខេត្ត.................... មេត្តាពិនិត្យ និងសម្រេចអនុញ្ញាតឲ្យចុះបញ្ជីតាមសំណើខាងលើដោយអនុគ្រោះ។

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ

| | |
|---|---|
| អ្នកមានសិទ្ធិចុះបញ្ជី ឬតំណាង | អ្នកមានកាតព្វកិច្ចចុះបញ្ជី ឬតំណាង |
| *(ស្នាមម្រាមដៃ)* | *(ស្នាមម្រាមដៃ)* |

ឯកសារភ្ជាប់ ៖ .................................................................

# ឧបសម្ព័ន្ធ២.ន

ពាក្យសុំចុះបញ្ជីអំពីការផ្លាស់ប្តូរកាលបរិច្ឆេទដែលប្រាក់ដើមត្រូវបានកំណត់ជាស្ថាពរនៃហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## ពាក្យសុំចុះបញ្ជី អំពីការផ្លាស់ប្តូរកាលបរិច្ឆេទដែលប្រាក់ដើម ត្រូវបានកំណត់ជាស្ថាពរ នៃហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត

យើងខ្ញុំ ឈ្មោះ.................. ភេទ................ អាយុ.........ឆ្នាំ[1] អាសយដ្ឋានបច្ចុប្បន្ននៅផ្ទះលេខ..........ផ្លូវលេខ...........ភូមិ................ឃុំ/សង្កាត់....................ក្រុង/ស្រុក/ខណ្ឌ..............រាជធានី/ខេត្ត.......................(បុគ្គលមានសិទ្ធិចុះបញ្ជី) និង ឈ្មោះ.................. ភេទ................អាយុ.........ឆ្នាំ[2] អាសយដ្ឋានបច្ចុប្បន្ននៅផ្ទះលេខ..............ផ្លូវលេខ...............ភូមិ................ឃុំ/សង្កាត់.................ក្រុង/ស្រុក/ខណ្ឌ........................ រាជធានី/ខេត្ត.......................(បុគ្គលមានកាតព្វកិច្ចចុះបញ្ជី)។

**សូមគោរពជូន**

លោក/លោកស្រីប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានី/ខេត្ត[3]....

កម្មវត្ថុ ៖ សំណើសុំចុះបញ្ជីអំពីការផ្លាស់ប្តូរកាលបរិច្ឆេទដែលប្រាក់ដើមត្រូវបានកំណត់ជាស្ថាពរ នៃហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត

យោង ៖ មូលហេតុ និងកាលបរិច្ឆេទ...........................................................................

តាមកម្មវត្ថុ និងយោងខាងលើ យើងខ្ញុំសូមស្នើសុំចុះបញ្ជីអំពីកាលបរិច្ឆេទដែលប្រាក់ដើមត្រូវបានកំណត់ជាស្ថាពរ នៃហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ដូចខាងក្រោម ៖

ក– គោលបំណងនៃការចុះបញ្ជី ៖

- ការផ្លាស់ប្តូរកាលបរិច្ឆេទដែលប្រាក់ដើមត្រូវបានកំណត់ជាស្ថាពរ នៃហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត លេខ.....លើកម្មសិទ្ធិ ឬ
- ការផ្លាស់ប្តូរកាលបរិច្ឆេទដែលប្រាក់ដើមត្រូវបានកំណត់ជាស្ថាពរ នៃហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត លេខ.....លើសិទ្ធិជួលអចិន្ត្រៃយ៍ ឬ

---

(1) និង(2) ក្នុងករណីបុគ្គលមានសិទ្ធិចុះបញ្ជី ឬ បុគ្គលមានកាតព្វកិច្ចចុះបញ្ជីជានីតិបុគ្គល ត្រូវសរសេរនាមករណ៍ និងអាសយដ្ឋានដែលជាទីស្នាក់ការរបស់នីតិបុគ្គលនោះ។

(3) ក្នុងករណីពាក្យសុំចុះបញ្ជីដាក់នៅរដ្ឋបាលសុរិយោដីក្រុង/ស្រុក/ខណ្ឌ ត្រូវសរសេរបន្ថែមថា ៖ "តាមរយៈ លោក/លោកស្រីប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល ក្រុង/ស្រុក/ខណ្ឌ.................."

ចំណាំ ៖ សូមជម្រាបថា ៖ ដើម្បីជៀសវាងការយឺតយ៉ាវក្នុងការទទួលបាននូវលំដាប់អាទិភាពជាយថាហេតុ ម្ចាស់សិទ្ធិអាចដាក់ពាក្យសុំចុះបញ្ជីទៅរដ្ឋបាលសុរិយោដី រាជធានី/ខេត្ត ដោយផ្ទាល់តែម្តងក៏បានដែរ (សូមមើលប្រការ ៥ ដល់ប្រការ ៨ នៃប្រកាសអន្តរក្រសួងស្តីពី នីតិវិធីនៃការចុះបញ្ជីនៃសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណីលេខ ៣០ កយដនស-ប្រក/១៣ ចុះថ្ងៃទី ២៩ ខែមករា ឆ្នាំ ២០១៣)។

– ការផ្លាស់ប្តូរកាលបរិច្ឆេទដែលប្រាក់ដើមត្រូវបានកំណត់ជាស្ថាពរនៃហ៊ីប៉ូតែកដើម្បី ធានាបំណុលអណ្តែត លេខ.....លើផលុបភោគ ឬ

ខ– មូលហេតុ និងកាលបរិច្ឆេទ

– កិច្ចសន្យាផ្លាស់ប្តូរ ចុះថ្ងៃទី...........ខែ............ឆ្នាំ............

គ– បុគ្គលមានសិទ្ធិចុះបញ្ជី

– ឈ្មោះ ................................................................................................

– ថ្ងៃ ខែ ឆ្នាំកំណើត និងទីកន្លែងកំណើត ................................................

– អាសយដ្ឋាន ........................................................................................

– ឈ្មោះឪពុក ..........................................ឈ្មោះម្តាយ ..................................

–បុគ្គលមានកាតព្វកិច្ចចុះបញ្ជី

– ឈ្មោះ ................................................................................................

– ថ្ងៃ ខែ ឆ្នាំកំណើត និងទីកន្លែងកំណើត ................................................

– អាសយដ្ឋាន ........................................................................................

– ឈ្មោះឪពុក ..........................................ឈ្មោះម្តាយ..................................

ឃ– ចំណុចដែលត្រូវផ្លាស់ប្តូរ

– កាលបរិច្ឆេទ ដែលប្រាក់ដើមត្រូវបានកំណត់ជាស្ថាពរថ្មី........................................

ង– អត្តសញ្ញាណនៃអចលនវត្ថុ

– ទីតាំងដី....................................................................................................

– លេខក្បាលដី ឬ លេខប័ណ្ណ.......................................................................

ឯកសារភ្ជាប់ : ដូចមានចែងក្នុងប្រការ ២៧

អាស្រ័យហេតុនេះសូមលោក/លោកស្រីប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានី/ខេត្ត.................... មេត្តាពិនិត្យ និងសម្រេចអនុញ្ញាតឲ្យចុះបញ្ជីតាមសំណើ ខាងលើដោយអនុគ្រោះ។

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ

អ្នកមានកាតព្វកិច្ចចុះបញ្ជី ឬតំណាង

*(ស្នាមម្រាមដៃ)*

អ្នកមានសិទ្ធិចុះបញ្ជី ឬតំណាង

*(ស្នាមម្រាមដៃ)*

ឯកសារភ្ជាប់ ៖ ........................................................

## ប្រការ ១៣០ របៀបចុះបញ្ជី អំពីកាលបរិច្ឆេទដែលប្រាក់ដើមត្រូវបានកំណត់ជាស្ថាពរនៃហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត

| | | | | |
|---|---|---|---|---|
| រាជធានី/ខេត្ត | ក្រុង/ស្រុក/ខណ្ឌ | ឃុំ/សង្កាត់ | ភូមិ | ផ្លូវ |
| លេខក្បាលដី | សន្លឹកផែនទី | មធ្យោបាយធ្វើអត្តសញ្ញាណកម្មក្បាលដី | | ទំហំដី ម² |
| ប្រភេទដី | រូបភាពប្រើប្រាស់ដី | លក្ខណៈនៃការប្រើប្រាស់ដី | | អក្សរសញ្ញា ៖ ...................... |

ឈ្មោះកម្មសិទ្ធិករ ៖ ......................................

| អត្រានុកូលដ្ឋានម្ចាស់អចលនវត្ថុ | | | ការផ្លាស់ប្តូរ | | សេចក្តីផ្សេងៗ |
|---|---|---|---|---|---|
| នាមត្រកូល និងនាមខ្លួន / ប្រភេទទ្រព្យ | ថ្ងៃ ខែ ឆ្នាំ និង ទីកន្លែងកំណើត | សាវតា | លេខាចារឹកដោយសង្ខេបនៃ លិខិតសញ្ញា ឬសាលក្រមតុលាការ | បន្ទុកលើអចលនវត្ថុ | |
| ១ | ២ | ៣ | ៤ | ៥ | ៦ |
| ច័ន្ទ រតនា | ០១.០១.១៩៥០ | | | ១. បង្កើតហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតឲ្យធនាគារ អេ ភី.អិល.ស៊ី កូនបំណុល ច័ន្ទ រតនា ប្រាក់អតិបរមា ១០.០០០ ដុល្លារ ទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានា ប្រតិបត្តិការធានាគារ កាលបរិច្ឆេទដែលប្រាក់ដើមត្រូវបានកំណត់ជាស្ថាពរ ០១.០១.២០១៥ កិច្ចសន្យាបង្កើតហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ចុះថ្ងៃ០១.០១.២០១៣<br>១.១ ហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតលេខ១ ប្រាក់ដើមត្រូវបានកំណត់ជាស្ថាពរ នៅថ្ងៃទី ០១.០១.២០១៤ តាមកិច្ចសន្យា ចុះថ្ងៃ ០១.០៧.២០១៣ | |

# ឧបសម្ព័ន្ធ២.ប

## ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីអំពីហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ពាក្យសុំចុះបញ្ជី អំពីការលុបការចុះបញ្ជី អំពីហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត**

យើងខ្ញុំ ឈ្មោះ.................... ភេទ.................. អាយុ.........ឆ្នាំ[1] អាសយដ្ឋានបច្ចុប្បន្ននៅផ្ទះលេខ..........ផ្លូវលេខ...........ភូមិ...............ឃុំ/សង្កាត់...................ក្រុង/ស្រុក/ខណ្ឌ...............រាជធានី/ខេត្ត......................(បុគ្គលមានសិទ្ធិចុះបញ្ជី) និង ឈ្មោះ.................. ភេទ................ អាយុ.........ឆ្នាំ[2] អាសយដ្ឋានបច្ចុប្បន្ននៅផ្ទះលេខ..............ផ្លូវលេខ..............ភូមិ................ឃុំ/សង្កាត់.................ក្រុង/ស្រុក/ខណ្ឌ....................... រាជធានី/ខេត្ត......................(បុគ្គលមានកាតព្វកិច្ចចុះបញ្ជី)។

**សូមគោរពជូន**

លោក/លោកស្រីប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានី/ខេត្ត[3]....

កម្មវត្ថុ ៖ សំណើសុំចុះបញ្ជីអំពីការលុបការចុះបញ្ជី អំពីហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត
យោង ៖ មូលហេតុ និងកាលបរិច្ឆេទ..............................................................................

តាមកម្មវត្ថុ និងយោងខាងលើ យើងខ្ញុំសូមស្នើសុំចុះបញ្ជីអំពីការលុបការចុះបញ្ជី អំពីហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ដូចខាងក្រោម ៖

ក– គោលបំណងនៃការចុះបញ្ជី ៖

- ការលុបការចុះបញ្ជី អំពីហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត លេខ....... លើកម្មសិទ្ធិ ឬ
- ការលុបការចុះបញ្ជី អំពីហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត លេខ........... លើសិទ្ធិជួលអចិន្ត្រៃយ៍ ឬ
- ការលុបការចុះបញ្ជី អំពីហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត លេខ................ លើផលុបភោគ

ខ– មូលហេតុ និងកាលបរិច្ឆេទ

---

[1] និង[2] ក្នុងករណីបុគ្គលមានសិទ្ធិចុះបញ្ជី ឬ បុគ្គលមានកាតព្វកិច្ចចុះបញ្ជីជានីតិបុគ្គល ត្រូវសរសេរនាមករណ៍ និងអាសយដ្ឋានដែលជាទីស្នាក់ការរបស់នីតិបុគ្គលនោះ។

[3] ក្នុងករណីពាក្យសុំចុះបញ្ជីដាក់នៅរដ្ឋបាលសុរិយោដីក្រុង/ស្រុក/ខណ្ឌ ត្រូវសរសេរបន្ថែមថា ៖ "តាមរយៈ លោក/លោកស្រីប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល ក្រុង/ស្រុក/ខណ្ឌ....................."

ចំណាំ ៖ សូមជម្រាបថា ៖ ដើម្បីជៀសវាងការយឺតយ៉ាវក្នុងការទទួលបានឡើងវិញនូវលិខិតបញ្ជាក់ ម្ចាស់សិទ្ធិអាចដាក់ពាក្យសុំចុះបញ្ជីទៅរដ្ឋបាលសុរិយោដី រាជធានី/ខេត្ត ដោយផ្ទាល់តែម្តងក៏បានដែរ (សូមមើលប្រការ ៥ ដល់ប្រការ ៨ នៃប្រកាសអន្តរក្រសួងស្តីពី នីតិវិធីនៃការចុះបញ្ជីនៃសិទ្ធិប្រាតិភោគទាក់ទងនឹងក្រមរដ្ឋប្បវេណីលេខ ៣០ កយដនស-ប្រក/១៣ ចុះថ្ងៃទី ២៥ ខែមករា ឆ្នាំ ២០១៣)។

– ការសង ចុះថ្ងៃទី............ខែ...............ឆ្នាំ............ ឬ

– ការបោះបង់ហើប៉ុន្តែកដើម្បីធានាបំណុលអណ្តែត ចុះថ្ងៃទី.......ខែ.........ឆ្នាំ......... ឬ

– ការទាមទារឲ្យរំលត់ហើប៉ុន្តែកដើម្បីធានាបំណុលអណ្តែត ចុះថ្ងៃទី....ខែ......ឆ្នាំ..... ឬ

– មូលហេតុផ្សេងទៀត..........................................ចុះថ្ងៃទី.......ខែ.........ឆ្នាំ.........

គ– បុគ្គលមានសិទ្ធិចុះបញ្ជី

– ឈ្មោះ ..........................................................................................

– ថ្ងៃ ខែ ឆ្នាំកំណើត និងទីកន្លែងកំណើត ..........................................

– អាសយដ្ឋាន ...................................................................................

– ឈ្មោះឪពុក ......................................ឈ្មោះម្តាយ ..........................

–បុគ្គលមានកាតព្វកិច្ចចុះបញ្ជី

– ឈ្មោះ ..........................................................................................

– ថ្ងៃ ខែ ឆ្នាំកំណើត និងទីកន្លែងកំណើត..........................................

– អាសយដ្ឋាន ...................................................................................

– ឈ្មោះឪពុក ......................................ឈ្មោះម្តាយ...........................

ឃ– អត្តសញ្ញាណនៃអចលនវត្ថុ

– ទីតាំងដី.......................................................................................

– លេខក្បាលដី ឬ លេខប័ណ្ណ..........................................................

ឯកសារភ្ជាប់ : ដូចមានចែងក្នុងប្រការ ២៧

អាស្រ័យហេតុនេះសូមលោក/លោកស្រីប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានី/ខេត្ត.................... មេត្តាពិនិត្យ និងសម្រេចអនុញ្ញាតឲ្យចុះបញ្ជីតាមសំណើខាងលើដោយអនុគ្រោះ។

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ

| | |
|---|---|
| អ្នកមានសិទ្ធិចុះបញ្ជី ឬតំណាង | អ្នកមានកាតព្វកិច្ចចុះបញ្ជី ឬតំណាង |
| *(ស្នាមម្រាមដៃ)* | *(ស្នាមម្រាមដៃ)* |

ឯកសារភ្ជាប់ ៖ ............................................................

# ប្រការ ១៣១ របៀបចុះបញ្ជី អំពីការលុបការចុះបញ្ជី អំពីហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត

| | | | | |
|---|---|---|---|---|
| រាជធានី/ខេត្ត | ក្រុង/ស្រុក/ខណ្ឌ | ឃុំ/សង្កាត់ | ភូមិ | ផ្លូវ |
| លេខក្បាលដី | សន្លឹកផែនទី | មធ្យោបាយធ្វើអត្តសញ្ញាណកម្មក្បាលដី | | ទំហំដី ម² |
| ប្រភេទដី | រូបភាពប្រើប្រាស់ដី | លក្ខណៈនៃការប្រើប្រាស់ដី | | អក្សរសញ្ញា ៖ ...................... |

ឈ្មោះកម្មសិទ្ធិករ ៖ ......................................

| អត្រានុកូលដ្ឋានម្ចាស់អចលនវត្ថុ | | | ការផ្លាស់ប្តូរ | | សេចក្តីផ្សេងៗ |
|---|---|---|---|---|---|
| នាមត្រកូល និងនាមខ្លួន / ប្រភេទទ្រព្យ | ថ្ងៃ ខែ ឆ្នាំ និង ទីកន្លែងកំណើត | សាវតា | លេខចារឹកដោយសង្ខេបនៃលិខិតសញ្ញា ឬសាលក្រមតុលាការ | បន្ទុកលើអចលនវត្ថុ | |
| ១ | ២ | ៣ | ៤ | ៥ | ៦ |
| ច័ន្ទ រេតនា | ០១.០១.១៩៩០ | | | ~~១. បង្កើតហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែតឲ្យធនាគារ អេ ភី.អិល.ស៊ី កូនបំណុល ច័ន្ទ រេតនា ប្រាក់អតិបរមា ១០.០០០ ដុល្លារ ទំហំនៃសិទ្ធិអេបីបំណុលដែលត្រូវបានធានា ប្រតិបត្តិការធានាគារកាលបរិច្ឆេទដែលប្រាក់ដើមត្រូវបានកំណត់ជាស្ថាពរ ០១.០១.២០១៥ កិច្ចសន្យាបង្កើតហ៊ីប៉ូតែកដើម្បីធានាបំណុលអណ្តែត ចុះថ្ងៃ ០១.០១.២០១៣~~<br><br>២. លុបការចុះបញ្ជីអំពីហ៊ីប៉ូតែកដើម្បីធានាបំណុល អណ្តែត ដោយមូលហេតុការសង ចុះថ្ងៃទី០១.០២.២០១៥ | |

# ឧបសម្ព័ន្ធ៣

## ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិពាក់ពន្ធ័

# ឧបសម្ព័ន្ធ៣.ក

ប្រកាសអន្តរក្រសួងលេខ ១៥៩ ប្រក/ដនស./មផ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលប្រការ ៩ នៃប្រកាសអន្តរក្រសួងលេខ ២១៥ ប្រក/ដនស.មផ ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ ២០០៥ ស្តីពីតួនាទី និងការទទួលខុសត្រូវរបស់រដ្ឋបាលឃុំ សង្កាត់ ក្នុងការចុះបញ្ជីដីធ្លី

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
លេខ÷...១៥៩..... ប្រក/ដនស./មផ

**ប្រកាសអន្តរក្រសួង**
**ស្តីពី**
**ការកែសម្រួលប្រការ ៩ នៃប្រកាសអន្តរក្រសួងលេខ ២១៥ ប្រក/ដនស.មផ ចុះថ្ងៃទី ០៩ខែ កញ្ញា ឆ្នាំ ២០០៥ ស្តីពីតួនាទី និងការទទួលខុសត្រូវរបស់រដ្ឋបាលឃុំ សង្កាត់ ក្នុងការចុះបញ្ជីដីធ្លី**

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី ០៤ ខែមេសា ឆ្នាំ ២០១៦ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី ១៩ ខែមីនា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែសីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញអនុក្រឹត្យលេខ ៤៦ អនក្រ.បក ចុះថ្ងៃទី ៣១ ខែឧសភា ឆ្នាំ ២០០២ ស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី
- បានឃើញអនុក្រឹត្យលេខ ៤៨ អនក្រ.បក ចុះថ្ងៃទី ៣១ ខែឧសភា ឆ្នាំ ២០០២ ស្តីពីការចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំ
- យោងតាមការចាំបាច់របស់ក្រសួងមហាផ្ទៃ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

អាសយដ្ឋាន : ផ្លូវលេខ ៧៧១-៧៧៣ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ
ទូរស័ព្ទ/ទូរសារ (855) 23 215 660 / 23 215 277 គេហទំព័រ www.mlmupc.gov.kh អ៊ីមែល mlmupc.cabinet@gmail.com

# សម្រេច

**ប្រការមួយ .**

ប្រការ ៩ នៃប្រកាសអន្តរក្រសួងលេខ ២១៥ ប្រក/ដនស.មផ ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ ២០០៥ ស្តីពីតួនាទី និងការទទួលខុសត្រូវរបស់រដ្ឋបាលឃុំ សង្កាត់ ក្នុងការចុះបញ្ជីដីធ្លី ត្រូវបានកែសម្រួលដូចតទៅ÷

**ប្រការ ៩ . ថ្មី**

មេឃុំ ចៅសង្កាត់ ជាអ្នកបញ្ជាក់លើលិខិតសញ្ញាផ្សេងៗ ដូចជា លិខិតលក់ផ្តាច់ អំណោយផ្តាច់ កិច្ចសន្យាបញ្ចាំ ដាក់ធានា ហ៊ុប៉ូតែក កិច្ចសន្យាជួលរយៈពេលវែង កិច្ចសន្យាបង្កើតសេវភាព ផលុបភោគ អាស្រ័យលើការព្រមព្រៀងរបស់គូភាគី ។ ក្នុងការបញ្ជាក់ មេឃុំ ចៅសង្កាត់ត្រូវយកចិត្តទុកដាក់ និងទទួលខុសត្រូវលើ ÷

- អត្តសញ្ញាណអចលនវត្ថុ ដែលជាកម្មវត្ថុនៃលិខិតកិច្ចសន្យា និង
- អត្តសញ្ញាណគូភាគីនៃកិច្ចសន្យា ។

**ប្រការពីរ .**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការបី .**

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល គ្រប់ប្រធានអង្គភាពក្រោមនិវាទក្រសួងមហាផ្ទៃ នាយកខុទ្ទកាល័យ អគ្គនាយកគ្រប់អគ្គនាយកដ្ឋាន គ្រប់ប្រធានអង្គភាពក្រោមនិវាទក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ គ្រប់អភិបាលរាជធានី ខេត្ត គ្រប់ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត គ្រប់អភិបាលក្រុង ស្រុក ខណ្ឌ គ្រប់ប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ខណ្ឌ គ្រប់ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែមិថុនា គ.ស. ២០១៦

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្តេចក្រឡាហោម ស ខេង

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

ជា សុផារ៉ា

<u>កន្លែងទទួល÷</u>

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- ដូចប្រការបី
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ឧបសម្ព័ន្ធ៣.ខ

អនុក្រឹត្យលេខ១៨ អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតយន្តការច្រកចេញចូលតែមួយសម្រាប់ការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១៨ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពី
## ការបង្កើតយន្តការច្រកចេញចូលតែមួយ សម្រាប់ការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលសមាសភាពសមាជិករាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ

- បានឃើញអនុក្រឹត្យលេខ២១៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីភ្នំពេញ និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ
- បានឃើញអនុក្រឹត្យលេខ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- បានឃើញអនុក្រឹត្យលេខ៦៨ អនក្រ.បក ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ៦៨ អនក្រ.បក ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១២ ស្តីពីដំណើរការទូទៅនៃការផ្ទេរមុខងារ និងធនធានឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- យោងតាមសំណើរបស់ប្រធានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១._**

អនុក្រឹត្យនេះ មានគោលបំណងលើកកម្ពស់គុណភាព ប្រសិទ្ធភាព ប្រសិទ្ធផល តម្លាភាព និងគណនេយ្យភាពនៃការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈការប្រមូលផ្តុំការផ្តល់សេវារដ្ឋបាលលើវិស័យនានានៅកន្លែងតែមួយ ដើម្បីបង្កលក្ខណៈងាយស្រួល និងឆ្លើយតបទាន់ពេលវេលាទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ។

**មាត្រា២._**

អនុក្រឹត្យនេះ មានគោលដៅកំណត់អំពីយន្តការ គោលការណ៍ បែបបទ និងនីតិវិធីនៃការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងការគាំទ្រ ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃទៅលើការផ្តល់សេវារដ្ឋបាលទាំងនោះ។

**មាត្រា៣._**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងក្របខ័ណ្ឌសមត្ថកិច្ចដែលទទួលបានតាមរយៈការប្រគល់ឬការធ្វើប្រតិភូកម្មពីក្រសួង ស្ថាប័នពាក់ព័ន្ធនានារបស់រាជរដ្ឋាភិបាល និងក្នុងក្របខ័ណ្ឌសមត្ថកិច្ចនៃអាណត្តិទូទៅរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

## ជំពូកទី២
## យន្តការនៃការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលរាជធានី ខេត្ត
### ផ្នែកទី១
### រចនាសម្ព័ន្ធនិងតួនាទី

**មាត្រា៤._**

រដ្ឋបាលរាជធានី ខេត្តនីមួយៗ ត្រូវបង្កើតឱ្យមាន**អង្គភាពច្រកចេញចូលតែមួយ**សម្រាប់ផ្តល់សេវារដ្ឋបាលជូនប្រជាពលរដ្ឋនៅក្នុងក្របខ័ណ្ឌសមត្ថកិច្ចរបស់ខ្លួន។

**មាត្រា៥._**

អង្គភាពច្រកចេញចូលតែមួយ គឺជាកន្លែងប្រមូលផ្តុំការផ្តល់សេវារដ្ឋបាលនៅកន្លែងតែមួយតាមនីតិវិធីសាមញ្ញ ប្រកបដោយគុណភាព ប្រសិទ្ធភាព ប្រសិទ្ធផល តម្លាភាព និងគណនេយ្យភាព។

អង្គភាពច្រកចេញចូលតែមួយ ត្រូវរៀបចំជាពីរផ្នែកគឺ ផ្នែកជួរមុខ និងផ្នែកជួរក្រោយ។

**ផ្នែកជួរមុខ** គឺជាកន្លែងសម្រាប់ប្រជាពលរដ្ឋប្រាស្រ័យទាក់ទងដោយផ្ទាល់ ដើម្បីទទួលព័ត៌មាននានាអំពីការផ្តល់សេវារដ្ឋបាល ទទួលទម្រង់បែបបទ ដាក់ពាក្យស្នើសុំ បង់ប្រាក់កម្រៃ និងទទួលលទ្ធផលសម្រេចជាផ្លូវការនៃសេវារដ្ឋបាលដែលបានស្នើសុំ។

**ផ្នែកជួរក្រោយ** គឺជាកន្លែងពិនិត្យ និងផ្តល់យោបល់ផ្នែកបច្ចេកទេសលើសំណុំបែបបទនៃការស្នើសុំសេវារដ្ឋបាល។

**មាត្រា៦._**

អង្គភាពច្រកចេញចូលតែមួយត្រូវដឹកនាំដោយប្រធានមួយ(១)រូប និងអនុប្រធានយ៉ាងច្រើនពីរ(២)រូបជាជំនួយការ។

ប្រធានអង្គភាពច្រកចេញចូលតែមួយ មានឋានៈស្មើនាយកទីចាត់ការនៃសាលារាជធានី ខេត្ត។

អនុប្រធានអង្គភាពច្រកចេញចូលតែមួយ មានឋានៈស្មើនាយករងទីចាត់ការនៃសាលារាជធានី ខេត្ត។

ការតែងតាំងប្រធាននិងអនុប្រធានអង្គភាពច្រកចេញចូលតែមួយ ត្រូវអនុលោមលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ និងលិខិតបទដ្ឋានគតិយុត្តដែលមានជាធរមាន។

**មាត្រា៧._**

ការរៀបចំនិងការប្រព្រឹត្តទៅនៃអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

### ផ្នែកទី២
### ទីកន្លែងធ្វើការ បុគ្គលិក និងប្រភេទសេវារដ្ឋបាល

**មាត្រា៨._**

អភិបាលរាជធានី ខេត្ត ត្រូវរៀបចំឱ្យមានទីកន្លែងបំពេញការងាររបស់អង្គភាពច្រកចេញចូលតែមួយឱ្យបានសមស្រប និងបំពាក់នូវសម្ភារៈ បរិក្ខារ ឧបករណ៍ និងមធ្យោបាយសម្រាប់គាំទ្រដល់បុគ្គលិកបំពេញការងារនៅក្នុងអង្គភាពនេះ ព្រមទាំងបង្កលក្ខណៈងាយស្រួលដល់ប្រជាពលរដ្ឋក្នុងការទទួលសេវារដ្ឋបាល។

**មាត្រា៩.-**

រដ្ឋបាលរាជធានី ខេត្ត ត្រូវរៀបចំចាត់តាំងបុគ្គលិកដែលមានសមត្ថភាព និងបទពិសោធការងារក្នុងចំនួនសមស្របតាមទំហំការងារ និងស្ថានភាពជាក់ស្តែងនៃរដ្ឋបាលរាជធានី ខេត្តនីមួយៗសម្រាប់បំពេញការងារនៅផ្នែកជួរមុខនៃអង្គភាពច្រកចេញចូលតែមួយ។

**មាត្រា១០.-**

អភិបាលរាជធានី ខេត្ត ត្រូវសម្របសម្រួលជាមួយប្រធានមន្ទីរ អង្គភាពជំនាញពាក់ព័ន្ធនឹងការផ្តល់សេវារដ្ឋបាលដើម្បីចាត់តាំងបុគ្គលិកជំនាញយ៉ាងតិចចំនួនមួយ(១)រូប ដែលមានសមត្ថភាព និងបទពិសោធមកបំពេញការងារពេញម៉ោងនៅផ្នែកជួរក្រោយនៃអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត។

អភិបាលរាជធានី ខេត្ត ត្រូវរាយការណ៍អំពីការចាត់តាំងបុគ្គលិកមកបំពេញការងារនៅអង្គភាពច្រកចេញចូលតែមួយនេះជូនក្រុមប្រឹក្សារបស់ខ្លួន។

បុគ្គលិកដែលត្រូវបានចាត់តាំងឱ្យមកបំពេញការងារនៅផ្នែកជួរក្រោយនៃអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត ត្រូវបានប្រគល់សិទ្ធិក្នុងការពិនិត្យ និងការផ្តល់យោបល់បច្ចេកទេសលើសេវារដ្ឋបាលតាមវិស័យជំនាញរបស់ខ្លួន លើកលែងតែប្រភេទសេវារដ្ឋបាលមួយចំនួនដែលមានលក្ខណៈបច្ចេកទេសស៊ាំញ៉ាំ ស្មុគស្មាញ មានតម្រូវការបច្ចេកទេសច្រើន និងតម្រូវឱ្យមានការទទួលខុសត្រូវខ្ពស់។

ក្នុងករណីខាងលើនេះ អភិបាលរាជធានី ខេត្ត ត្រូវពិគ្រោះយោបល់ជាមួយប្រធានមន្ទីរ អង្គភាពជំនាញនីមួយៗ ដើម្បីកំណត់អំពីប្រភេទសេវារដ្ឋបាលមួយចំនួនដែលមានលក្ខណៈបច្ចេកទេសស៊ាំញ៉ាំ ស្មុគស្មាញ មានតម្រូវការបច្ចេកទេសច្រើន និងតម្រូវឱ្យមានការទទួលខុសត្រូវខ្ពស់ ព្រមទាំងចាត់តាំងបុគ្គលិកជំនាញទទួលខុសត្រូវឱ្យបានច្បាស់លាស់នៅតាមមន្ទីរ អង្គភាពពាក់ព័ន្ធ ដើម្បីពិនិត្យ និងផ្តល់យោបល់បច្ចេកទេសលើប្រភេទសេវារដ្ឋបាលទាំងនេះ។

**មាត្រា១១.-**

អង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត ត្រូវផ្តល់សេវារដ្ឋបាលតាមប្រភេទសេវារដ្ឋបាលដូចបានកំណត់នៅក្នុងតារាងឧបសម្ព័ន្ធទី១ ភ្ជាប់នឹងអនុក្រឹត្យនេះ។

កម្រៃសេវា រយៈពេលនៃការផ្តល់សេវា និងសុពលភាពនៃសេវារដ្ឋបាល ត្រូវអនុវត្តតាមប្រកាសអន្តរក្រសួងរវាងក្រសួង ស្ថាប័នពាក់ព័ន្ធនីមួយៗ ជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើកលែងតែមានការកំណត់ផ្សេងពីនេះ។

ក្រសួង ស្ថាប័នពាក់ព័ន្ធនានា ត្រូវបន្តផ្ទេរមុខងារក្នុងការផ្តល់សេវារដ្ឋបាលបន្ថែមទៀតទៅឱ្យរដ្ឋបាលរាជធានី ខេត្ត ដើម្បីបង្កលក្ខណៈងាយស្រួល និងបង្កិតការផ្តល់សេវារដ្ឋបាលឱ្យទៅជិតអ្នកប្រើប្រាស់សេវា។

**មាត្រា១២.-**

ក្រសួងមហាផ្ទៃដោយមានការពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនានា ត្រូវផ្តល់ការណែនាំអំពីទម្រង់បែបបទ នីតិវិធី និងលក្ខខណ្ឌភ្ជាប់សម្រាប់ស្នើសុំសេវារដ្ឋបាលឱ្យមានលក្ខណៈសាមញ្ញងាយយល់និងច្បាស់លាស់។

## ជំពូកទី៣
## យន្តការនៃការផ្ដល់សេវារដ្ឋបាលនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ
### ផ្នែកទី១
### រចនាសម្ព័ន្ធនិងតួនាទី

**មាត្រា១៣.—**

រដ្ឋបាលក្រុង ស្រុក ខណ្ឌនីមួយៗ ត្រូវបង្កើតឱ្យមានការិយាល័យច្រកចេញចូលតែមួយ ឬយន្តការច្រកចេញចូលតែមួយសម្រាប់ផ្ដល់សេវារដ្ឋបាលជូនប្រជាពលរដ្ឋនៅក្នុងក្របខ័ណ្ឌសមត្ថកិច្ចរបស់ខ្លួន។

លក្ខណសម្បត្តិនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ សម្រាប់បង្កើតការិយាល័យច្រកចេញចូលតែមួយ ត្រូវកំណត់ដោយសេចក្ដីណែនាំរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**មាត្រា១៤.—**

ការិយាល័យច្រកចេញចូលតែមួយ គឺជាកន្លែងប្រមូលផ្ដុំការផ្ដល់សេវារដ្ឋបាលនៅកន្លែងតែមួយ តាមនីតិវិធីសាមញ្ញ ប្រកបដោយគុណភាព ប្រសិទ្ធភាព ប្រសិទ្ធផល តម្លាភាព និងគណនេយ្យភាព។

ការិយាល័យច្រកចេញចូលតែមួយ ត្រូវរៀបចំជាពីរផ្នែកគឺ ផ្នែកជួរមុខ និងផ្នែកជួរក្រោយ។

**ផ្នែកជួរមុខ** គឺជាកន្លែងសម្រាប់ប្រជាពលរដ្ឋប្រាស្រ័យទាក់ទងដោយផ្ទាល់ ដើម្បីទទួលព័ត៌មាននានាអំពីការផ្ដល់សេវារដ្ឋបាល ទទួលទម្រង់បែបបទ ដាក់ពាក្យស្នើសុំ បង់ប្រាក់កម្រៃ និងទទួលលទ្ធផលសម្រេចជាផ្លូវការនៃសេវារដ្ឋបាលដែលបានស្នើសុំ។

**ផ្នែកជួរក្រោយ** គឺជាផ្នែកដែលទ្រទ្រង់ដ៏សំខាន់លើការងារបច្ចេកទេស។ ផ្នែកជួរក្រោយមានតួនាទីពិនិត្យ និងផ្ដល់យោបល់ផ្នែកបច្ចេកទេសលើការផ្ដល់សេវារដ្ឋបាលតាមវិស័យជំនាញ។

**មាត្រា១៥.—**

ការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវអនុវត្តតាមប្រកាសលេខ ៥២៨ប្រក ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០០៩ របស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃការិយាល័យច្រកចេញចូលតែមួយនៅក្រុង ស្រុក ខណ្ឌគោលដៅ។

បែបបទនិងនីតិវិធីនៃការបង្កើតយន្តការច្រកចេញចូលតែមួយសម្រាប់ផ្ដល់សេវារដ្ឋបាលនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវកំណត់ដោយសេចក្ដីណែនាំរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

### ផ្នែកទី២
### ទីកន្លែងធ្វើការ បុគ្គលិក និងប្រភេទសេវារដ្ឋបាល

**មាត្រា១៦.—**

អភិបាលក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំឱ្យមានទីកន្លែងបំពេញការងាររបស់ការិយាល័យច្រកចេញចូលតែមួយឱ្យបានសមស្រប និងបំពាក់នូវសម្ភារៈ បរិក្ខារ ឧបករណ៍ និងមធ្យោបាយសម្រាប់គាំទ្រដល់

បុគ្គលិកបំពេញការងារនៅក្នុងការិយាល័យនេះ ព្រមទាំងបង្កលក្ខណៈងាយស្រួលដល់ប្រជាពលរដ្ឋក្នុងការទទួលសេវារដ្ឋបាល។

**មាត្រា១៧.-**

រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវចាត់តាំងបុគ្គលិកមានសមត្ថភាព និងបទពិសោធការងារក្នុងចំនួនសមស្របតាមទំហំការងារ និងតាមស្ថានភាពជាក់ស្តែងនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌនីមួយៗឱ្យមកបំពេញការងារនៅផ្នែកជួរមុខនៃការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ។

ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពជំនាញពាក់ព័ន្ធនានា ត្រូវចាត់តាំងបុគ្គលិកជំនាញមានសមត្ថភាព និងបទពិសោធការងារឱ្យមកបំពេញការងារជាផ្នែកជួរក្រោយនៅក្នុងការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ។

អភិបាលក្រុង ស្រុក ខណ្ឌ ត្រូវរាយការណ៍អំពីការចាត់តាំងបុគ្គលិកមកបំពេញការងារនៅការិយាល័យច្រកចេញចូលតែមួយនេះជូនក្រុមប្រឹក្សារបស់ខ្លួន។

ក្នុងករណីដែលក្រសួង ស្ថាប័ន មន្ទីរ អង្គភាពណាមួយពុំទាន់មានបុគ្គលិកជំនាញសម្រាប់ចាត់តាំងឱ្យមកបំពេញការងារនៅផ្នែកជួរក្រោយ រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវចាត់តាំងបុគ្គលិករដ្ឋបាលរបស់ខ្លួនឱ្យមកបំពេញការងារជាបុគ្គលិកផ្នែកជួរក្រោយទទួលរ៉ាប់រងក្នុងនាមជាភ្នាក់ងារតំណាងឱ្យវិស័យជំនាញនោះ។ ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពជំនាញ ត្រូវផ្តល់ការបណ្តុះបណ្តាលដល់បុគ្គលិកដែលត្រូវបានចាត់តាំងនោះ។

បុគ្គលិកដែលបំពេញការងារនៅក្នុងការិយាល័យច្រកចេញចូលតែមួយ ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់អភិបាលក្រុង ស្រុក ខណ្ឌ។ ក្របខ័ណ្ឌ និងបៀវត្សរបស់បុគ្គលិកមកពីក្រសួង ស្ថាប័នពាក់ព័ន្ធនានាដែលបំពេញការងារនៅការិយាល័យច្រកចេញចូលតែមួយ ត្រូវស្ថិតនៅក្នុងក្រសួង ស្ថាប័នសាមីដោយទទួលបានការដំឡើងថ្នាក់ ឋានន្តរស័ក្តិ គ្រឿងឥស្សរិយយស ការលើកទឹកចិត្ត និងអត្ថប្រយោជន៍នានាតាមនីតិវិធីជាធរមាន។

**មាត្រា១៨.-**

ការិយាល័យច្រកចេញចូលតែមួយ និងយន្តការច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវផ្តល់សេវារដ្ឋបាលដូចបានកំណត់នៅក្នុងតារាងឧបសម្ព័ន្ធទី២ ភ្ជាប់នឹងអនុក្រឹត្យនេះ។

កម្រៃសេវា រយៈពេលនៃការផ្តល់សេវា និងសុពលភាពនៃសេវារដ្ឋបាល ត្រូវអនុវត្តតាមប្រកាសអន្តរក្រសួងរវាងក្រសួងមហាផ្ទៃជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លើកលែងតែមានការកំណត់ផ្សេងពីនេះ។

ក្រសួង ស្ថាប័នពាក់ព័ន្ធនានា ត្រូវបន្តផ្ទេរមុខងារក្នុងការផ្តល់សេវារដ្ឋបាលបន្ថែមទៀតទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដើម្បីបង្កលក្ខណៈងាយស្រួល និងបង្កើតការផ្តល់សេវារដ្ឋបាលឱ្យទៅជិតអ្នកប្រើប្រាស់សេវា។

**មាត្រា១៩.-**

ក្រសួងមហាផ្ទៃ ដោយមានការពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនានា ត្រូវផ្តល់ការណែនាំអំពីទម្រង់បែបបទ នីតិវិធី និងលក្ខខណ្ឌភ្ជាប់សម្រាប់ស្នើសុំសេវារដ្ឋបាលឱ្យមានលក្ខណៈសាមញ្ញ ងាយយល់ និងច្បាស់លាស់។

## ជំពូកទី៤

## យន្តការនៃការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលឃុំ សង្កាត់

**មាត្រា២០.-**

រដ្ឋបាលឃុំ សង្កាត់ត្រូវរៀបចំឱ្យមានយន្តការច្រកចេញចូលតែមួយសម្រាប់ការផ្តល់សេវារដ្ឋបាលជូនប្រជាពលរដ្ឋនៅក្នុងក្របខ័ណ្ឌសមត្ថកិច្ចរបស់ខ្លួន។

យន្តការច្រកចេញចូលតែមួយនៃរដ្ឋបាលឃុំ សង្កាត់ ត្រូវស្ថិតនៅក្រោមការដឹកនាំរបស់មេឃុំ ចៅសង្កាត់ក្នុងនាមក្រុមប្រឹក្សាឃុំ សង្កាត់ ដោយមានស្មៀនឃុំ សង្កាត់ជាសេនាធិការ។

មេឃុំ ចៅសង្កាត់ អាចប្រគល់សិទ្ធិក្នុងការពិនិត្យ ការសម្រេច និងការចុះហត្ថលេខាលើលិខិតអនុញ្ញាតឬលិខិតបញ្ជាក់ចាំបាច់មួយចំនួនជូនជំទប់ ចៅសង្កាត់រងរបស់ខ្លួនស្របតាមមាត្រា៤០នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។

**មាត្រា២១.-**

មេឃុំ ចៅសង្កាត់ ត្រូវចាត់តាំងស្មៀន ឬបុគ្គលិកជំនួយការរដ្ឋបាលឱ្យបំពេញភារកិច្ចជាបុគ្គលិកផ្តល់ព័ត៌មាន ទទួលប្រគល់ឯកសារ ទទួលកម្រៃសេវារដ្ឋបាល និងពិនិត្យផ្តល់យោបល់លើសំណើសុំសេវារដ្ឋបាលដើម្បីដាក់ជូនមេឃុំ ចៅសង្កាត់ពិនិត្យ និងសម្រេច។

ការចាត់តាំងឬការប្រគល់ភារកិច្ចជូនបុគ្គលិកផ្តល់ព័ត៌មាន ទទួលប្រគល់ឯកសារ និងទទួលកម្រៃសេវារដ្ឋបាល ត្រូវធ្វើឡើងដោយសេចក្តីសម្រេចរបស់រដ្ឋបាលឃុំ សង្កាត់។

មេឃុំ ចៅសង្កាត់ ត្រូវរៀបចំឱ្យមានទីកន្លែងសម្រាប់ការផ្តល់សេវារដ្ឋបាលឱ្យបានសមស្រប និងបំពាក់នូវសម្ភារៈ បរិក្ខារ ឧបករណ៍ និងមធ្យោបាយសម្រាប់គាំទ្រដល់ការផ្តល់សេវារដ្ឋបាល ព្រមទាំងបង្កលក្ខណៈងាយស្រួលដល់ប្រជាពលរដ្ឋក្នុងការទទួលសេវារដ្ឋបាល។

**មាត្រា២២.-**

យន្តការច្រកចេញចូលតែមួយនៃរដ្ឋបាលឃុំ សង្កាត់ ត្រូវផ្តល់សេវារដ្ឋបាលទៅតាមប្រភេទសេវា កម្រៃសេវា រយៈពេលនៃការផ្តល់សេវា និងសុពលភាពនៃសេវារដ្ឋបាល ដូចបានកំណត់នៅក្នុងប្រកាសអន្តរក្រសួងរវាងក្រសួងមហាផ្ទៃជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើកលែងតែមានការកំណត់ផ្សេងពីនេះ។

**មាត្រា២៣.-**

ក្រសួងមហាផ្ទៃត្រូវផ្តល់ការណែនាំអំពីទម្រង់បែបបទ នីតិវិធី និងលក្ខខណ្ឌភ្ជាប់សម្រាប់ស្នើសុំសេវារដ្ឋបាលឱ្យមានលក្ខណៈសាមញ្ញ ងាយយល់ និងច្បាស់លាស់។

## ជំពូកទី៥

## ការគ្រប់គ្រងនិងការចាត់ចែងចំណូលសេវារដ្ឋបាល

**មាត្រា២៤.‒**

រដ្ឋបាលថ្នាក់ក្រោមជាតិមានសិទ្ធិទទួលបានចំណូលពីកម្រៃសេវារដ្ឋបាល។

ចំណូលដែលទទួលបានពីកម្រៃនៃការផ្តល់សេវារដ្ឋបាលរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់នីមួយៗ ត្រូវបង់ចូលថវិកាថ្នាក់ជាតិ និង/ឬថវិកាថ្នាក់ក្រោមជាតិតាមគោលការណ៍កំណត់។

ការគ្រប់គ្រងចំណូល ចំណាយ ការកត់ត្រា និងការបែងចែកប្រាក់រង្វាន់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវអនុវត្តតាមច្បាប់ លិខិតបទដ្ឋាន គោលការណ៍ និងនីតិវិធីនានាដែលពាក់ព័ន្ធនឹងការគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

**មាត្រា២៥.‒**

ការបែងចែកចំណូលដែលប្រមូលបានពីការផ្តល់សេវារដ្ឋបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ និងការបែងចែកប្រាក់រង្វាន់លើកទឹកចិត្តសម្រាប់ឧបត្ថម្ភដល់បុគ្គលិក និងសម្រាប់ពង្រឹងយន្តការផ្តល់សេវារដ្ឋបាល ត្រូវអនុវត្តតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន លើកលែងតែមានការកំណត់ផ្សេងពីនេះ។

## ជំពូកទី៦

## ការគាំទ្រ ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃ

**មាត្រា២៦.‒**

គ.ជ.អ.ប មានតួនាទីក្នុងការសម្របសម្រួលជាមួយក្រសួង ស្ថាប័នជំនាញពាក់ព័ន្ធនានាក្នុងការគាំទ្រផ្នែកគោលនយោបាយ ការកៀរគរធនធាន និងការគាំទ្របច្ចេកទេសពីអ្នកពាក់ព័ន្ធនានាក្នុងដំណើរការនៃការផ្ទេរមុខងារ និងដំណើរការអនុវត្តការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

គ.ជ.អ.ប អាចប្រើប្រាស់យន្តការដែលមានស្រាប់ដូចជា ក្រុមពិគ្រោះយោបល់បច្ចេកទេសអន្តរក្រសួងដើម្បីសម្របសម្រួលក្នុងដំណើរការនៃការផ្ទេរមុខងារ និងដំណើរការអនុវត្តការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

**មាត្រា២៧.‒**

ក្រសួងមហាផ្ទៃមានតួនាទីសម្របសម្រួលក្នុងការបង្កើតអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត ការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងយន្តការច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងរដ្ឋបាលឃុំ សង្កាត់ ព្រមទាំងគាំទ្រផ្នែកបច្ចេកទេសដល់ដំណើរការផ្តល់សេវារដ្ឋបាល ការអភិវឌ្ឍសមត្ថភាព ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃលើការអនុវត្តការផ្តល់សេវារដ្ឋបាលដោយសហការជាមួយក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធនានា។

ក្រសួងមហាផ្ទៃ ត្រូវសម្របសម្រួលជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួង ស្ថាប័នពាក់ព័ន្ធនានា និងរដ្ឋបាលរាជធានី ខេត្ត ដើម្បីគាំទ្រដល់ការរៀបចំទីកន្លែងផ្តល់សេវា និងបំពាក់សម្ភារៈ បរិក្ខារ ឧបករណ៍ និងមធ្យោបាយដល់អង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត និងការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ។

ក្រសួងមហាផ្ទៃ អាចប្រើប្រាស់ប្រព័ន្ធគ្រប់គ្រង ឬយន្តការដែលមានស្រាប់ដើម្បីធានាលើការគ្រប់គ្រង ការគាំទ្រ ការសម្របសម្រួល និងការអនុវត្តកិច្ចការនេះ។

**មាត្រា២៨.–**

ក្រសួង ស្ថាប័នពាក់ព័ន្ធនានា ត្រូវសម្របសម្រួល និងជំរុញមន្ទីរ អង្គភាពជំនាញរបស់ខ្លួនក្នុងការចាត់តាំងបុគ្គលិកដែលមានសមត្ថភាព និងបទពិសោធការងារឱ្យមកបំពេញការងារជាបុគ្គលិកផ្នែកជួរក្រោយនៅក្នុងអង្គភាពច្រកចេញចូលតែមួយ ការិយាល័យច្រកចេញចូលតែមួយ និងយន្តការច្រកចេញចូលតែមួយ ព្រមទាំងផ្តល់ការគាំទ្រលើការអភិវឌ្ឍសមត្ថភាព ការគាំទ្រផ្នែកបច្ចេកទេស ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃលើការផ្តល់សេវារដ្ឋបាលដែលបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។

**មាត្រា២៩.–**

រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗត្រូវធានាឱ្យមានការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃជាប្រចាំ ព្រមទាំងទទួលដោះស្រាយនូវរាល់ភាពមិនប្រក្រតីក្នុងការផ្តល់សេវារដ្ឋបាលនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

## ជំពូកទី៧
## អន្តរប្បញ្ញត្តិ

**មាត្រា៣០.–**

រដ្ឋបាលរាជធានី ខេត្ត ត្រូវបង្កើតអង្គភាពច្រកចេញចូលតែមួយឱ្យបានយ៉ាងយូរត្រឹមដំណាច់ឆមាសទី១នៃឆ្នាំ២០១៧។

រដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលមានលក្ខណសម្បត្តិស្របតាមការកំណត់របស់ក្រសួងមហាផ្ទៃ ត្រូវបង្កើតការិយាល័យច្រកចេញចូលតែមួយឱ្យបានយ៉ាងយូរត្រឹមដំណាច់ឆ្នាំ២០១៧។

រដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលពុំទាន់មានលក្ខណសម្បត្តិសមស្របសម្រាប់បង្កើតការិយាល័យច្រកចេញចូលតែមួយ និងរដ្ឋបាលឃុំ សង្កាត់ ត្រូវបង្កើតយន្តការច្រកចេញចូលតែមួយឱ្យបានយ៉ាងយូរត្រឹមដំណាច់ឆ្នាំ២០១៧។

## ជំពូកទី៨
## អវសានប្បញ្ញត្តិ

**មាត្រា៣១.–**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៣២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែកុម្ភៈ ឆ្នាំ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីសូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.អ.ប**

**សម្តេចក្រឡាហោម ស ខេង**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ឧបសម្ព័ន្ធ៣.គ

សេចក្តីជម្រាបរបស់ក្រសួងដែនដី នគរូនីយកម្ម និងសំណង់ លេខ១៨៩៧ដនស/អរប ចុះថ្ងៃទី ០៧ សីហា ២០១៨ ជូនដល់ប្រធានមន្ទីរដែនដី នគរូនីយកម្ម និងសំណង់ រាជធានីខេត្ត

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

លេខ : ១៨៩៧ ដនស/អរប.

ថ្ងៃអង្គារ ១១ រោច ខែអាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ២០១៨

**ជម្រាបមក**

**លោកប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត**

**កម្មវត្ថុ÷** អំពីមុខសេវាសាធារណៈរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដែលត្រូវបញ្ចូលឱ្យដំណើរការតាមយន្តការអង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត

**យោង ÷**- អនុក្រឹត្យលេខ ១៨ អនក្រ.បក ចុះថ្ងៃទី ០៨ ខែកុម្ភៈ ឆ្នាំ ២០១៧ ស្តីពីការបង្កើតយន្តការច្រកចេញចូលតែមួយសម្រាប់ការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

- លិខិតលេខ ១៣២១ សជណ ចុះថ្ងៃទី ០២ ខែសីហា ឆ្នាំ ២០១៨ របស់ក្រសួងមហាផ្ទៃ

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **លោកប្រធានមន្ទីរ** ជ្រាបថា ដើម្បីធានានិរន្តរភាពនៃការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ ស្នើ **លោកប្រធាន** សម្របសម្រួលជាមួយរដ្ឋបាលរាជធានី ខេត្ត បញ្ចូលមុខសេវាសាធារណៈរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដែលមិនមានភាពស្មុគ្រស្មាញចំនួន ៣៣ ចង្កោមសេវា ស្មើ ១១១ មុខសេវា(ឧបសម្ព័ន្ធទី១) និងហិរញ្ញប្បទានពេលវេលា(ឧបសម្ព័ន្ធទី ២) ដូចមានជូនភ្ជាប់មកជាមួយ ឱ្យដំណើរការតាមយន្តការអង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត ។

ចំពោះមុខសេវាផ្សេងទៀតដែលមានភាពស្មុគ្រស្មាញពាក់ព័ន្ធនឹងក្រមរដ្ឋប្បវេណី ក្រមនីតិវិធីរដ្ឋប្បវេណី ប្រកាសអន្តរក្រសួងលេខ ៥៩ ប្រក.ដនស/១១ ស្តីពីការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណី និងប្រកាសអន្តរក្រសួងលេខ ៣០ កយ.ដនស ប្រក/១៣ ស្តីពីនីតិវិធីនៃការចុះបញ្ជីអំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី នឹងបញ្ចូលឱ្យដំណើរការតាមយន្តការអង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត នៅដំណាក់កាលបន្ទាប់ ក្រោយពីបានធ្វើការបណ្តុះបណ្តាលមន្ត្រីជំនាញក្រោមឱវាទរួច។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម **លោកប្រធានមន្ទីរ** ជ្រាប និងចាត់ចែងអនុវត្ត។

សូម **លោកប្រធានមន្ទីរ** ទទួលនូវការរាប់អានពីខ្ញុំ។

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**ជា សុផារ៉ា**

**ចម្លងជូន÷**

- ក្រសួងមហាផ្ទៃ
- សាលារាជធានី ខេត្ត ទាំង ២៥
- ឯកសារ-កាលប្បវត្តិ

អាសយដ្ឋានៈ ដីឡូត៍លេខ ៧៧១-៧៧៣ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ
ទូរស័ព្ទ /ទូរសារ (885) 23 215 660 / 23 215 277 គេហទំព័រ www.mlmupc.gov.kh អ៊ីមែល mlmupc.cabinet@gmail.com